ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៤ លេខ៤ | តុលា - ធ្នូ ឆ្នាំ២០១០ | តម្លៃ ១.៥០០រ

# ការពិនិត្យឡើងវិញពីគោលនយោបាយកសិកម្ម និងការស្រាវជ្រាវខាងគោលនយោបាយ[១]

## សេចក្ដីផ្ដើម

តាំងពីការកកើតរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋសភាអាណត្តិទីមួយនៅឆ្នាំ១៩៩៣ មក អាទិភាពចំបងនៅក្នុងយុទ្ធសាស្ត្រជាតិ និងផែនការអភិវឌ្ឍន៍ ដែលអនុម័តឡើងដើម្បីអភិវឌ្ឍប្រទេស គឺការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ក្នុងគោលបំណងជួយជនក្រីក្រ ឱ្យចាកពីភាពក្រីក្រ និងតម្រង់ទិសឲ្យកម្ពុជា ដើរចំគន្លងនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ។ តាំងពីពេលនោះមក វិស័យកសិកម្មមានសក្ដានុពលធំធេង ហើយកំណើនផលិតភាព អាចផ្ដល់ផ្លែផ្កាជាការងារ និងប្រាក់ចំណូល ដែលមានចីរភាពល្អ ដើម្បីជួយកាត់បន្ថយភាពក្រីក្រ ។ គោលនយោបាយអភិវឌ្ឍន៍របស់រដ្ឋាភិបាល បានកំណត់វិស័យនេះជាក្បាលម៉ាស៊ីនជំរុញកំណើនសេដ្ឋកិច្ច សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ ។ អត្ថបទនេះព្យាយាម (១) ពិនិត្យឡើងវិញពីគោលនយោបាយសន្តិសុខស្បៀង និងអភិវឌ្ឍន៍កសិកម្ម ដែលមានស្រាប់នៅកម្ពុជា (២) វាយតម្លៃពីការស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ អំពីកសិកម្មនៅកម្ពុជា និង (៣) កំណត់ពីកង្វះខាតចំណេះដឹង និងវិស័យសក្ដានុពល សម្រាប់ការស្រាវជ្រាវទៅអនាគត ដើម្បីកែលំអការអភិវឌ្ឍកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជា ។



វិស័យកសិកម្ម ត្រូវធ្វើពិពិធកម្ម និងរៀបចំតម្រូវទៅតាមលក្ខខ័ណ្ឌមូលដ្ឋានៈ ភូមិមួយដែលលិចទឹករៀងរាល់ឆ្នាំ នៅឃុំព្រែកក្មេង ខេត្តកណ្ដាល ។

## ប្រវត្តិវិស័យកសិកម្មនៅកម្ពុជា

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ គួរឱ្យកោតសរសើរក្នុងទសវត្សរ៍កន្លងទៅ នៅមុនពេលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីវិបត្តិសេដ្ឋកិច្ចសាកលក្នុងឆ្នាំ២០០៩ ។ ផសស មានកំណើនជាមធ្យម ៩,៥% ក្នុងមួយឆ្នាំ នៅអំឡុងឆ្នាំ១៩៩៩-២០០៨ ហើយឡើងខ្ពស់បំផុតដល់ ១៣,៣% នៅឆ្នាំ២០០៥ (ក្រាហ្វិក ១) ដោយសារមានសេដ្ឋកិច្ចបើកចំហ និងបរិយាកាសម៉ាក្រូសេដ្ឋកិច្ចមានស្ថិរភាព វិនិយោគផ្ទាល់ពីបរទេស (FDI) និងការនាំចេញកើនឡើង ហើយអតិផរណា ក៏មានកម្រិតទាប ត្រឹម ៥,0%

## មាតិកា

ការពិនិត្យឡើងវិញពីគោលនយោបាយកសិកម្ម និង ការស្រាវជ្រាវខាងគោលនយោបាយ ........................ ១
យុទ្ធសាស្ត្រវិស័យកសិកម្មនៅកម្ពុជាៈ ជម្រើស អភិវឌ្ឍន៍ នៅពេលអនាគត សម្រាប់ផលិតកម្មស្រូវ .. ៧
សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជាៈ លំនាំ និង មាគ៌ាឆ្ពោះទៅរកជោគជ័យ .................................... ១២
ជំរើសគោលនយោបាយសម្រាប់ជនរងគ្រោះៈ កំណើនប្រាក់ចំណូល និងការគាំពារសង្គម ............... ១៨
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ............ ២៣
— ស្ថានភាពក្នុងប្រទេស ............... ២៥
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI .................................... ៣២

---

១ អត្ថបទនេះរៀបចំឡើងដោយបណ្ឌិត ថេង វុទ្ធី អ្នកស្រាវជ្រាវ និងជាអ្នកសម្របសម្រួលកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI និងលោក ឈឹម ឈន់ ជាជំនួយការស្រាវជ្រាវក្នុងកម្មវិធីជាមួយគ្នា ។ នេះជាសេចក្ដីសង្ខេបនៃឯកសារពិភាក្សាគោលនយោបាយ សម្រាប់កិច្ចប្រជុំបូកសរុបស្ដីពីគោលនយោបាយកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជា នៃ CDRI-IFPRI រៀបចំដោយក្រុមអ្នកស្រាវជ្រាវនៃ CDRI និងក្រោមជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពី USAID ។

ក្រាហ្វិក ១៖ កំណើន ផសស នៅអំឡុងឆ្នាំ១៩៩៤-២០០៨ (ថ្លៃថេរឆ្នាំ២០០០)




ប្រភព៖ NIS and National Accounts (2008)

ក្រាហ្វិក ២៖ ចំណែកក្នុង ផសស ជាភាគរយ (ថ្លៃថេរឆ្នាំ២០០០) សេវាកម្ម ឧស្សាហកម្ម កសិកម្ម




ប្រភព៖ NIS and National Accounts (2008)

លើកលែងតែនៅឆ្នាំ២០០៨ ដែលវាឡើងដល់ ២២% ដោយសារថ្លៃស្បៀងអាហារស្ទុះឡើងខ្ពស់ភ្លាមៗ ។ ទោះជាយ៉ាងនេះក្ដី កំណើនសេដ្ឋកិច្ចនៅកម្ពុជាពឹងផ្អែកជាចំបងលើ ៤ វិស័យឈានមុខ គឺមាន កាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម ។

មូលដ្ឋានគ្រឹះសេដ្ឋកិច្ចបានផ្លាស់ប្ដូរយ៉ាងជ្រាលជ្រៅ ហើយចាប់ពីឆ្នាំ២០០៦ មក វិស័យកសិកម្មបានធ្លាក់មកនៅលំដាប់បន្ទាប់ពីវិស័យសេវាកម្ម និងឧស្សាហកម្ម ។ ចំណែកនៃកសិកម្មនៅក្នុង ផសស បានធ្លាក់ចុះជាលំដាប់ ប៉ុន្តែវិស័យនេះនៅតែជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចកម្ពុជា ដោយរួមចំណែក ២៧% នៃ ផសស នៅឆ្នាំ២០០៨ (ក្រាហ្វិក ២) ។ កសិកម្មមានអត្រាកំណើនជាមធ្យម ៤,៥% ក្នុងមួយឆ្នាំ នៅអំឡុងឆ្នាំ១៩៩៨-២០០៨ (ក្រាហ្វិក ៣) ដោយបានរួមចំណែក ២% ក្នុងកំណើន ផសស នៅអំឡុងពេលនោះ (Guimbert 2010) ។ ការថយចុះតម្លៃបន្ថែមនៅក្នុង ផសស វិស័យកសិកម្ម បង្កឡើងដោយកំណើនគួរឱ្យកត់សម្គាល់ក្នុងឧស្សាហកម្ម ។ វិស័យកសិកម្មតំណាងឲ្យប្រមាណ ៥៦% នៃកម្លាំងពលកម្មមានការងារសរុបនៅឆ្នាំ២០០៧ (IMF 2009) ហើយផលិតភាពពលកម្មបានកើនឡើង ២% គិតពីឆ្នាំ១៩៩៨ ដល់ ២០០៧ (World Bank 2009) ។ កំណើននេះផុសចេញពីកំណើនដីធ្លី កម្លាំងពលកម្ម និងផលិតភាព ប៉ុន្តែលក្ខខណ្ឌអាកាសធាតុ ធ្វើឲ្យវាប្រែប្រួលមិនទៀងទាត់រហូតដល់ឆ្នាំ២០០៥ ទើបមានស្ថិរភាពវិញ (ក្រាហ្វិក ៣) ដោយសារការ

ក្រាហ្វិក ៣៖ កំណើនតាមវិស័យនៃ ផសស ឆ្នាំ១៩៩៤-២០០៩ (ថ្លៃថេរឆ្នាំ២០០០) កសិកម្ម ឧស្សាហកម្ម សេវាកម្ម




ប្រភព៖ NIS and National Accounts (2008) and MAFF (2010)

ពង្រីកផលិតកម្មផលដំណាំ ដែលបានរួមចំណែក ៤៧,៥% នៃ ផសស វិស័យកសិកម្ម នៅអំឡុងឆ្នាំ១៩៩៨-២០០៨ ។ នៅអំឡុងពេលនោះ ស្រូវនៅតែជាអនុវិស័យដំណាំធំជាងគេ ដោយរួមចំណែកបាន ២៦% នៃ ផសស ក្នុងវិស័យនេះ (IMF 2004 & 2009) ។

## គោលនយោបាយដើម្បីជំរុញការអភិវឌ្ឍកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជា (RGC) បានចែងពីគោលនយោបាយកសិកម្ម នៅក្នុងយុទ្ធសាស្ត្រចតុកោណថា៖ "ត្រូវលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម ដើម្បីឲ្យវិស័យនេះអាចក្លាយជាកម្លាំងខ្លាំងក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ។" សមាសធាតុសំខាន់ៗនៃគោលនយោបាយអភិវឌ្ឍន៍កសិកម្មផ្អែកលើគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ឆ្នាំ២០០៣ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច (SEDP-II) ឆ្នាំ២០០១-២០០៥ និងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ២០០៣-២០០៥ ហើយផ្ដោតលើ (១) ការលើកកម្ពស់ផលិតភាព និងពិពិធកម្មកសិកម្ម (២) កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន (៣) កំណែទម្រង់ជលផល និង (៤) កំណែទម្រង់ព្រៃឈើ (RGC 2004) ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០០៦-២០១០ បានបំពេញបន្ថែមលើគោលនយោបាយអភិវឌ្ឍន៍កសិកម្ម ដោយមានគោលដៅចំបង "កាត់បន្ថយភាពក្រីក្រ និងអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីពង្រឹងវិស័យកសិកម្ម" (RGC 2006) ។ NSDP ក៏បានចែងពីតម្រូវការចំបងបង្កើតយុទ្ធសាស្ត្រជាតិលើវិស័យកសិកម្ម និងទឹក (SAW) ឲ្យបានត្រឹមឆ្នាំ២០០៦ ប៉ុន្តែយុទ្ធសាស្ត្រនេះបានហើយរួចរាល់ក្នុងឆ្នាំ២០០៧ គឺយឺតជាងផែនការមួយឆ្នាំ ។ SAW បានកំណត់ចេញជាកម្មវិធីចំនួន ៥ គឺ ការកសាងសមត្ថភាពស្ថាប័ន សន្តិសុខស្បៀង កសិកម្ម និងកសិពាណិជ្ជកម្ម ការគ្រប់គ្រងធនធានទឹក និង ការស្រាវជ្រាវនិងអភិវឌ្ឍវិស័យកសិកម្ម (MAFF & MoWRAM 2007) ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម ឆ្នាំ២០០៦-២០១០ កសាងឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

(MAFF) បានកំណត់គោលដៅជាអាទិភាពចំនួន ៧ ឧបសគ្គរារាំង ព្រមទាំងសកម្មភាពត្រូវអនុវត្ត ដើម្បីសម្រេចគោលដៅទាំងនេះ ។ គោលដៅអាទិភាពទាំង ៧ នោះគឺ (១) សន្តិសុខស្បៀង ផលិតភាព និងពិពិធកម្ម (២) ការកែលំអពង្រឹងការស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយអពី បច្ចេកទេសកសិកម្ម (៣) ទីផ្សារសម្រាប់ ផលិតផលកសិកម្ម (៤) ក្របខណ្ឌអភិវឌ្ឍន៍ស្ថាប័ន និងបទបញ្ញត្តិច្បាប់ (៥) កំណែទម្រង់ដីធ្លី ការកាន់កាប់ដីធ្លី និងលទ្ធភាពទទួលបានដីធ្លីប្រើប្រាស់សម្រាប់អ្នកក្រ (៦) កំណែទម្រង់ជលផល និង (៧) កំណែទម្រង់ព្រៃឈើ (MAFF 2005) ។

ថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយមួយដើម្បីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។ គោលនយោបាយនេះ បានជួយកែលំអថែមទៀតដល់ វិធានការខាងគោលនយោបាយជាយុទ្ធសាស្ត្រចំបងៗរបស់រដ្ឋាភិបាល សម្រាប់ជំរុញការអភិវឌ្ឍកសិកម្ម ដោយសង្កត់ធ្ងន់លើល្បឿន និងខ្នាតមួយថ្មី ដើម្បីពង្រឹងបន្ថែមនូវមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ច បង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ និងកែលំអកម្រិតជីវភាពរបស់ប្រជាជនកម្ពុជា ។ ដើម្បីសម្រេចគោលដៅខាងលើ គោលនយោបាយថ្មី បានកំណត់យុទ្ធសាស្ត្រមានមុខព្រួញ ៣ គឺៈ ការបង្កើនផលិតភាព ពិពិធកម្ម និង ពាណិជ្ជភាវូបនីយកម្មកសិកម្ម (RGC 2010) ។

គោលនយោបាយផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍកសិកម្ម សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ មានដូចជាៈ

- គោលនយោបាយជាតិលើវិស័យធនធានទឹក
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធនធានទឹក និងឧតុនិយម ឆ្នាំ២០០៩-២០១៣
- សារាចរលេខ ៣ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅព្រះរាជាណាចក្រកម្ពុជា
- សេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជា ស្តីពី គោលនយោបាយជាតិលើវិស័យជលផល
- គោលនយោបាយជាតិលើវិស័យជលផល និងច្បាប់ស្តីពីវិស័យជលផល (MAFF 2006)
- កម្មវិធីជាតិសម្រាប់សន្តិសុខស្បៀងក្នុងគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៧-២០១១
- ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា ឆ្នាំ២០០៨-២០១២
- កម្មវិធីសកម្មភាពជាតិ ដើម្បីបន្សាំទៅនឹងការផ្លាស់ប្តូរអាកាសធាតុ (NAPA)
- ច្បាប់ស្តីពី វិនិយោគ (ថ្ងៃទី៥ សីហា ១៩៩៤)
- ច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ (ថ្ងៃទី២៣ មីនា ២០០៣)
- អនុក្រឹត្យស្តីពី ការដាក់បញ្ចាំ-ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច (ចុះថ្ងៃទី២៩ សីហា ២០០៧)
- ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/០០៩ (ចុះថ្ងៃទី២០ មិថុនា ២០០៩) ដើម្បីផ្តល់ការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មនៅកម្ពុជា ។

## ការស្រាវជ្រាវគោលនយោបាយដែលមានស្រាប់ និងកង្វះខាតចំណេះដឹង

នៅកម្ពុជា មានស្ថាប័នស្រាវជ្រាវគោលនយោបាយជាច្រើន ដូចជា ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC) សាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល (LI) មជ្ឈមណ្ឌលមច្ឆាពិភពលោក (World Fish Centre) វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា (EIC) និង វិទ្យាស្ថានកម្ពុជាដើម្បីសិក្សាការអភិវឌ្ឍន៍ (CIDS) ជាដើម ។ ប៉ុន្តែលទ្ធភាពប្រើប្រាស់ឯកសារស្រាវជ្រាវខាងគោលនយោបាយ ដែលមានផ្សព្វផ្សាយជាសាធារណៈនៅមានតិចណាស់ ជាពិសេសសម្រាប់វិទ្យាស្ថានស្រាវជ្រាវសាធារណៈ និងក្រុមផ្តល់គំនិតនានា ។ ការពិនិត្យឡើងវិញលើ ការស្រាវជ្រាវខាងគោលនយោបាយដែលមានស្រាប់នេះ ផ្តោតជាចំបងលើ ប្រព័ន្ធស្រោចស្រព ដំណាំកសិកម្ម ជលផល អនុវិស័យចិញ្ចឹមសត្វ ហើយអាចមានផ្នែកជាប់ទាក់ទិនមួយចំនួនទៀត ។

ការស្រាវជ្រាវគោលនយោបាយពាក់ព័ន្ធនឹងធនធានទឹកគ្របដណ្តប់លើបញ្ហាអភិបាលកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ផលចំណេញខាងសេដ្ឋកិច្ច និងការសិក្សាសាកល្បងមួយចំនួនពីគម្រោងស្រោចស្រព ។ ការសិក្សាទាំងនេះរកឃើញថា ថ្នាក់ដឹកនាំមានសមត្ថភាពទាប និងស្ថាប័នទន់ខ្សោយ គឺជាកំហិតចំបងនៅក្នុងគម្រោងស្រោចស្រពភាគច្រើន ។ គម្រោងស្រោចស្រពជាច្រើន រៀបចំមិនទាន់សមស្របទេ ដែលនាំឲ្យមានកង្វះទឹក ការចែកចាយទឹកមិនស្មើភាព និងទំនាស់គ្នាក្នុងចំណោមអ្នកប្រើប្រាស់ទឹក ។ ទំនាស់ខ្លះអាចដោះស្រាយនៅក្នុងសហគមន៍ ប៉ុន្តែខ្លះទៀត ត្រូវមានអន្តរាគមន៍ពីអាជ្ញាធរខេត្ត និងថ្នាក់ជាតិ (CDRI 2010) ។ ការចូលរួមរបស់សមាជិកសហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ក្នុងការបង់ថ្លៃទឹក ការថែទាំ ការធ្វើជាម្ចាស់ និងការចែកចាយទឹក ជាកត្តាសំខាន់ណាស់ សម្រាប់ការគ្រប់គ្រងប្រព័ន្ធស្រោចស្រពឲ្យបានជោគជ័យ ។ ទឹកក្រោមដីនៅកម្ពុជា មិនទាន់មានការស្រាវជ្រាវនៅឡើយទេ (Ros 2010) ។ ទឹកក្រោមដី អាចក្លាយជាប្រភពសម្រាប់ការស្រោចស្រពបានពេញៗមួយឆ្នាំ និងជួយកាត់បន្ថយផលប៉ះពាល់នៃគ្រោះរាំងស្ងួត និងបម្រែបម្រួលអាកាសធាតុ ទៅលើ កសិកម្ម និងសន្តិសុខស្បៀង ។

ការស្រាវជ្រាវមួយចំនួនស្តីពី ពាណិជ្ជកម្មកសិកម្មរវាងកម្ពុជា និងប្រទេសអាស៊ាន ហើយនិង រវាងអាស៊ាន និងប្រទេសចិន បានរកឃើញថា ទំនិញកសិកម្ម ដូចជា សត្វចិញ្ចឹម (ជ្រូក គោ ក្របី) និង ផលដំណាំ (កៅស៊ូ ដំឡូងឈើ ពោត សណ្តែកសៀង និងស្រូវ) បានបម្រើការដោះដូរពាណិជ្ជកម្មជាចំបង ។ ពាណិជ្ជកម្មឆ្លងកាត់ព្រំដែននេះ អាចជួយរក្សាស្ថិរភាពថ្លៃទីផ្សារ និងពង្រីកទីផ្សារ សម្រាប់ផលិតផលកសិកម្មកម្ពុជា ។ ប៉ុន្តែ

កម្ពុជាទទួលបានផលប្រយោជន៍តិចតួច និងមានសមត្ថភាពប្រកួតប្រជែងតិចជាងប្រទេសអាស៊ានដទៃទៀត ដោយសារទំនិញកម្ពុជាស្ទើរគ្រប់មុខសុទ្ធតែជាផលិតផលដើម និងនាំចេញតាមរយៈច្រកពាណិជ្ជកម្មមិនផ្លូវការ ។ ប្រទេសថៃ និងវៀតណាមបានទាញយកចំណេញពីកម្ពុជា ដោយធ្វើការកែច្នៃទំនិញជាច្រើន ដែលនាំចូលពីកម្ពុជា រួចលក់វាចេញទៅទីផ្សារពិភពលោក (Ballard & Thun 2007; Hing & Nou 2006; Hing & Thun 2009) ។

នៅកម្ពុជា មានការសិក្សាជាច្រើនអំពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច សន្តិសុខស្បៀង និងភាពក្រីក្រ ដោយប្រើការវិភាគលើទិន្នន័យបានពីអង្កេត នៅត្រង់ចំណុចមួយនៃពេលវេលា (cross-sectional data) និងទិន្នន័យបានពីអង្កេតតាមពេលវេលាបន្តបន្ទាប់ (panel data) និងដោយប្រើវិធីសាស្ត្របែបគុណភាព ។ ការសិក្សាបង្ហាញថា ការកាត់បន្ថយភាពក្រីក្រមិនទំនងជាផ្សារភ្ជាប់ទៅនឹងកំណើនសេដ្ឋកិច្ចទេ ហើយកំណើនសេដ្ឋកិច្ច ក៏គ្មានលក្ខណៈរាប់បញ្ចូលដែរ ។ ភាពក្រីក្រ និងអសន្តិសុខស្បៀង នៅតែមានកម្រិតខ្ពស់នៅតាមតំបន់ជនបទ ។ បញ្ហាកម្មសិទ្ធិដីធ្លី នៅតែជាកត្តាកំណត់យ៉ាងសំខាន់នៃភាពក្រីក្រ និងអសន្តិសុខស្បៀង សម្រាប់គ្រួសារនៅតាមជនបទកម្ពុជា ។ គ្រួសារធំៗដែលមានសមាជិកក្នុងបន្ទុកមច្រើន ការអប់រំតិចតួច និង ការថែទាំសុខភាពទន់ខ្សោយ គឺជាកត្តាកំណត់ផ្នែកខាងក្នុងដ៏ចំបងនៃភាពក្រីក្រនៅតាមសហគមន៍ជនបទ ។ លទ្ធភាពតិចតួចក្នុងការទទួលសេវាសាធារណៈ ដូចជា ការអប់រំ ការថែទាំសុខភាព និងការបណ្តុះបណ្តាលវិជ្ជាជីវៈ កង្វះលទ្ធភាពទទួលបានឥណទាន និងហេដ្ឋារចនាសម្ព័ន្ធខ្សត់ខ្សោយ (ផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រព) គឺជាកត្តាផ្នែកខាងក្រៅដែលកំណត់ភាពក្រីក្រនៅជនបទ ។ គេរកឃើញថា ការកែលំអចំណុចដ៏ចាំបាច់សម្រាប់វិស័យកសិកម្ម គឺជាកត្តាសំខាន់ណាស់ដើម្បីលើកកម្ពស់ជីវភាព និងសន្តិសុខស្បៀងនៅតំបន់ជនបទ រីឯធនធានរួម (ពិសេសធនធានធម្មជាតិ) និងឱកាសការងារទទួលបានប្រាក់កម្រៃ គឺជាប្រព័ន្ធសុវត្ថិភាពដ៏សំខាន់សម្រាប់ជនក្រីក្រ (So *et al.* 2010; Fitzgerald & So 2007; Ballard *et al.* 2007) ។ ចំនួនគ្រួសារគ្មានដីធ្លី បានកើនឡើងគួរឲ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារគ្រួសារកកើតថ្មី និងទីផ្សារដីធ្លី ។ ប៉ុន្តែគេមិនទាន់ដឹងច្បាស់ទេពីបញ្ហាប្រឈមនានា និងអន្តរកម្មរវាងភាពគ្មានដីធ្លី និងអសន្តិសុខស្បៀង ជាមួយនឹងការការពារសង្គម និងភាពងាយរងគ្រោះ ។

ការសិក្សាស្រាវជ្រាវខាងគោលនយោបាយជាច្រើន បានផ្តោតលើបញ្ហាជលផលទឹកសាបផ្សេងៗ ដើម្បីពិនិត្យលើគោលនយោបាយរដ្ឋាភិបាលស្តីពី កំណែទម្រង់វិស័យជលផល ។ គេរកឃើញថា ការអនុវត្ត និងចីរភាពនៃការគ្រប់គ្រងជលផលរួមគ្នា បានជួបឧបសគ្គរាំង ដោយសារកង្វះការកំណត់សិទ្ធិលើទ្រព្យសម្បត្តិ និងព្រំដែនធនធានឲ្យបានច្បាស់លាស់ និងអវត្តមានបទបញ្ញត្តិច្បាប់ ។ បញ្ហានេះនាំឲ្យមានជម្លោះរវាងសហគមន៍នេសាទនានា និងជម្លោះរវាងសហគមន៍នេសាទ និងសហគមន៍កសិកម្ម ដែលប្រជែងគ្នាដណ្តើមប្រើប្រាស់ធនធានទឹក (Viner *et al.* 2006; So *et al.* forthcoming) ។ ជនក្រីក្រនៅមិនទាន់ទទួលបានអត្ថប្រយោជន៍ពីកំណើនលទ្ធភាពមានកន្លែងនេសាទទេ ។ ចំណូលជាមធ្យមនៃគ្រួសារនេសាទតូចតាច គឺ ១២ដុល្លារ ក្នុងការចេញនេសាទ ១ លើក នៅរដូវបើកការនេសាទ និង ៤,៦ដុល្លារ ក្នុងការចេញនេសាទ ១ លើក នៅរដូវបិទការនេសាទ ។ ប៉ុន្តែបើដកថ្លៃពលកម្មគ្រួសារចេញពីចំណូលសុទ្ធនោះ ប្រាក់ចំណូលពិតប្រាកដនៅសល់ត្រឹម ៤,៥ដុល្លារ សម្រាប់រដូវបើកការនេសាទ និង ១,៦ដុល្លារ សម្រាប់រដូវបិទការនេសាទ (Hap & Madhusudan 2009) ។ បម្រែបម្រួលផ្នែកជលសាស្ត្រ ការដុះដីល្បាប់ ការអភិវឌ្ឍកសិកម្មនៅជុំវិញបឹងទន្លេសាប និងសមត្ថភាពគ្រប់គ្រងរបស់សហគមន៍នេសាទនាពេលបច្ចុប្បន្ន បានគំរាមកំហែងដល់ការប្រើប្រាស់បឹងទន្លេសាបប្រកបដោយចីរភាព និងសុវត្ថិភាពដល់បរិស្ថាន (Chadwick *et al.* 2008) ។ ម្យ៉ាងវិញទៀត កម្រិតទឹកបានធ្លាក់ទាបជាងមុន ៥ម៉ែត្រ នៅទន្លេមេគង្គ និង ៣ម៉ែត្រ នៅបឹងទន្លេសាប ធៀបនឹងឆ្នាំកន្លងទៅ ដោយសារការសាងសង់ទំនប់នៅតំបន់ខ្សែទឹកខាងលើ ។ កម្រិតទឹកទាបនេះ នឹងប៉ះពាល់អវិជ្ជមានដល់ជម្រកត្រី និងអេកូឡូស៊ីជលផលទឹកសាបនៅកម្ពុជា ។ គេនៅមិនទាន់ដឹងច្បាស់ទេពី ឥទ្ធិពលនៃកម្រិតទឹកទាប ទៅលើចំនួនមច្ឆាជាតិ ការពងកូនរបស់ត្រី និងសន្តិសុខស្បៀងនៅកម្ពុជា ។ ការស្រាវជ្រាវគ្រប់ជ្រុងជ្រោយពីជលផលសមុទ្រ ក៏នៅមិនទាន់មានដែរ ។

គោលនយោបាយរដ្ឋាភិបាលសម្រាប់អនុវិស័យសត្វចិញ្ចឹមមិនទាន់បានកំណត់ទិសដៅឲ្យជាក់លាក់នៅឡើយទេ ហើយក៏មិនមានផែនការយុទ្ធសាស្ត្រសម្រាប់តម្រង់ទិសដល់ការស្រាវជ្រាវ និងការអភិវឌ្ឍដែរ ទោះបីជាវិស័យនេះមានតួនាទីសំខាន់ក្នុងសន្តិសុខស្បៀង និងកម្លាំងអូសទាញសម្រាប់ផលិតកម្មកសិកម្មក៏ដោយ ។ គេចិញ្ចឹមគោក្របីសម្រាប់ប្រើជាកម្លាំងអូសទាញ និងអាហារ ។ គេចិញ្ចឹមជ្រូក មាន់ទា សម្រាប់លក់យកប្រាក់សន្សំទុក និងធ្វើជាអាហារ ។ ជ្រូក មាន់ទា ងាយស្រួលដោះដូរនៅក្នុង និងឆ្លងកាត់សហគមន៍នៅជនបទ ។ ការលក់ដូរ គោ ក្របីភាគច្រើន ជាលក្ខណៈក្រៅផ្លូវការជាមួយប្រទេសជិតខាង (Ear 2005; FAO 2004) ។ នាបច្ចុប្បន្ន ពុំមានការស្រាវជ្រាវថ្មីៗខាងគោលនយោបាយសម្រាប់វិស័យសត្វចិញ្ចឹមទេ ដូច្នេះគួរធ្វើការស្រាវជ្រាវជាបន្ទាន់ ដើម្បីជំរុញការអភិវឌ្ឍអនុវិស័យនេះ និងក៏គួរផ្តល់អាទិភាពខ្ពស់ដល់ការសិក្សាខាងសេដ្ឋកិច្ច-សង្គមកិច្ចលើការចិញ្ចឹមសត្វ ។

ការស្រាវជ្រាវគោលនយោបាយ មានធ្វើឡើងក្នុងពេលកន្លងមក ស្តីពី ការលើកកម្ពស់អនុវិស័យដំណាំស្រូវ និងការជម្រុញការនាំចេញអង្ករ ដោយសារវិស័យនេះ មានសក្តានុពលខ្ពស់សម្រាប់សន្តិសុខស្បៀង និងកំណើនសេដ្ឋកិច្ចនៅកម្ពុជា ។ ការជំរុញការកែច្នៃផលិតផលកសិកម្ម និងកសិ-ពាណិជ្ជកម្ម នឹងជួយពង្រឹងអនុវិស័យនេះសម្រាប់បម្រើការនាំចេញ ។ បច្ចុប្បន្នប្រទេសកម្ពុជា មានសមត្ថភាពកិនស្រូវទាប (តិចជាង ១០តោន/ម៉ោង) ហើយអាចកិនបានតែមួយភាគបីនៃផលស្រូវសរុបរបស់ខ្លួនប៉ុណ្ណោះ ។ ដូច្នេះ កម្ពុជាត្រូវបង្កើនសមត្ថភាព

កិនស្រូវមួយជាបី ដើម្បីបំពេញតម្រូវការកិនស្រូវក្នុងស្រុក ។ ដំណាំស្រូវ ក៏មានសក្តានុពលធំធេងសម្រាប់ការបង្កើនផលិតកម្ម និងផលិតភាព ប្រសិនបើមានការកែលំអបច្ចេកទេសដាំដុះ និងការវិនិយោគលើធាតុចូល ដូចជា គ្រាប់ពូជល្អ ជី និងការស្រោចស្រព ។ ប៉ុន្តែកំណើនផលិតភាពស្រូវទៅអនាគតមិនទៀងទាត់ទេ ព្រោះមានឧបសគ្គរាំងជាច្រើន ដូចជាការប្រើធាតុចូលតិច ដោយសារកង្វះឥណទាន ការស្រោចស្រពមិនគ្រប់គ្រាន់ កង្វះគ្រាប់ពូជល្អ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មអន់ខ្សោយ និងកង្វះផ្លូវថ្នល់តាមទីជនបទ ជាដើម (Tong & Puy 2010; Yu & Fan 2009) ។

## វិស័យសក្តានុពលសម្រាប់ការស្រាវជ្រាវទៅអនាគត

ប្រធានបទស្រាវជ្រាវសំខាន់ៗជាច្រើន ត្រូវបានកំណត់ឡើងសម្រាប់បង្កើតជាក្របខណ្ឌនៃចំណាប់អារម្មណ៍ និងការស្រាវជ្រាវទៅអនាគត ទោះបីជាក្របខណ្ឌនេះ អាចមិនទាន់គ្រប់គ្រាន់សម្រាប់ឆ្លើយតបទៅនឹងរាល់កង្វះខាតនៃចំណេះដឹងក្តី ។ ប្រធានបទទាំងនោះ រួមមាន៖

### ការគ្រប់គ្រងធនធានទឹក

១. តើទឹកក្រោមដីមានសក្តានុពលប៉ុណ្ណា សម្រាប់ការស្រោចស្រព ទាំងក្នុងទិដ្ឋភាពដ៏សំខាន់នៃតុល្យភាពទឹកនៅកម្ពុជា និងការស្តុកទឹកធម្មជាតិយ៉ាងច្រើនៗ ដែលអាចប្រើប្រាស់បានពេញៗមួយឆ្នាំ? តើការប្រើប្រាស់ទឹកក្រោមដីមានអត្ថប្រយោជន៍ និងគុណវិបត្តិអ្វីខ្លះ សម្រាប់ការអភិវឌ្ឍកសិកម្មនិងបរិស្ថាន? តើទឹកក្រោមដីផ្តល់ផលប៉ះពាល់យ៉ាងដូចម្តេចទៅលើគុណភាព និងជីជាតិដីក្នុងរយៈពេលវែង?

២. តើប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកលើដី ក្នុងគម្រោងស្រោចស្រពដែលមានស្រាប់ អាចកែលំអយ៉ាងណាបាន?

៣. តើមានវិធីណាអាចជួយពង្រឹងការចូលរួមរបស់អ្នកប្រើប្រាស់ទឹកលើដីអោយអនុវត្តភាពជាម្ចាស់ និងជួយថែទាំគម្រោងស្រោចស្រពឲ្យបានសក្តិសិទ្ធិ? តើការវិនិយោគក្នុងតំហែទាំគម្រោងស្រោចស្រព អាចហុចផលចំណេញខាងសេដ្ឋកិច្ចបានប៉ុណ្ណា?

៤. តើមានទំនាស់ប្រភេទអ្វីខ្លះ ដែលកើតមានឡើងទាក់ទិននឹងកង្វះទឹក និងការបែងចែកធនធានទឹក និង តើមានវិធីអ្វីខ្លះសម្រាប់ដោះស្រាយទំនាស់ទាំងនេះឲ្យបានសក្តិសិទ្ធិ?

### ការអភិវឌ្ឍវិស័យកសិកម្ម និងសន្តិសុខស្បៀង

១. តើការស្រាវជ្រាវខាងកសិកម្មអាចពង្រីកយ៉ាងណាបាន ដើម្បីជំរុញកំណើនវិស័យកសិកម្ម? តើធ្វើយ៉ាងណាឲ្យស្ថាប័នស្រាវជ្រាវ និងអ្នកប្រើប្រាស់បច្ចេកវិទ្យា មានទំនាក់ទំនងគ្នាប្រកបដោយប្រសិទ្ធភាពខ្ពស់? តើមានមធ្យោបាយអ្វីប្រសើរជាងគេ សម្រាប់ជំរុញ និងលើកទឹកចិត្តកសិករ ឲ្យអនុវត្តរបៀបរបបផលិតកម្មបែបថ្មី ដើម្បីបង្កើនផលិតភាព និងសន្តិសុខស្បៀង?

២. តើការប្រើប្រាស់ធាតុចូល និងបច្ចេកវិទ្យាសមស្របអ្វីខ្លះ ដែលអាចបង្កើនផលិតភាពកសិកម្ម ជួយឲ្យកសិករម្ចាស់ដីតូចៗ អាចផលិតស្បៀងអាហារបានគ្រប់គ្រាន់? តើកសិកម្មដែលយកស្រូវជាមូលដ្ឋាន និងមានសមត្ថភាពស្រោចស្រពតិចនេះ អាចធ្វើពិពិធកម្មយ៉ាងណាបាន ដើម្បីលើកកម្ពស់ជីវភាពនៅជនបទ និងកាត់បន្ថយភាពក្រីក្រ?

៣. តើធ្វើយ៉ាងណា អាចលើកកម្ពស់ការធ្វើផែនការប្រើប្រាស់ដីឲ្យបានប្រសើរ និងការកំណត់តំបន់សម្រាប់ដំណាំកសិកម្ម ដើម្បីជំរុញកំណើនវិស័យកសិកម្ម? តើធ្វើយ៉ាងណាអាចពង្រីកតំបន់ផលិតកម្មស្រូវ ដើម្បីជំរុញកំណើនវិស័យកសិកម្ម និងការនាំចេញ? តើត្រូវអនុវត្តយ៉ាងណា ដើម្បីកែប្រែដីទំនេរឲ្យទៅជាដីដាំដុះមានផលិតភាពវិញ?

៤. តើធ្វើយ៉ាងណា អាចជំរុញសម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារគ្មានដីធ្លី និងគ្រួសារស្ទើរគ្មានដីធ្លី? តើមានហានិភ័យ និងបញ្ហាប្រឈមអ្វីខ្លះ ចំពោះសន្តិសុខស្បៀងរបស់គ្រួសារគ្មានដីធ្លី? តើគោលនយោបាយអ្វីខ្លះ ដែលមានប្រសិទ្ធភាពល្អក្នុងការកាត់បន្ថយហានិភ័យ និងអសន្តិសុខស្បៀងរបស់ពួកគេ? តើមានហានិភ័យ និងបញ្ហាប្រឈមអ្វីខ្លះ សម្រាប់គ្រួសារនៅជនបទ ដែលកំពុងជួបប្រទះអសន្តិសុខស្បៀងធ្ងន់ធ្ងរ?

៥. ក្រោមការគំរាមកំហែងនៃបម្រែបម្រួលអាកាសធាតុ តើហានិភ័យចំពោះផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង អាចកាត់បន្ថយយ៉ាងដូចម្តេចបាន? តើការប្រើប្រាស់ទឹកក្រោមដីប្រកបដោយប្រសិទ្ធភាព អាចរៀបចំ និងជំរុញយ៉ាងណាបាន ដើម្បីកាត់បន្ថយការគំរាមកំហែងចំពោះដីកសិកម្ម?

### ការអភិវឌ្ឍអនុវិស័យជលផល

១. តើកម្រិតទឹកទន្លេទាប មានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះលើអេកូឡូស៊ីជលផល ជម្រកត្រី និងផលិតភាព ក្នុងវិស័យជលផលទឹកសាបនៅកម្ពុជា? តើបម្រែបម្រួលកម្រិតទឹកទន្លេអាចគ្រប់គ្រងយ៉ាងណាបាន ដើម្បីរក្សាចីរភាពអេកូឡូស៊ីជលផល ជម្រកត្រី និងផលិតភាព?

២. តើធ្វើយ៉ាងណា អាចជួយជំរុញ និងពង្រឹងការអភិវឌ្ឍសហគមន៍នេសាទ និងការកសាងសមត្ថភាព ដើម្បីឲ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងចីរភាពនូវធនធានជលផលធម្មជាតិ សំដៅបង្កើនប្រាក់ចំណូល សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ?

៣. តើធ្វើយ៉ាងណា អាចជួយជំរុញផលិតកម្មវារីវប្បកម្ម ដើម្បីកាត់បន្ថយការគំរាមកំហែងចំពោះជលផលទឹកសាបធម្មជាតិ? តើធ្វើយ៉ាងណា អាចជួយជំរុញវារីវប្បកម្មនៅតាមជនបទឆ្ងាយៗពីតំបន់នេសាទទឹកសាប ដើម្បីបង្កើនប្រាក់ចំណូល និងការទទួលបានប្រូតេអ៊ីនពីការបរិភោគសាច់សត្វ?

ការអភិវឌ្ឍអនុវិស័យសត្វចិញ្ចឹម

១. តើអនុវិស័យសត្វចិញ្ចឹមអាចជំរុញយ៉ាងណាបាន ដើម្បីបង្កើនប្រាក់ចំណូល និងសន្តិសុខស្បៀងនៅជនបទ? តើការចិញ្ចឹមសត្វមានទំនាក់ទំនងយ៉ាងដូចម្តេច ជាមួយផលិតកម្មកសិកម្មចំណូលគ្រួសារនៅជនបទ និងសន្តិសុខស្បៀង? តើការចិញ្ចឹមសត្វទ្រង់ទ្រាយតូច មានផលចំណេញខាងសេដ្ឋកិច្ចយ៉ាងដូចម្តេច? តើសហគមន៍ជនបទជួបប្រទះហានិភ័យ និងឧបសគ្គរារាំងចំបងៗអ្វីខ្លះក្នុងការចិញ្ចឹមសត្វ? តើធ្វើយ៉ាងណាអាចកាត់បន្ថយហានិភ័យ និងឧបសគ្គទាំងនេះបាន?

២. តើគេអាចអភិវឌ្ឍទីផ្សារសត្វចិញ្ចឹមសម្រាប់ផលិតករខ្នាតតូចយ៉ាងណាបាន? តើត្រូវមានបទបញ្ញត្តិច្បាប់អ្វីខ្លះ ដើម្បីលើកកម្ពស់ទីផ្សារសត្វចិញ្ចឹម?

៣. តើផលិតកម្មជ្រូកនៅមូលដ្ឋាន អាចកែលំអយ៉ាងណាបាន ដើម្បីអាចផ្គត់ផ្គង់តាមតម្រូវការទីផ្សារមូលដ្ឋាន? តើមានរបៀបរបបផលិតកម្មសមស្របអ្វីខ្លះ សម្រាប់បង្កើនការចិញ្ចឹមជ្រូក? តើអ្នកចិញ្ចឹមជ្រូកត្រូវប្រឈមមុខនឹងហានិភ័យ និងឧបសគ្គរារាំងអ្វីខ្លះ? តើមានបទបញ្ញត្តិច្បាប់ និងគោលនយោបាយអ្វីខ្លះដែលកំពុងអនុវត្ត ដើម្បីកាត់បន្ថយការនាំចូលជ្រូកឲ្យនៅតិចបំផុត និងជំរុញផលិតករនៅមូលដ្ឋាន?

## ឯកសារយោង


Ballard, B., C. Sloth, W. David, I. FitzGerald. K.A.S. Murshid, Hansen, Phim, R. & Lim, S. (2007), *We are Living with Worry All the Time: A Participatory Poverty Assessment of the Tonle Sap*

Ballard, B. & Thun, V. (2007), *Livestock Production and Veterinary Services in Cambodia*, ADR 2006/07

CDRI (2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*, WP 48

Chadwick M. Juntopas M. & Sithirith M. (2008), *Sustainable Tonle Sap: An assessment of Development Challenges Facing the Great Lake*, The Sustainable Mekong Research Network

Sophal Ear, S. (2005), *The Political Economy of Pro-poor Livestock Policy in Cambodia*, PPLPI WP No. 26 FAO Pro-Poor Livestock Policy Initiative

FAO (2004), *Review of the Livestock Sector in the Mekong Countries Livestock Sector Report: Cambodia-Lao-Thailand-Vietnam*

Fitzgerald, I. & So, S. (2007), *Moving Out of Poverty Study? Trends in Community Well-Being and Household Mobility in Nine Cambodian Villages*

Guimbert, S. (2010), *Cambodia 1998-2008: An Episode of Rapid Growth, World Bank Policy Research* Working Paper 5271

Hap N. & Madhusudan B. (2009), *Economics and Livelihoods of Small-scale Inland Fisheries in the Lower Mekong Basin: A Survey of Three Communities in Cambodia*.Water Policy 11 Supplement 1, 31-5

Hing, V. & Nou, K. (2006), *Early Harvest Programme: Implication for Cambodian Agriculture*, CDRI, Phnom Penh

Hing, V. & Thun, V. (2009), *Agricultural Trade in the Greater Mekong Sub-Region: The Case of Cassava and Rubber in Cambodia*, CDRI WP 43

IMF (2004 &2009), *Cambodia: Statistical Appendix*, IMF Country Report No. 04/330&No. 09/48

MAFF (2005), *Agricultural Sector Strategic Development Plan 2006-2010*

MAFF & MoWRAM (2007), *Strategy for Agriculture and Water 2006-2010*

NIS (2008), *National Institute of Statistics-National Accounts (NIS-NA) 2008*

RGC (2004), *Rectangular Strategy for Growth, Employment, Equity and Efficiency*

RGC (2005), *National Strategy Development Plan 2006-2010*

RGC (2010), Policy Document on *Promotion of Paddy Rice Production and Export of Milled Rice*

Ros, B (2010), *Farmer Participation and the Success of Farmer-managed Irrigation Systems: A Case Study of the O-treng Farmer Water User Community, Kampong Speu Province*, CDRI Annual Development Review 2009/2010

Sovannarith S., D.R. Blake, Kosal M. & Sour K. (forthcoming), *Conflict and Collective Action in Tonle Sap Fisheries: Adapting Institutions to Support Community Livelihoods*, CDRI WP 49

So S., Tong, K. & Theng, V. (2010), *Poverty Dynamics Study*, CDRI report for the World Bank on Longitudinal Poverty Study in Cambodia

Tong K. & Puy P. (2010), "Promoting Export of Cambodia's White Gold", *Cambodia Development Review*, Vol. 14, Issue 2, CDRI, Phnom Penh

Viner K., M. Ahmed, T. Bjorndal & K. Lorenzen (2006), *Development of Fisheries Co-management in Cambodia: A case Study and its Implications*, WorldFish Centre, Discussion Series No. 2

World Bank (2009), *Sustaining Rapid Growth in a Challenging Environment*

World Bank (2010), *Emerging Stronger from the Crisis*

Yu B. & Fan S. (2009), *Rice Production Responses in Cambodia*, IFPRI Discussion Paper 00939

# យុទ្ធសាស្ត្រវិស័យកសិកម្មនៅកម្ពុជា៖ ជម្រើសអភិវឌ្ឍន៍នៅពេលអនាគតសម្រាប់ផលិតកម្មស្រូវ[១]

## សេចក្ដីផ្ដើម

ឯកសារនេះ ផ្ដោតសំខាន់ទៅលើតួនាទីនៃផលិតកម្មស្រូវក្នុងយុទ្ធសាស្ត្រកសិកម្មនៅកម្ពុជា ។ ដំបូង ឯកសារនេះពិនិត្យពីលទ្ធផលផលិតកម្មស្រូវនៅកម្ពុជា ព្រមទាំងអន្តរាគមន៍ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលជាប់ទាក់ទងនឹងដំណាំស្រូវ ហើយបន្ទាប់មក កំណត់ពីសក្ដានុពល និងឧបសគ្គសម្រាប់ការអភិវឌ្ឍវិស័យនេះនៅពេលអនាគត ។ ដោយគិតគូរដល់យុទ្ធសាស្ត្រកសិកម្មដ៏ធំទូលាយផង ឯកសារនេះនឹងស្រាវជ្រាវថែមទៀតពីជម្រើសនានា និងមាគ៌ាអភិវឌ្ឍន៍ដំណាំស្រូវទៅអនាគត ដោយប្រៀបធៀបស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ទៅនឹងដំណាក់កាលអភិវឌ្ឍន៍ដំបូងនៅប្រទេសជិតខាងទាំងពីររបស់កម្ពុជា គឺ ថៃ និងវៀតណាម ។ ទោះបី ថៃ និងវៀតណាម សុទ្ធតែជាប្រទេសផលិតស្រូវ និងនាំចេញអង្ករក្ដី ប៉ុន្ដែគេមានយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យស្រូវ ខុសគ្នាគួរឲ្យកត់សម្គាល់ ។ ឯកសារនេះក៏មានផ្ដល់មតិពីប្រធានបទមួយចំនួន ឧត្តមភាពប្រៀបធៀបរបស់កម្ពុជាសម្រាប់ធ្វើការស្រាវជ្រាវជាបន្ត ព្រមទាំងស្នើឡើងនូវការសិក្សាប្រៀបធៀបពីមាគ៌ាអភិវឌ្ឍន៍ និងពិពិធកម្ម ក្នុងវិស័យកសិកម្ម ដើម្បីមានជម្រើសកាន់តែច្រើនសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មកម្ពុជានៅពេលអនាគត ។

កម្ពុជា បានឆ្លងកាត់ការផ្លាស់ប្ដូរសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ ដោយមានកំណើនមធ្យមនៃ ផសស (GDP) យ៉ាងលឿនដល់ទៅ ៩,៨% នៅចន្លោះឆ្នាំ២០០០-២០០៨ គឺខ្ពស់ជាងប្រទេសជាច្រើននៅក្នុងតំបន់ (World Bank 2009) ។ នៅអំឡុងពេលជាមួយគ្នានោះ វិស័យកសិកម្មក៏មានលទ្ធផលយ៉ាងល្អ ដោយកើនឡើងជាមធ្យម ៥,៦% ក្នុងមួយឆ្នាំ ។ សេដ្ឋកិច្ចកម្ពុជានៅតែពឹងផ្អែកយ៉ាងខ្លាំងលើវិស័យកសិកម្ម ដែលបានរួមចំណែកប្រមាណមួយភាគបីនៃ ផសស ជាតិ និងប្រើប្រាស់ដល់ជាង ៥០% នៃកម្លាំងពលកម្មសរុប (World Bank 2009) ។

## លទ្ធផល និងគោលនយោបាយជម្រុញផលិតកម្មស្រូវ

ស្រូវជាដំណាំដ៏សំខាន់នៅកម្ពុជា ដោយគ្របដណ្ដប់លើផ្ទៃដីដាំដុះអស់ប្រមាណ ៨០% និងជាទំនិញកសិកម្មនាំចេញសំខាន់បំផុត ។ ស្រូវអង្ករ ជាប្រភពចំបងនៃតម្លៃបន្ថែមលើផលដំណាំ និងជាកត្តាចំបងជំរុញកំណើនវិស័យកសិកម្ម ។ វាជាអាហារមូលដ្ឋានក្នុងរបបអាហារជាប្រពៃណី ដោយផ្ដល់ជាមធ្យមប្រមាណជាង ៣ភាគ៤ នៃថាមពលស្រូបចូលប្រចាំថ្ងៃរបស់ប្រជាជនធម្មតានៅកម្ពុជា ។ ដូច្នេះស្រូវមានតួនាទីដ៏សំខាន់ ហើយបន្ដើរតួនាទីជាយុទ្ធសាស្ត្រក្នុងកំណើនប្រាក់ចំណូល ការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀង នៅកម្រិតគ្រួសារ និងនៅថ្នាក់ជាតិ ។

ដោយទទួលស្គាល់ពីតួនាទីសំខាន់នៃដំណាំស្រូវ រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់អាទិភាពខ្ពស់ ដោយដាក់បញ្ចូលវិស័យនេះក្នុងគ្រប់ឯកសារយុទ្ធសាស្ត្រ និងផែនការរបស់រដ្ឋាភិបាល ដែលមានចែងពីវិស័យកសិកម្ម ។ ការកែលំអទិន្នផលតាមរយៈការធ្វើប្រពលវប្បកម្ម (ដូចជា ការប្រើប្រាស់ជី និងធារាសាស្ត្រ) ជាអាទិភាពទីមួយដើម្បីជំរុញកំណើនវិស័យកសិកម្ម (គឺសំខាន់ជាង ការពង្រីកផ្ទៃដីដាំដុះ) ។ យោងតាមកម្មវិធីគាំទ្រវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្មកម្ពុជា (CAASP) ផលិតកម្មស្រូវត្រូវឡើងដល់ ៦លានតោននៅឆ្នាំ២០១០ និងរំពឹងឡើងដល់ ៧,៥លានតោននៅឆ្នាំ២០២០ (MAFF & MOWRAM 2008) ។ កំណើននេះត្រូវជំរុញឡើងដោយកំណើនទិន្នផលពី ២,៥តោន/ហិកតានៅឆ្នាំ២០០៧ ដល់ ៣,០តោន/ហិកតា នៅឆ្នាំ២០២០ ។ ក្នុងពេលជាមួយគ្នា គេព្យាករណ៍ថា ផ្ទៃដីប្រមូលផលនឹងធ្លាក់ចុះបន្តិច ប៉ុន្ដែទំហំផ្ទៃដីស្រោចស្រពនឹងកើនឡើង ២០% ។

ដោយមានការគាំទ្រយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល ផលិតកម្មស្រូវបានកើនឡើងគួរឱ្យកត់សម្គាល់តាំងពីឆ្នាំ២០០៣ មក ។ ស្រូវវស្សាគ្មានប្រព័ន្ធស្រោចស្រព រួមចំណែកបានប្រមាណ ៧៥% នៃផលិតកម្មស្រូវសរុប ហើយការរីកចម្រើនផ្នែកស្រូវវស្សា គឺជាកត្តាចំបងក្នុងកំណើនជាងមួយជាពីរនៃទិន្នផលស្រូវ នៅអំឡុងឆ្នាំ១៩៩៤-២០០៨ ។ កំណើនផលិតកម្មស្រូវយ៉ាងលឿននេះ បានប្រែក្លាយកម្ពុជា ពីប្រទេសនាំចូលអង្ករសុទ្ធ ទៅជាប្រទេសនាំចេញអង្ករវិញ ។ កម្ពុជាបាននាំចេញអង្ករ ១,៥លានតោន ក្នុងឆ្នាំ២០០៧ ដែលរួមចំណែកបាន ១០% នៃតម្លៃនាំចេញសរុបរបស់កម្ពុជា ។ ទោះបីផលិតកម្ម និងការនាំចេញស្រូវអង្ករបានកើនឡើងគួរឱ្យស្ញើចសរសើរក្ដី ប៉ុន្ដែមានផលិតកម្មស្រូវ

---

១ អត្ថបទនេះរៀបចំឡើងដោយ បណ្ឌិត Bingxin Yu ជាអ្នកស្រាវជ្រាវ និង បណ្ឌិត Xinshen Diao ជាអ្នកស្រាវជ្រាវជាន់ខ្ពស់ នៅវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) ។ អត្ថបទនេះ ផ្អែកលើឯកសារពិភាក្សាគោលនយោបាយ រៀបចំសម្រាប់កិច្ចប្រជុំបូកសរុប ស្ដីពីគោលនយោបាយកសិកម្ម និងសន្តិសុខស្បៀង នៅកម្ពុជា ដែលធ្វើឡើងកាលពីថ្ងៃទី ៤ វិច្ឆិកា ២០១០ ។

តែមួយចំណែកតូចទេ ដែលចូលទៅដល់ទីផ្សារបរទេស ដូច្នេះ នៅទាបជាខ្លាំង បើធៀបនឹងកម្រិតនាំចេញរបស់វៀតណាម និង ថៃ ។

## សក្ដានុពលកំណើនស្រូវនាថ្ងៃខាងមុខ និងឧបសគ្គនានា

កម្ពុជា មានសក្ដានុពលធំណាស់ដើម្បីបង្កើនផលិតកម្មស្រូវ ។ គេទទួលស្គាល់ជាទូទៅថា កម្ពុជាសំបូរដីកសិកម្ម និង ធនធានទឹក ដែលមិនទាន់បានប្រើប្រាស់ពេញលេញ ពីព្រោះ មានផ្ទៃដីអាចដាំដុះបាន មិនដល់ ៣0% ទេ ដែលគេកំពុងប្រើ សម្រាប់ការដាំដុះ ហើយផ្ទៃដីអាចស្រោចស្រពបាន មានចំនួន ភាគរយកាន់តែតិចជាងនេះទៀត ដែលទទួលការស្រោចស្រព ជាក់ស្ដែង (Pech & Sunada, 2008) ។ ដូច្នេះ ការអភិវឌ្ឍ ធារាសាស្ត្រ និងការពង្រីកផ្ទៃដីដាំដុះ អាចជាមធ្យោបាយសាមញ្ញ ជាងគេសម្រាប់បង្កើនផលិតកម្មស្រូវ ។ ផលិតភាព គឺជាប្រភព មួយទៀតនៃសក្ដានុពលក្នុងការអភិវឌ្ឍផលិតកម្មស្រូវ ពីព្រោះ ទិន្នផលស្រូវជាមធ្យមនៅកម្ពុជា នៅទាបជាងទិន្នផលនៅ ថៃ និង វៀតណាម ។ ទិន្នផលស្រូវអាចបង្កើនច្រើនទៀតបាន តាមរយៈ ការប្រើប្រាស់បច្ចេកទេសប្រពលវប្បកម្មដំណាំ រាប់បញ្ចូលទាំង ការបង្កើនជីប្រើប្រាស់ និងការកែលំអរបៀបរបបដាំដុះផង ។

ផលិតកម្មស្រូវកម្ពុជាមានសក្ដានុពលខ្លាំងក៏ពិតមែន ប៉ុន្តែ កម្ពុជាត្រូវជំនះលើឧបសគ្គជាច្រើនដើម្បីសម្រេចវាបាន ។ តាម ឯកសារមានស្រាប់ គេចាត់ទុកថា ការប្រើប្រាស់ជីមិនគ្រប់គ្រាន់ និងប្រព័ន្ធស្រោចស្រពអន់ខ្សោយ គឺជាឧបសគ្គរាំងស្ទះតឹងតែង ជាងគេ ។ កសិករភាគច្រើននៅកម្ពុជា តែងប្រើជីក្នុងការធ្វើ ស្រែជាទូទៅ ហើយអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៤ និង ២០០៧ បង្ហាញថា មានការប្រើជីគីមីលើ ៧៧-៧៨% នៃស្រូវវស្សា និង ៨៧-៩៤% នៃស្រូវប្រាំង (តារាង ១) ។ បរិមាណជីប្រើប្រាស់នេះ នៅតិច និងទាបជាង កម្រិតណែនាំសម្រាប់ទូទាំងប្រទេស (Blair & Blair 2010) ។ ដោយផ្អែកលើទិន្នន័យបានពី CSES គួបផ្សំនឹងថ្លៃជាមធ្យម ប៉ាន់ស្មានដែលកសិករបង់លើជី គេគណនាឃើញថានៅឆ្នាំ២០០៤ ការប្រើប្រាស់ជីមានប្រហែល ៧២គ.ក. ក្នុងមួយហិកតា សម្រាប់ ស្រូវវស្សា និង ១០៥គ.ក. ក្នុងមួយហិកតា សម្រាប់ស្រូវប្រាំង ។ កង្វះប្រព័ន្ធស្រោចស្រព ជាឧបសគ្គចំបងមួយទៀតចំពោះការ អភិវឌ្ឍដំណាំស្រូវ ដែលនាំឲ្យវិស័យនេះ ត្រូវពឹងផ្អែកលើ អាកាសធាតុ ។ នៅឆ្នាំ២០០៤ ប្រហែល ១១,៥% នៃផ្ទៃដីស្រែ វស្សា និង ៥០% នៃផ្ទៃដីស្រែប្រាំង ទទួលបានការស្រោចស្រព គ្រប់គ្រាន់ (តារាង ១) ។ នៅឆ្នាំ២០០៧ បរិមាណជីប្រើប្រាស់ និងចំនួនភាគរយផ្ទៃដីស្រែបានស្រោចស្រព មានការថយចុះ ដោយសារអាកាសធាតុអំណោយផល ហើយធាតុចូលឡើងថ្លៃ ខ្ពស់ ។

## ដំណាំស្រូវក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មធំទូលាយ

ដោយសារស្រូវនឹងបន្តដើរតួនាទីសំខាន់ ក្នុងកំណើនកសិកម្មទៅ អនាគតនៅកម្ពុជា ដូច្នេះគេត្រូវដាក់បញ្ចូលផលិតកម្មស្រូវទៅក្នុង បរិបទនៃការអភិវឌ្ឍធំទូលាយ ដើម្បីកំណត់ពីជម្រើសដ៏ប្រសើរ សម្រាប់ការអភិវឌ្ឍថែមទៀត ។ ដំណាំស្រូវមានតួនាទីសំខាន់ ស្រដៀងគ្នាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅថៃ នៅដើមទសវត្សរ៍

តារាង ១៖ ការប្រើប្រាស់ជីនៅកម្ពុជា

| | ស្រូវវស្សា | | ស្រូវប្រាំង | |
|---|---|---|---|---|
| | 2004 | 2007 | 2004 | 2007 |
| ចំណែកនៃក្បាលដី (%) | 86.8 | 84.1 | 14.3 | 15.9 |
| ចំណែកនៃផ្ទៃដីដាំដុះសរុប (%) | 60.9 | 79.2 | 10.8 | 20.7 |
| ក្បាលដីសម្រាប់ដំណាំស្រូវ | | | | |
| ចំណែកនៃក្បាលដីមានប្រើជី (%) | 77.5 | 76.8 | 81.5 | 86.9 |
| ចំណែកនៃផ្ទៃដីមានប្រើជី (%) | 76.9 | 78.5 | 87.2 | 93.5 |
| ចំណាយជាមធ្យមលើជី (រៀល/ហិកតា) | 101,426 | 84,871 | 148,265 | 222,666 |
| ទំហំក្បាលដីជាមធ្យម | 0.9 | 0.9 | 1.0 | 1.3 |
| ថ្លៃជីអ៊ុយរេអន្តរជាតិ (ដុល្លារ/តោន)* | 200 | 415 | 200 | 415 |
| ថ្លៃជីអ៊ុយរេលក់ឲ្យកសិករ (ដុល្លារ/តោន)** | 350 | 600 | 350 | 600 |
| អត្រាប្ដូរប្រាក់ជាមធ្យម (រៀល ក្នុង ១ដុល្លារ)*** | 4021 | 4032 | 4021 | 4032 |
| ការប្រើប្រាស់ជីតាមការគណនា (គ.ក./ហិកតា) | 72.1 | 35.1 | 105.4 | 92.0 |
| ចំណែកក្បាលដីមានការស្រោចស្រព (%) | 14.9 | 9.4 | 40.9 | 38.4 |
| ចំណែកផ្ទៃដីមានការស្រោចស្រព (%) | 11.5 | 8.1 | 50.1 | 36.0 |

*កំណត់សម្គាល់៖ បរិមាណជីប្រើប្រាស់ គ្មានរាយការណ៍ក្នុងអង្កេតទេ ។ * IFDC (2008); ** CDRI (2008) ជីអ៊ុយរេ ថ្លៃ 350-510ដុល្លារ/តោន ហើយជីឌីអាម៉ូញ៉ូមផូស្វាត (DAP) ថ្លៃ 450-1080ដុល្លារ/តោន នៅលើទីផ្សារតាមខេត្ត ក្នុងឆ្នាំ2007; *** IMF (2009)*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ លើទិន្នន័យពី CSES 2004 និង 2007 (វិទ្យាស្ថានជាតិស្ថិតិ)*

ក្រាហ្វិក ១៖ ផសស ក្នុងមនុស្សម្នាក់ គិតតាមថ្លៃប្រាក់ដុល្លារថេរឆ្នាំ២០០០




*កំណត់សម្គាល់៖ តម្លៃនៃខ្សែដេក x គឺ៖ 1 សម្រាប់ឆ្នាំ1997 និង 13 សម្រាប់ឆ្នាំ2009 នៅកម្ពុជា ហើយ 1 សម្រាប់ឆ្នាំ1991 និង 18 សម្រាប់ឆ្នាំ2008 នៅវៀតណាម ហើយនិង ៦ តាងឲ្យឆ្នាំ1960 និង ១៨ តាងឲ្យឆ្នាំ1972 នៅថៃ ។*
*ប្រភព៖ ធនាគារពិភពលោក (2009) ។*

១៩៦០ និង ១៩៧០ នៅវៀតណាម នៅទសវត្សរ៍ ១៩៩០ និងនៅកម្ពុជានាពេលសព្វថ្ងៃ ។ ការប្រៀបធៀបស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ទៅនឹងដំណាក់កាលអភិវឌ្ឍន៍ស្រដៀងគ្នានៅ ថៃ និងវៀតណាម នឹងជួយបង្ហាញពីជម្រើសល្អៗជាក់ស្តែង សម្រាប់ផលិតកម្មស្រូវនៅកម្ពុជា ។

យើងជ្រើសយកឆ្នាំ១៩៩៧ ជាឆ្នាំដំបូងសម្រាប់ធ្វើការសិក្សាពីកម្ពុជា ដែលពេលនោះមានកម្រិតចំណូលក្នុងមនុស្សម្នាក់ ២៣៩ដុល្លារ (គិតតាមថ្លៃ០ប្រាក់ដុល្លារថេរក្នុងឆ្នាំ២០០០) ។ វៀតណាម សម្រេចបានកម្រិតចំណូលក្នុងមនុស្សម្នាក់ស្រដៀងគ្នានេះក្នុងឆ្នាំ១៩៩១ ។ ចំណូលក្នុងមនុស្សម្នាក់នៅថៃ ឡើងដល់ ៣១៧ដុល្លារ ក្នុងឆ្នាំ១៩៦០ ហើយកម្ពុជាឡើងដល់កម្រិតនេះដែរនៅឆ្នាំ២០០២ ។ ក្រាហ្វិក ១ បង្ហាញពីការប្រៀបធៀប ផសស ក្នុងមនុស្សម្នាក់ សម្រាប់ ៣ ប្រទេសខាងលើ ។ ដើម្បីសម្រួលការប្រៀបធៀបនៅក្នុងក្រាហ្វិក ឆ្នាំទី១ តាងឲ្យឆ្នាំ១៩៩៧ សម្រាប់កម្ពុជា និង ១៩៩១ សម្រាប់វៀតណាម រីឯក្រាហ្វិកសម្រាប់ប្រទេសថៃ ចាប់ផ្តើមនៅឆ្នាំទី៦ ដែលតាងឲ្យឆ្នាំ២០០២ សម្រាប់កម្ពុជា និង ១៩៦០ សម្រាប់ថៃ ។ កំណើននាពេលថ្មីៗនៅកម្ពុជាគិតតាមចំណូលក្នុងមនុស្សម្នាក់ បានកើនឡើងលឿនជាងនៅថៃ និងវៀតណាម កាលពីពេលដែលប្រទេសទាំងពីរចាប់មានកម្រិតប្រាក់ចំណូលស្រដៀងគ្នានេះដែរ ។ តួយ៉ាង កម្ពុជាសម្រេចបានកម្រិតចំណូលក្នុងមនុស្សម្នាក់ ៣៧០ដុល្លារ នៅឆ្នាំ២០០៤ (ក្នុងរយៈពេល ៧ឆ្នាំ) និង ៥១១ដុល្លារ នៅឆ្នាំ២០០៩ (ក្នុងរយៈពេល ១១ឆ្នាំ) ។ វៀតណាមត្រូវប្រើពេល ៧ឆ្នាំ ដើម្បីបង្កើនចំណូលក្នុងមនុស្សម្នាក់ ពី ២៣៥ដុល្លារ ក្នុងឆ្នាំ១៩៩១ ដល់ ៣៦៥ដុល្លារ ក្នុងឆ្នាំ១៩៩៨ ហើយត្រូវប្រើពេល ១៣ឆ្នាំ ដើម្បីសម្រេចបានចំណូលក្នុងមនុស្សម្នាក់ លើសពី ៥០០ដុល្លារ ។ ការធ្លាក់ចុះសេដ្ឋកិច្ចសាកលនាពេលថ្មីៗ បានពន្យឺតកំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០០៩ ប៉ុន្តែកំណើននេះរំពឹងថានឹងរើបឡើងវិញនៅឆ្នាំ២០១០ និង ២០១១ (ADB 2010) ហើយគម្លាតនៃ ផសស ក្នុងមនុស្សម្នាក់ រវាង កម្ពុជា និងវៀតណាម ទំនងជានឹងរួមចុះនៅទសវត្សរ៍បន្ទាប់ ។ ពិតមែនតែការរើបសេដ្ឋកិច្ចនៅកម្ពុជា អាចថាមិនសូវពឹងផ្អែកខ្លាំងលើស្រូវអង្ករ (ដែលរងការប៉ះពាល់ពីវិបត្តិសាកល តិចជាងវិស័យកាត់ដេរ និងទេសចរណ៍) ប៉ុន្តែវិស័យកសិកម្ម ជាពិសេស ដំណាំស្រូវ នៅតែសំខាន់សម្រាប់កំណើនទៅអនាគតនៅកម្ពុជា ដោយសារមូលហេតុជាច្រើន ។ ការពិនិត្យពីចំណែកនៃវិស័យកសិកម្ម បង្ហាញថា មាគ៌ានៃបំលាស់ប្តូរស៊ីជំរៅនៅកម្ពុជា វាស្រដៀងគ្នានឹង ថៃ ជាង វៀតណាម ។

ការប្រៀបធៀបទិន្នផលស្រូវបច្ចុប្បន្ននៅកម្ពុជា ថៃ និងវៀតណាម បង្ហាញថា ដំណាំស្រូវកម្ពុជាផ្តល់ទិន្នផលបានតែពាក់កណ្តាលនៃទិន្នផលវៀតណាម ប៉ុន្តែគម្លាតរវាងកម្ពុជា និងថៃ មានទំហំតូចត្រឹម ១០% ប៉ុណ្ណោះ ។ គេតែងលើកពីប្រទេសវៀតណាមជារឿយៗ ដើម្បីរែកញែកពីសក្តានុពលទិន្នផលនៅកម្ពុជា ប៉ុន្តែប្រទេសទាំងពីរមានភាពខុសគ្នាគួរឱ្យកត់សម្គាល់ក្នុងលក្ខខណ្ឌពីដំបូង ដូច្នេះទិន្នផលស្រូវនៅកម្ពុជាដើរស្របច្រើនជាងតាមលំនាំទិន្នផលនៅថៃ (ក្រាហ្វិក ២) ។

កម្ពុជា គួរយកចិត្តទុកដាក់កាន់តែច្រើនលើបទពិសោធន៍ប្រទេសថៃ ក្នុងការបង្កើតយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំស្រូវ ព្រោះទីមួយ កម្ពុជា និង ថៃ មានលក្ខខណ្ឌធនធានធម្មជាតិស្រដៀងគ្នាដោយសារប្រទេសទាំងពីរមានដីសំបូរ បើគិតតាមស្តង់ដាក្នុងតំបន់ ។ ទីពីរ លទ្ធភាពស្រោចស្រព និងអត្រាប្រើប្រាស់ជី មាន

ក្រាហ្វិក ២៖ និន្នាការទិន្នផលស្រូវក្នុង ៣ ប្រទេស (គិតជា តោន/ហិកតា)




*កំណត់សម្គាល់៖ តម្លៃនៃខ្សែដេក x គឺ៖ 1 សម្រាប់ឆ្នាំ1997 និង 13 សម្រាប់ឆ្នាំ2009 នៅកម្ពុជា ហើយ 1 សម្រាប់ឆ្នាំ1991 និង 18 សម្រាប់ឆ្នាំ2008 នៅវៀតណាម ហើយនិង 7 តាងឲ្យឆ្នាំ1961 និង ១៨ តាងឲ្យឆ្នាំ1972 នៅថៃ ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យបានពី FAO (2010) ។*

កម្រិតទាបនៅថៃ បើធៀបនឹងនៅវៀតណាម ។ ភាពប្រកួតប្រជែងរបស់ថៃលើទីផ្សារអន្តរពិភពលោក មិនជាប់ទាក់ទងខ្លាំងនឹងការកែលំអទិន្នផលទេ ពីព្រោះកំណើនផលិតកម្មថៃផុសចេញពីការពង្រីកផ្ទៃដីផង និងការកែលំអទិន្នផលផង ។ ទីបី លក្ខណៈប្លែកដាច់គេមួយនៃផលិតកម្មស្រូវនៅថៃគឺ ពិពិធកម្មនៃវិស័យនេះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការខុសៗគ្នានៅទីផ្សារបរទេស ។ អង្ករគុណភាពខ្ពស់របស់ថៃ ច្រើនតម្រង់ទិសទៅកាន់ទីផ្សារប្រទេសអភិវឌ្ឍន៍ ឬអ្នកប្រើប្រាស់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលខ្ពស់ រីឯអង្ករថ្លៃទាប បានជួយឲ្យថៃ ជ្រៀតចូលដល់ទីផ្សារអង្ករនៅប្រទេសអាហ្វ្រិកជាច្រើន ។ ប្រភេទស្រូវដែលកម្ពុជាដាំដុះសម្រាប់នាំចេញ ទទួលបានថ្លៃខ្ពស់ដោយសារមានគុណភាព និងរសជាតិល្អ គាប់ចិត្តអ្នកប្រើប្រាស់ក្នុងទីផ្សារកម្រិត

តារាង ២៖ លទ្ធផលពិសោធន៍ពីកំណើនផលស្រូវដោយការពង្រីកផ្ទៃដីដាំដុះ និងការបង្កើនធាតុចូលប្រើប្រាស់

| រដូវ | ផ្ទៃដីបច្ចុប្បន្ន ឬ ការប្រើធាតុចូល | ផលស្រូវបច្ចុប្បន្ន (ពាន់តោន) | ការពង្រីកផ្ទៃដីដាំដុះ ឬ បង្កើនធាតុចូល (% នៃកម្រិតបច្ចុប្បន្ន) | ការបង្កើនផ្ទៃដី និងការប្រើធាតុចូល សាកល្បង (Simulation) | ភាពលុត (Elasticity) នៃផលស្រូវ ដោយកត្តា ដី/ធាតុចូល | កំណើនផលស្រូវ (តោន) |
|---|---|---|---|---|---|---|
| | (1) | (2) | (3) | (4) | (5) | (6) |
| ផ្ទៃដីដាំស្រូវ[១] | | | | | | |
| ស្រូវវស្សា | 2,110.0 | 2,828 | 10 | 211.0 | 0.683 | 193,180 |
| ស្រូវប្រាំង | 373.0 | 827 | 10 | 37.0 | 0.625 | 51,678 |
| ការប្រើជី[២] | | | | | | |
| ស្រូវវស្សា | 72.1 | 2,828 | 50 | 108.2 | 0.100 | 141,420 |
| ស្រូវប្រាំង | 105.4 | 827 | 10 | 115.9 | 0.203 | 16,785 |
| ការស្រោចស្រព[៣] | | | | | | |
| ស្រូវវស្សា | 11.5 | 2,828 | 100 | 23.0 | 0.152 | 49,441 |
| ស្រូវប្រាំង | 50.1 | 827 | 10 | 55.1 | 0.213 | 8,823 |

*កំណត់សម្គាល់៖ 1 ផ្ទៃដីដាំស្រូវក្នុងជួរឈរលេខ (1) និង (4) គិតជាពាន់ហិកតា*

*2 ការប្រើជី ក្នុងជួរឈរលេខ (1) និង (4) គិតជា គ.ក./ហិកតា*

*3 ការស្រោចស្រព ក្នុងជួរឈរលេខ (1) និង (4) គិតជាភាគរយនៃផ្ទៃដីដាំដុះសរុប ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ លើទិន្នន័យបានពី CSES 2004, Yu and Fan (2010) and FAO (2010)*

ខ្ពស់ ។ បទពិសោធន៍នៅថៃ បានផ្ដល់គំនិតថា ជាជាងខំជំរុញផលិតភាពដែលងាយវាស់វែងតាមរយៈទិន្នផលនោះ យុទ្ធសាស្ត្រដំណាំស្រូវរបស់កម្ពុជា គួរប្រឹងប្រែងបង្កើនភាពប្រកួតប្រជែងតាមការស្វែងរកឱកាសនាំចេញ ដូចជា ការតម្រង់រកទីផ្សារសម្រាប់ប្រភេទស្រូវជាក់លាក់ និងការដាំដុះប្រភេទស្រូវខុសៗគ្នា សម្រាប់អ្នកប្រើប្រាស់ប្រភេទខុសៗគ្នានៅក្រៅប្រទេស ។

លទ្ធផលនៃការពិសោធមួយ ដែលផ្អែកលើការប៉ាន់ស្មានពីការឆ្លើយតបនៃផ្នែកផ្គត់ផ្គង់ ទៅនឹង កំណើនការប្រើប្រាស់ធាតុចូល និងការពង្រីកផ្ទៃដីដាំដុះ ក៏បានបញ្ជាក់ច្បាស់ពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជាដែរ ដោយបង្ហាញថា តាមស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ការពង្រីកផ្ទៃដីដាំដុះអាចបង្កើនផលស្រូវបានច្រើនជាងកំណើនការប្រើប្រាស់ធាតុចូលទំនើប។លទ្ធផលបង្ហាញទៀតថា ឧត្តមភាពប្រៀបធៀបនៃផលិតកម្មស្រូវនៅកម្ពុជាពឹងផ្អែកលើធនធានដីដ៏សំបូរ ដូច្នេះគោលនយោបាយផ្ដោតលើទិន្នផលស្រូវតែម្យ៉ាង អាចមិនមែនជាមធ្យោបាយដ៏សក្ដិសិទ្ធិបំផុត ជួយឱ្យដំណាំស្រូវហុចផលចំណេញកាន់តែច្រើនដល់កសិករនោះឡើយ ។

## ការស្រាវជ្រាវទៅអនាគតសម្រាប់យុទ្ធសាស្ត្រកសិកម្ម

ដោយសារកម្ពុជា មានស្បៀងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯងនៅកម្រិតទូទាំងប្រទេស តាំងពីចុងទសវត្សរ៍ ១៩៩០ ដូច្នេះការបន្តផ្ដោតលើការបង្កើនផលិតកម្មស្រូវ អាចបង្កការផ្គត់ផ្គង់ស្រូវលើស និងការបាត់បង់ឱកាសចូលទីផ្សារស្រូវអង្ករមានតម្លៃខ្ពស់ និងដំណាំមានតម្លៃខ្ពស់ផ្សេងៗទៀត ។ គួរមានការស្រាវជ្រាវច្រើនទៀត ផ្ដោតលើបញ្ហាថា តើកម្ពុជាអាចទាញយកផលចំណេញយ៉ាងដូចម្ដេច ពីឧត្តមភាពប្រៀបធៀបរបស់ខ្លួនតាមការនាំចេញអង្ករមានគុណភាព និងតម្លៃបន្ថែមខ្ពស់ ។ សំខាន់គេត្រូវពិនិត្យទៅលើការដោះដូរគ្នា (trade-offs) រវាងគោលដៅអភិវឌ្ឍន៍ខុសៗគ្នានៃដំណាំស្រូវ ដូចជា រវាង ការបង្កើនទិន្នផលហើយនិងការអភិវឌ្ឍដំណាំស្រូវគុណភាព ខ្ពស់និងច្រើនប្រភេទជាដើម ។ ម្យ៉ាងទៀត កម្ពុជាក៏អាចរៀនសូត្រពីបទពិសោធន៍នៅថៃក្នុងការលើកកម្ពស់ការអភិវឌ្ឍ និងការស្រាវជ្រាវកសិកម្មដើម្បីកែលំអគុណភាព និងរសជាតិពូជស្រូវផ្សេងៗ ។ ការស្រាវជ្រាវទាំងនេះ ក៏ត្រូវពិចារណាពីផលប៉ះពាល់នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាំស្រូវខុសៗគ្នាទៅលើ ភាពក្រីក្រ សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្រិតគ្រួសារដែរ ។

ការស្រាវជ្រាវពីពិពិធកម្មមុខដំណាំ ក៏សំខាន់សម្រាប់យុទ្ធសាស្ត្រកសិកម្មរបស់កម្ពុជាដែរ ។ ដំណាំត្រូវការដីខ្ពស់ ដូចជា ដំឡូង និងពោត អាចផ្ដល់ប្រាក់ចំណូលកាន់តែច្រើនដល់កសិករ ជួយទ្រទ្រង់សន្តិសុខស្បៀងក្នុងតំបន់មួយចំនួន និងពង្រីកមូលដ្ឋានរកប្រាក់ចំណូលពីការនាំចេញទំនិញកសិកម្ម ។ បទពិសោធន៍ និងមេរៀននៅតាមបណ្ដាប្រទេសនៅអាស៊ីអាគ្នេយ៍ ក៏មានប្រយោជន៍គួរសិក្សាដែរ ។ ការស្រាវជ្រាវពីពិពិធកម្មដំណាំគួរផ្ដោតទៅលើទាំងផលិតកម្ម និងការធ្វើពិពិធកម្ម ។ បទពិសោធន៍នៅប្រទេសអាស៊ីអាគ្នេយ៍នានាបង្ហាញថា ផលិតកម្មស្បៀងមានច្រើនមុខ អាចធ្វើឲ្យការហូបចុកមានអាហារច្រើនមុខដែរ ដែលជួយកែលំអស្ថានភាពអាហារូបត្ថម្ភរបស់គ្រួសារនៅជនបទ ។ ទំនាក់ទំនងរវាងពិពិធកម្មផលិតកម្ម ពិពិធកម្មការហូបចុក និងការកែលំអអាហារូបត្ថម្ភ គួរមានការសិក្សាកាន់តែលម្អិតនៅពេលអនាគត ។

សរុបមក ការអភិវឌ្ឍយុទ្ធសាស្ត្រវិស័យកសិកម្មផ្អែកលើភស្តុតាងជាក់ស្ដែង ត្រូវមានការស្រាវជ្រាវបង្កើនការយល់ដឹងពីឧត្តមភាពប្រៀបធៀបរបស់កម្ពុជា និងជម្រើសនានាសម្រាប់ស្វែងរកឧត្តមភាពនេះ ។ ត្រូវមានការយល់ដឹងកាន់តែច្បាស់ដែរពីអន្តរកម្មរវាងជម្រើសកំណើនខុសៗគ្នា និងផលប្រយោជន៍នៃកំណើនក្នុងការបង្កើតប្រាក់ចំណូលសម្រាប់អ្នកក្រ និងការកែលំអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។ បន្ទាប់មក ត្រូវមានការកំណត់ច្បាស់ពីអាទិភាព និងលំដាប់នៃវិនិយោគសាធារណៈដើម្បីជំរុញកំណើនកសិកម្ម ។

## ឯកសារយោង


ADB ( 2010 ), *Asian Development Outlook 2010: Macroeconomic Management beyond the Crisis,* ( Mandaluyong City, Philippines: Asian Development Bank )

Blair, G. and N. Blair ( 2010 ), Soil Fertility Constraints and Limitations to Fertiliser Recommendations in Cambodia, paper presented at the 19th World Congress of Soil Science, Soil Solutions for a Changing World, 1 - 6 August 2010, Brisbane, Australia

CDRI ( 2008 ), Impact of High Food Prices in Cambodia: Survey Report. Phnom Penh, ( ambodia: Cambodia Development Resource Institute )

CSES ( 2004; 20070, Cambodia Socio-Economic Survey ( Phnom Penh, Cambodia: National Institute of Statistics )

FAO ( 2010 ), FAOSTAT, http://faostat.fao.org/ ( accessed September 2010 )

IFDC ( 2008 ), http://www.eurekalert.org/pub_releases/2008-02/i-wfp021908.php

IMF ( 2009 ), *Cambodia: Statistical Appendix,* Country Report No. 09/48 ( Washington D.C.: International Monetary Fund )

MAFF & MOWRAM ( 2008 ), *Strategy for Agriculture and Water: Cambodian Agricultural and Agribusiness Support Programme* ( Phnom Penh, Cambodia: Ministry of Agriculture Forestry and Fisheries and Ministry of Water Resources and Meteorology )

Pech, S. & K. Sunada ( 2008 ), Population Growth and Natural Resources Pressures in the Mekong River Basin, *Ambio* 37( 3 ): 219-224

World Bank ( 2009 ), *World Development Indicator* ( Washington, D.C.: World Bank )

Yu, B. & S. Fan ( forthcoming ), Rice Production Response in Cambodia.,Agricultural Economics, No. doi: 10.1111/j.1574-0862.2010.00522.x

# សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា៖ លំនាំ និងមាគ៌ាឆ្ពោះទៅរកជោគជ័យ

## ឯកសារពិភាក្សាគោលនយោបាយ[១]

### សេចក្ដីផ្ដើម

នៅប៉ុន្មានឆ្នាំថ្មីៗនេះ អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ មានកំណើនសេដ្ឋកិច្ចលឿនគួរឱ្យកត់សម្គាល់ ដែលជំរុញឡើងដោយកំណើនយ៉ាងលឿនរបស់ប្រទេសចិន និងឥណ្ឌា ។ ដោយសារមានការផ្លាស់ប្ដូរនៅក្នុងតំបន់បែបនេះ កម្ពុជាក៏ទទួលបានផលចំណេញពីទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេសជិតខាងផ្ទាល់ ដូចជា ថៃ និងវៀតណាម និងប្រទេសដទៃទៀតនៅក្នុងតំបន់ ដូចជា ចិន ជាដើម ។ ប្រទេសវៀតណាម ថៃ និងចិន ជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់កម្ពុជា ហើយក៏បានផ្ដល់ឱកាសការងារជាច្រើនដល់ប្រជាជនកម្ពុជាដែរ តាមរយៈការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែន ។ ម្យ៉ាងទៀត កម្ពុជាកំពុងតាមដានយ៉ាងជិតដល់លើការរីកចម្រើន និងកត្តារាំងស្ទះការអភិវឌ្ឍនៅវៀតណាម ដែលជាប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង និង នៅថៃ ដែលជាប្រទេសមានប្រាក់ចំណូលឡើងដល់កម្រិតមធ្យម និងសម្រេចបាន កំណើនសេដ្ឋកិច្ចលឿនប្រកបដោយចីរភាពក្នុងរយៈពេលបួនទសវត្សរ៍មុនពេលមានវិបត្តិអាស៊ី ។

ក្នុងស្ថានភាពរួមនៃអន្តរកម្ម និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ការអភិវឌ្ឍនៅកម្ពុជា និងឥទ្ធិពលនៃការអភិវឌ្ឍ ទៅលើអាហារូបត្ថម្ភ និងសន្តិសុខស្បៀង អាចកាន់តែងាយយល់បានតាមការប្រៀបធៀបជាមួយបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ ម្យ៉ាងទៀត បទពិសោធន៍ដែលប្រទេសអាស៊ីដទៃទៀតទទួលបាននៅដំណាក់កាលដំបូងនៃការអភិវឌ្ឍ និងមាគ៌ាដែលគេប្រកាន់យក ដើម្បីទទួលបានជោគជ័យដូចសព្វថ្ងៃ អាចផ្ដល់ជាព័ត៌មានដ៏មានប្រយោជន៍ ដើម្បីវាយតម្លៃពីដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍនៅកម្ពុជា និងព្យាករណ៍ពីឱកាស និងបញ្ហាប្រឈមដែលកម្ពុជាត្រូវជួបប្រទះនៅពេលអនាគត ។

អត្ថបទនេះ បង្ហាញជារួមពី ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ដោយឈរលើទស្សនវិស័យនៃការអភិវឌ្ឍក្នុងតំបន់ ។ អត្ថបទនេះ មានគោលបំណងស្វែងយល់ពីស្ថានភាពបច្ចុប្បន្ននៅក្នុងបរិបទនៃការផ្លាស់ប្ដូរសេដ្ឋកិច្ច និងកំណត់នូវលំនាំរួមគ្នា និងលំនាំខុសៗគ្នា រវាងកម្ពុជា និងប្រទេសដទៃទៀតក្នុងតំបន់ ។ មេរៀនដែលទទួលបានពីប្រទេសទាំងនេះ អាចជួយដល់ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងអន្តរាគមន៍ជាក់លាក់លើអាហារូបត្ថម្ភ និងសន្តិសុខស្បៀងនៅកម្ពុជា ។

អត្ថបទនេះ ចែកចេញជាបីផ្នែក ។ ផ្នែកទីមួយ បង្ហាញពីក្របខណ្ឌទស្សនទានមួយសម្រាប់វិភាគពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្សារភ្ជាប់នឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ។ ក្របខណ្ឌនេះ សង្កត់ធ្ងន់ទៅលើអន្តរកម្ម និងចំណងទាក់ទងរវាងកត្តាផ្សេងៗដែលជះឥទ្ធិពលទៅលើស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀងទាំងនៅកម្រិតម៉ាក្រូ និងមីក្រូ ។ ផ្នែកទីពីរ វិភាគពីស្ថានភាពបច្ចុប្បន្ននៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ធៀបនឹងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ដទៃទៀត និងនិន្នាការនៃការអភិវឌ្ឍ ។ ទិន្នន័យមានស្រាប់ និងសូចនាករសំខាន់ៗនៃការអភិវឌ្ឍ និងអាហារូបត្ថម្ភ ត្រូវបានយកមកប្រើប្រាស់ ដើម្បីគូសបញ្ជាក់ពីតួនាទីនៃកំណើនសេដ្ឋកិច្ច ក្នុងការជំរុញសន្តិសុខស្បៀង និងអាហារូបត្ថម្ភឲ្យកាន់តែប្រសើរឡើង ។ ផ្នែកទីបី គឺជាសេចក្ដីសន្និដ្ឋាន ។

### ក្របខ័ណ្ឌទស្សនទាន និងកត្តាជំរុញសន្តិសុខស្បៀង

ទស្សនៈបច្ចុប្បន្ន ស្ដីពីសន្តិសុខស្បៀង បានផ្ដល់ជាក្របខ័ណ្ឌដ៏មានប្រយោជន៍ និងគ្រប់ជ្រុងជ្រោយមួយ សម្រាប់វិភាគពីស្ថានភាពអាហារូបត្ថម្ភ និងស្បៀងអាហារ និងស្វែងយល់ពីកត្តាជំរុញសំខាន់ៗ ។ និយមន័យរួមគ្នាសព្វថ្ងៃ ស្ដីពីសន្តិសុខស្បៀង ត្រូវបានកំណត់ឡើងក្នុងកិច្ចប្រជុំកំពូល ស្ដីពីស្បៀងអាហារសាកលកាលពីឆ្នាំ១៩៩៩ ។ សន្តិសុខស្បៀងកើតមានឡើង "នៅពេលមនុស្សទាំងអស់ មានលទ្ធភាពពេញលេញទាំងផ្នែករូបវ័ន្ត ផ្នែកសង្គម និងផ្នែកសេដ្ឋកិច្ច ក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ សម្រាប់បំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេល ដើម្បីឲ្យមានជីវិតរស់នៅយ៉ាងសកម្ម និងសុខភាពមាំមួន" (FAO 1996) ។ ការសម្រេចបានស្ថានភាពបែបនេះ ទាមទារឱ្យមានសកម្មភាពរួមគ្នានៅកម្រិត បុគ្គល គ្រួសារ ជាតិ តំបន់ និងសាកល (FAO 1996) ។ ក្នុងកិច្ចប្រជុំកំពូល ស្ដីពីសន្តិសុខស្បៀងសាកលកាលពីឆ្នាំ២០០៩ សហគមន៍អន្តរជាតិបានបញ្ជាក់គាំទ្រដល់និយមន័យនេះ និងសង្កត់ធ្ងន់ថា "សមាសធាតុអាហារូបត្ថម្ភត្រូវមានជាចាំបាច់ក្នុងនិយមន័យនេះ" (FAO 2009) ។ និយមន័យដែលមានសមាសធាតុច្រើនបូកបញ្ចូលគ្នានៃសន្តិសុខស្បៀង ត្រូវបានយកមកប្រើជាទូទៅក្នុងអត្ថបទនេះ ។

ក្រាហ្វិក ១ បង្ហាញពីក្របខណ្ឌទស្សនទាន សម្រាប់ការវិភាគពីសន្តិសុខស្បៀង ដែលជាអាទិភាពមួយក្នុងយុទ្ធសាស្ត្រ

---

១ អត្ថបទនេះរៀបចំឡើងដោយបណ្ឌិត Olivier Ecker និង បណ្ឌិត Xinshen Diao នៃវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) ។ អត្ថបទនេះផ្អែកលើឯកសារពិភាក្សាគោលនយោបាយ រៀបចំសម្រាប់កិច្ចប្រជុំបូកសរុប ស្ដីពី គោលនយោបាយកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជា ដែលធ្វើឡើងកាលពី ថ្ងៃទី ៤ វិច្ឆិកា ២០១០ ។

អភិវឌ្ឍន៍របស់កម្ពុជា ។ ការស្វែងរកឧបករណ៍គោលនយោបាយ និងយុទ្ធសាស្ត្រដ៏សក្តិសិទ្ធ ដើម្បីសម្រេចបានសន្តិសុខស្បៀងតាមនិយមន័យកំណត់ឡើងដោយកិច្ចប្រជុំកំពូល តម្រូវឱ្យមានវិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងបូកបញ្ចូលគ្នា និងទូលំទូលាយមួយ ដែលគិតគូរដល់លក្ខណៈច្រើនកម្រិត និងឆ្លងវិស័យនៃបញ្ហាសន្តិសុខស្បៀង ។ ដោយសារមានផលប៉ះពាល់ធ្ងន់ធ្ងរពីវិបត្តិសេដ្ឋកិច្ចសាកលនាពេលថ្មីៗ ក្របខណ្ឌរបស់យើងបានពង្រីកក្របខណ្ឌមានស្រាប់ (ដែលផ្តោតទៅលើបញ្ហាអាហារូបត្ថម្ភ និងការប្រើប្រាស់ស្បៀងនៅកម្រិតបុគ្គល និងគ្រួសារ) ដោយដាក់បញ្ចូលនូវសមាសធាតុម៉ាក្រូសេដ្ឋកិច្ចថែមទៀត ។ ក្របខណ្ឌនេះបានបង្ហាញពីច្រកផ្សេងៗនៅក្នុងប្រព័ន្ធសន្តិសុខស្បៀង ដែលក្នុងនោះ ម្ខាងមានអន្តរាគមន៍ផ្សេងៗនិងគោលនយោបាយ និងម្ខាងទៀតមានការប៉ះទង្គិចពីផ្នែកក្រៅ (ដូចជា វិបត្តិសាកល និងមហន្តរាយជាប់ទាក់ទងនឹងអាកាសធាតុ) ចូលមកលាយឡំគ្នាជះឥទ្ធិពលទៅលើស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជន ក៏ដូចជាកត្តាសំខាន់ៗដែលកំណត់ពីស្ថានភាពអាហារូបត្ថម្ភ ។ វាក៏បង្ហាញដែរថា ការផ្លាស់ប្តូរក្នុងស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជន មិនត្រឹមតែជះឥទ្ធិពលទៅលើសុខុមាលភាពរបស់បុគ្គល និងគ្រួសារប៉ុណ្ណោះទេ គឺថែមទាំងទៅលើ ការអភិវឌ្ឍសេដ្ឋកិច្ច និងទម្រង់សង្គម ទាំងនៅកម្រិតសហគមន៍ និងកម្រិតជាតិ ។

ក្របខ័ណ្ឌទស្សនទាន បានបង្ហាញភាពខុសគ្នា រវាងសន្តិសុខស្បៀងនៅកម្រិតម៉ាក្រូ និងកម្រិតមីក្រូ ។ នៅកម្រិតម៉ាក្រូ គឺមាន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រីឯកម្រិតមីក្រូ គឺមានកម្រិតបុគ្គល និងកម្រិតគ្រួសារ ។ យើងមិនត្រូវយល់ច្រឡំថា សន្តិសុខស្បៀងកម្រិតម៉ាក្រូ ជាការផលិតស្បៀងបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯងនោះទេ ពីព្រោះវាសំដៅទៅដល់តុល្យភាពនៃការផ្គត់ផ្គង់ និងតម្រូវការស្បៀងនៅក្នុងប្រទេស ឬក្នុងតំបន់ជាក់លាក់ណាមួយ ដែលនៅទីនោះតម្រូវការស្បៀង ទាំងបរិមាណ និងគុណភាព អាចដោះស្រាយបាន ដោយផលិតកម្មក្នុងស្រុក ឬដោយការនាំចូលជាក់ស្តែង ឬមធ្យោបាយទាំងពីរ (ករណីភាគច្រើន) ។ ក្នុងន័យនេះ សន្តិសុខស្បៀងកម្រិតម៉ាក្រូត្រូវបានកំណត់ឡើងដោយរចនាសម្ព័ន្ធ និងប្រតិបត្តិការនៃសេដ្ឋកិច្ចក្នុងស្រុក និងជាពិសេសវិស័យគន្លឹះជាក់លាក់មួយចំនួន ។ សន្តិសុខស្បៀងកម្រិតមីក្រូ ត្រូវបានកំណត់ដោយគ្រួសារ និងសមាជិកគ្រួសារគ្រប់រូប ដែលមានលទ្ធភាពទទួលបានស្បៀងអាហារមានបរិមាណ និងសារជាតិចិញ្ចឹមគ្រប់គ្រាន់ ក៏ដូចជាវត្តមានទ្រព្យសម្បត្តិគ្រួសារ និងលទ្ធភាពទទួលបានសេវា (សាធារណៈ) មូលដ្ឋាន ដែលជះឥទ្ធិពលទៅលើសុខភាព និងអាហារូបត្ថម្ភ របស់បុគ្គល ។ លទ្ធភាពទទួលបាន ភាគច្រើនជួបកំហិតនៃមធ្យោបាយខាងសេដ្ឋកិច្ច ដូចជា ភាពក្រីក្រ (ដាច់ខាត) ជាដើម ។

## សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងការអភិវឌ្ឍ

ភស្តុតាងក្នុងប្រវត្តិសាស្ត្របង្ហាញថា ជាទូទៅកំណើនសេដ្ឋកិច្ចនាំឲ្យអាហារូបត្ថម្ភរបស់មនុស្សប្រែប្រួលប្រសើរឡើង ហើយផ្លូវដើរដែលមើលឃើញច្បាស់ និងកាត់ត្រង់បំផុតដើម្បីឈានពីកំណើន

ក្រាហ្វិក ១៖ ក្របខ័ណ្ឌទស្សនទាននៃសន្តិសុខស្បៀង សម្រាប់ការវិភាគយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេស




*ប្រភព៖ ចងក្រងដោយអ្នកនិពន្ធ*

សេដ្ឋកិច្ចទៅដល់អាហារូបត្ថម្ភល្អប្រសើរ គឺតាមរយៈប្រាក់ចំណូលគ្រួសារ ។ ប្រសិនបើកំណើននាំឱ្យចំណូលគ្រួសារកើនឡើង ពេលនោះប្រជាជនតែងអាចបង្កើនការហូប (ក្នុងករណីកត្តាផ្សេងៗស្ថិតនៅថេរ) នូវស្បៀងអាហារដែលមានសារជាតិចិញ្ចឹមកម្រិតខ្ពស់ ដូច្នេះហើយប្រជាជនភាគច្រើន ក៏មានស្ថានភាពអាហារូបត្ថម្ភកាន់តែប្រសើរ ។ ប៉ុន្តែឥទ្ធិពលជួយកែលំអបន្តិចម្ដងៗនេះ អាចត្រូវរាំងស្ទះនៅតាមកម្រិតផ្សេងៗ និងត្រង់ចំណុចផ្សេងៗគ្នា ។ ច្រកមួយទៀតដើម្បីឲ្យកំណើនអាចជួយកែលំអស្ថានភាពអាហារូបត្ថម្ភ គឺអន្តរាគមន៍តាមគោលនយោបាយសាធារណៈ ។ កំណើនសេដ្ឋកិច្ចផ្ដល់ប្រាក់ចំណូលឲ្យរដ្ឋបានកាន់តែច្រើន និងជួយឲ្យរដ្ឋាភិបាលអាចរៀបចំជាកម្មវិធីស្បៀង និងអាហារូបត្ថម្ភ ឬពង្រីកបន្ថែមនូវសេវាអប់រំ និងសុខភាពសាធារណៈ ។

ភាពខុសគ្នាជាខ្លាំងនៃស្ថានភាព និងការកែលំអអាហារូបត្ថម្ភពីមួយឆ្នាំទៅមួយឆ្នាំនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ បានបង្ហាញថា កំណើនសេដ្ឋកិច្ចនៅប្រទេសមួយចំនួន បានជ្រាបចុះទៅដល់ប្រជាជនបានច្រើនជាងនៅប្រទេសដទៃទៀត ហើយរដ្ឋាភិបាលមួយចំនួនមានជោគជ័យច្រើន ក្នុងការប្រើប្រាស់កំណើនសេដ្ឋកិច្ចដើម្បីកែលំអស្ថានភាពអាហារូបត្ថម្ភ ប៉ុន្តែប្រទេសខ្លះទៀតមិនសូវបានជោគជ័យទេ និងប្រទេសខ្លះទៀតទទួលបរាជ័យតែម្ដង ។ ប្រទេសទទួលជោគជ័យ ជាបណ្ដាប្រទេសដែលបានបង្កើតជាកញ្ចប់គោលនយោបាយដ៏ស័ក្ដិសិទ្ធិ ជំរុញឲ្យមានកំណើនប្រាក់ចំណូលកម្រិតខ្ពស់ មានចីរភាពល្អ និងផ្ដល់ផលចំណេញដល់ជនក្រីក្រ ព្រមទាំងអន្តរាគមន៍ផ្សេងៗ ដែលផ្ដោតចំក្រុមជនងាយរងគ្រោះបំផុត ។ ទោះបីជាការផ្សំបញ្ចូលគ្នានូវជម្រើសគោលនយោបាយ ត្រូវតែរៀបចំឱ្យសមស្របទៅនឹងលក្ខខណ្ឌជាក់លាក់ក្នុងប្រទេសនីមួយៗក៏ដោយ ក៏ប្រទេសដែលទទួលបានជោគជ័យនានា តែងមានលក្ខខណ្ឌពីដំបូងប្រហាក់ប្រហែលគ្នា ហើយច្រើនតែមានលំនាំរីកលូតលាស់ដូចគ្នា និងដើរតាមមាគ៌ាប្រហាក់ប្រហែលគ្នា ។

**ស្ថានភាពអភិវឌ្ឍន៍ និងសន្តិសុខស្បៀងនៅកម្ពុជា នៅក្នុងបរិបទតំបន់នេះ**

ជាបឋម គួរពិនិត្យពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍ និងសន្តិសុខស្បៀងនៅកម្ពុជា និងរកមើលថា នៅឆ្នាំណាដែលបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ដទៃទៀត សម្រេចបាននូវស្ថានភាពប្រហាក់ប្រហែលគ្នា ក្នុងនេះគួរជ្រើសយកប្រទេស ចិន ឡាវ ថៃ វៀតណាម ឥណ្ឌា និងបង់ក្លាដែស សម្រាប់ធ្វើការប្រៀបធៀប ។ សន្ទស្សន៍អភិវឌ្ឍន៍នៅកម្រិតម៉ាក្រូ ផលិតផលក្នុងស្រុកសរុប (ផសស) គិតក្នុងមនុស្សម្នាក់ ចំណែកឯសន្ទស្សន៍នៅកម្រិតមីក្រូ គឺជា សន្ទស្សន៍ដែលគេតែងប្រើប្រាស់ជាទូទៅក្នុងការកំណត់ ភាពក្រីក្រ ភាពស្រេកឃ្លាន កង្វះអាហារូបត្ថម្ភកុមារ និងអត្រាមរណភាពរបស់កុមារ ។ ទិន្នន័យ បានប្រមូលចងក្រងឡើងពីប្រភពសាធារណៈផ្សេងៗ ដូចជា សន្ទស្សន៍អភិវឌ្ឍន៍សាកល (WDI 2010) មូលដ្ឋានទិន្នន័យស្ថិតិសន្តិសុខស្បៀងរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FSS 2010) និងមូលដ្ឋានទិន្នន័យសាកល ស្ដីពីកង្វះអាហារូបត្ថម្ភ និងការលូតលាស់ធំធាត់នៃកុមារ របស់អង្គការសុខភាពពិភពលោក (GDCGM 2010) ។

កម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងលឿនចាប់ពីឆ្នាំ១៩៩៣មក ជាពិសេសចាប់តាំងពីឆ្លងចូលសហស្សវត្សរ៍ថ្មី (Naron 2009) ។ នៅចន្លោះឆ្នាំ១៩៩៣ និង ១៩៩៨ ផសស កើនឡើង ៦,៣% ក្នុងមួយឆ្នាំ និង ៩,៥% ជាមធ្យមក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩៩ និង ២០០៨ ។ ទោះជាយ៉ាងនេះក្ដី កម្ពុជានៅតែជាប្រទេសមានប្រាក់ចំណូលទាប ដោយមានប្រាក់ចំណូលជាមធ្យមក្នុងមនុស្សម្នាក់ ៥០០ដុល្លារ នៅឆ្នាំ២០០៨ (តារាង ១ ខ្ទង់ទី១) ។ ក្នុងចំណោមប្រទេសដែលយកមកប្រៀបធៀបក្នុងការសិក្សានេះ មានតែ ឡាវ និងបង់ក្លាដែស ប៉ុណ្ណោះ ដែលមានកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ ទាបជាងកម្ពុជា ។ នៅឆ្នាំ២០០៨ ប្រាក់ចំណូលក្នុងមនុស្សម្នាក់នៅវៀតណាម និងឥណ្ឌា មានកម្រិតខ្ពស់ជាងកម្ពុជាបន្តិច ប៉ុន្តែចិនមានកម្រិតខ្ពស់ជាងមួយជាបួន និង ថៃមួយជាប្រាំ ។ ឥណ្ឌាឡើងដល់កម្រិតប្រាក់ចំណូលដូចកម្ពុជានាបច្ចុប្បន្ននៅឆ្នាំ២០០៣ ហើយវៀតណាមនៅឆ្នាំ២០០៤ រីឯចិនមានប្រាក់ចំណូលក្នុងមនុស្សម្នាក់ឡើងដល់កម្រិត ៥០០ដុល្លារ នៅឆ្នាំ២០០៣ និង ថៃ នៅឆ្នាំ១៩៧០ ។

វិសមភាពប្រាក់ចំណូលនៅកម្ពុជា មានលក្ខណៈកាន់តែធ្ងន់ធ្ងរ បើវាស់វែងដោយមេគុណ GINI នៅអំឡុងពេលដែលកម្ពុជាមានកំណើនលឿន ។ នៅឆ្នាំ១៩៩៤ មេគុណ GINI មានកម្រិត ០,៣៨ និងនៅឆ្នាំ២០០៧ មានកម្រិត ០,៤៤ ដែលជាតួលេខខ្ពស់បំផុតក្នុងចំណោមប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ ទោះបីវិសមភាពប្រាក់ចំណូលកើនលឿនក្ដី ក៏ភាពក្រីក្របានធ្លាក់ចុះយ៉ាងច្រើនគួរកត់សម្គាល់ ប៉ុន្តែវានៅតែប៉ះពាល់ដល់ប្រជាជនកម្ពុជាប្រមាណ ២៥% នាពេលបច្ចុប្បន្ន ។ ទោះបីកម្ពុជា មានការរីកចំរើនក្នុងពេលកន្លងមក ទាំងនៅតំបន់ជនបទ និងទីក្រុងក្ដី ក៏អត្រាភាពក្រីក្រនៅជនបទ នៅតែមានកម្រិតខ្ពស់ជាងទីក្រុងដដែល ។ កំណើនសេដ្ឋកិច្ចលឿននៅទីក្រុង និងការកាត់បន្ថយភាពក្រីក្រយឺតៗនៅជនបទ អាចមានចំណែកក្នុងកំណើនវិសមភាពប្រាក់ចំណូលនៅទូទាំងប្រទេស ។ កម្ពុជាមានភាពក្រីក្រស្មើនឹង ប្រហែលពាក់កណ្ដាលនៃកម្រិតនៅបង់ក្លាដែស និង ២ភាគ៣នៃកម្រិតនៅឥណ្ឌា និង ឡាវ (តារាង ១ ខ្ទង់ទី២) ។

ទោះបីជួបការលំបាកនៅអំឡុងពេលមានវិបត្តិអាស៊ីក្ដី ក៏កម្ពុជា បានកាត់បន្ថយប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភពីអត្រា ៣៨% នៅឆ្នាំ១៩៩២ មកត្រឹម ២៥% នៅឆ្នាំ២០០៦ គឺប្រហាក់ប្រហែលគ្នានឹងអត្រាភាពក្រីក្រ ។ ប៉ុន្តែមិនដូចជាភាពក្រីក្រទេ អត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភ (ឬភាពស្រេកឃ្លានដែលគេតែងលើកឡើង) ដែលជាភាគរយនៃប្រជាជនហូបចូលកាឡូរីតិចជាងកម្រិតតម្រូវការអប្បបរមា វាស្ទើរស្មើគ្នានឹងប្រទេសបង់ក្លាដែស និងខ្ពស់ជាងប្រទេសឥណ្ឌាបន្តិចផង (តារាង ១ ខ្ទង់ទី៣) ។ ផ្ទុយទៅវិញ អត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភនៅឡាវ ទាបជាងនៅកម្ពុជា ទោះបីឡាវមានកម្រិតភាពក្រីក្រខ្ពស់ជាង និងមានកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ទាបជាងកម្ពុជាក្ដី ។

តារាង ១៖ ការប្រៀបធៀបស្ថានភាពសន្តិសុខស្បៀង និងការអភិវឌ្ឍនៅកម្ពុជា

| | ផសស ក្នុងមនុស្សម្នាក់ (ថ្លៃដុល្លារថេរឆ្នាំ២០០០) | | អនុបាតភាពក្រីក្រក្រោម កម្រិត ១,២៥ដុល្លារ ក្នុងមួយថ្ងៃ (% នៃប្រជាជន) | | ប្រេវ៉ាឡង់ នៃកង្វះអាហារូបត្ថម្ភ (% នៃប្រជាជន) | | ប្រេវ៉ាឡង់ នៃកុមារគ្រិន (% នៃ កុមារអាយុក្រោម ៥ឆ្នាំ) | | អត្រាមរណភាព នៃកុមារអាយុក្រោម ៥ឆ្នាំ (ក្នុង ១០០០នាក់) | |
|---|---|---|---|---|---|---|---|---|---|---|
| | 2008 | *មានស្ថានភាព ប្រហែលគ្នានៅឆ្នាំ* | 2005-07 | *មានស្ថានភាព ប្រហែលគ្នានៅឆ្នាំ* | 2005-07 | *មានស្ថានភាព ប្រហែលគ្នានៅឆ្នាំ* | 2006-08 | *មានស្ថានភាព ប្រហែលគ្នានៅឆ្នាំ* | 2008 | *មានស្ថានភាព ប្រហែលគ្នានៅឆ្នាំ* |
| កម្ពុជា | 511 | | 26 | | 25 | | 40 | | 90 | |
| បង់ក្លាដែស | 462 | - | 50 | - | 26 | - | 43 | - | 54 | *2000* |
| ឡាវ | 475 | - | 44* | - | 19 | *1997* | 48 | - | 61 | *1999* |
| វៀតណាម | 647 | *2004* | 21 | *2004* | 13 | *1994* | 36 | *2002* | 14 | *<1975* |
| ឥណ្ឌា | 718 | *2003* | 42 | - | 22 | *1992* | 48 | - | 69 | *2001* |
| ចិន | 1,965 | *1993* | 16 | *2002* | 10 | *<1992* | 22* | *n.a.* | 21 | *1974* |
| ថៃ | 2,640 | *1970* | 2 | *<1981* | 17 | *1994* | 16 | *<1987* | 14 | *1973* |
| អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក | 1,760 | *1991* | 17 | *2002* | 12 | *<1992* | 27 | *const.* | 29 | *1976* |
| សាកលលោក | 6,007 | *n.a.* | n.a. | *n.a.* | 14 | *n.a.* | 35 | *n.a.* | 67 | *1992* |

*កំណត់សម្គាល់៖ * តួលេខប៉ាន់ស្មានក្នុងឆ្នាំ២០០២, n.a. (not available) បានន័យថា គ្មានតួលេខ, cont. (constant) បានន័យថា ថេរ*

*ប្រភព៖ WDI 2010, FSS 2010, GDCGM 2010*

នៅពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាក៏សម្រេចជោគជ័យគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភកុមារ ។ នៅឆ្នាំ១៩៩៦ មានកុមារអាយុក្រោម ៥ឆ្នាំ ប្រមាណ ៥៩% មានការលូតលាស់គ្រិន និង ៤៣% មានទម្ងន់ស្រាល ប៉ុន្តែនៅឆ្នាំ២០០៨ បញ្ហានេះបានថយចុះ ដោយអត្រាគ្រិនធ្លាក់ចុះមកត្រឹម ៤០% និង អត្រាទម្ងន់ស្រាល ធ្លាក់ចុះមកត្រឹម ២៩%[២] ។ ស្របគ្នានឹងកម្រិតប្រាក់ចំណូល បញ្ហាកង្វះអាហារូបត្ថម្ភកុមារនៅកម្ពុជា មានកម្រិតខ្ពស់ជាងនៅវៀតណាម ចិន និង ថៃ ប៉ុន្តែវាទាបជាងនៅឡាវ បង់ក្លាដែស និង ឥណ្ឌា (តារាង ១ ខ្ទង់ទី៤) ។

កម្ពុជាមានអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ កម្រិតខ្ពស់បំផុតក្នុងចំណោមបណ្ដាប្រទេសយកមកប្រៀបធៀប (តារាង ១ ខ្ទង់ទី៥) ។ ទោះបីអត្រាមរណភាពកុមារបានថយចុះកាន់តែលឿន ជាពិសេសចាប់ពីឆ្នាំ២០០០ មកក្ដី ក៏កុមារកម្ពុជា ៩០នាក់ ក្នុងចំណោម ១០០០នាក់ បានស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ សុខភាពទន់ខ្សោយ ឬបញ្ហាអាចបង្ការបានដទៃទៀត នៅឆ្នាំ២០០៨ ។ នៅឆ្នាំ១៩៩០ មានកុមារ ១១៧នាក់ ក្នុងចំណោម ១០០០នាក់ ត្រូវស្លាប់មុនដល់អាយុ ៥ឆ្នាំ ។ ដូច្នេះកម្ពុជា ទំនងមិនអាចសម្រេចបានទេនូវ ចំណុចទីបួននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន ដែលសំដៅកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ឲ្យបានពីរភាគបីនៅចន្លោះឆ្នាំ១៩៩០ និង ២០១៥ ។

២ សន្ទស្សន៍មនុស្សមាត្រវិធីចំនួនបី គេតែងប្រើប្រាស់ជាទូទៅក្នុងការកំណត់ពីបញ្ហាអាហារូបត្ថម្ភកុមារ គឺមាន កម្ពស់ធៀបនឹងអាយុ ទម្ងន់ធៀបនឹងអាយុ និងទម្ងន់ធៀបនឹងកម្ពស់ ។ គេចាត់ទុកថា កុមារមានលក្ខណៈគ្រិន ទម្ងន់ស្រាល ឬស្គមស្គាំង ខ្លាំង និងធ្ងន់ធ្ងរ ប្រសិនបើពិន្ទុកម្ពស់ធៀបនឹងអាយុ ពិន្ទុទម្ងន់ធៀបនឹងអាយុ ឬពិន្ទុទម្ងន់ធៀបនឹងកម្ពស់ របស់ពួកគេស្ថិតក្រោមកម្រិតគ្រោះថ្នាក់មួយចំនួន ។ សន្ទស្សន៍ទាំងបីនេះ មានអត្ថន័យផ្សេងៗគ្នាស្ដីពីអាហារូបត្ថម្ភកុមារ និងមិនអាចប្រើប្រាស់ប្ដូរផ្លាស់គ្នាបានទេ (WHO 1995) ។ តទៅនេះ អត្ថបទនឹងផ្ដោតទៅលើភាពគ្រិន ពីព្រោះសន្ទស្សន៍នៃកម្ពស់ធៀបនឹងអាយុ មានលក្ខណៈសមស្របបំផុតសម្រាប់កំណត់ពីកង្វះអាហារូបត្ថម្ភរយៈពេលវែង និងបកស្រាយពីអន្តរកម្មរវាងសុខភាព និង អាហារូបត្ថម្ភ ។

### កំណើនសេដ្ឋកិច្ចជាកម្លាំងជំរុញសន្តិសុខស្បៀង និងអាហារូបត្ថម្ភ

ផ្នែកនេះធ្វើការប្រៀបធៀបការអភិវឌ្ឍរបស់កម្ពុជា ជាមួយប្រទេសផ្សេងៗ និងពិភាក្សាពីទិសដៅដែលកម្ពុជាគួរប្រកាន់យកនាពេលអនាគត ។ នៅពេល ផសស ក្នុងមនុស្សម្នាក់ និងប្រាក់ចំណូលគ្រួសារកើនឡើង ភាពក្រីក្រត្រូវធ្លាក់ចុះ ហើយសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ជាទូទៅតែងកើនឡើង ។ ប៉ុន្តែល្បឿននៃកំណើន និងការកែលំអអាហារូបត្ថម្ភ អាចខុសៗគ្នា ដូចមានបង្ហាញក្នុងការប្រៀបធៀបតាមប្រទេស ។ ដោយហេតុថា ដំណាក់កាលនៃការអភិវឌ្ឍត្រូវតែយកមកគិតគូរ ដើម្បីប្រៀបធៀបពីជោគជ័យរបស់ប្រទេសផ្សេងៗ ក្នុងការប្រើប្រាស់កំណើនសេដ្ឋកិច្ចជំរុញឱ្យស្ថានភាពអាហារូបត្ថម្ភល្អប្រសើរឡើង ដូច្នេះការសិក្សានេះបានភ្ជាប់សន្ទស្សន៍នៃស្ថានភាពអាហារូបត្ថម្ភ ទៅនឹង កម្រិត ផសស នៅតាមឆ្នាំផ្សេងៗ ។

ក្រាហ្វិក ២ បង្ហាញពីការផ្លាស់ប្ដូរនៃប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ធៀបនឹងកំណើនសេដ្ឋកិច្ច សម្រាប់កម្ពុជា និងបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ក្នុងរយៈពេលកន្លងមក ។ គេឃើញថា ជាទូទៅកង្វះអាហារូបត្ថម្ភតែងធូរស្រាលនៅពេលកម្រិតប្រាក់ចំណូលកើនឡើង ។ ការធូរស្រាលនេះមានល្បឿនលឿនជាងនៅពេលដែល ផសស ក្នុងមនុស្សម្នាក់មានកម្រិតក្រោម ៥០០ដុល្លារ ។ ស្ថានភាពនេះកើតមានពិតនៅអំឡុងពេលទាំងមូលសម្រាប់ កម្ពុជា បង់ក្លាដែស ឡាវ និងវៀតណាម ប៉ុន្តែសម្រាប់ឥណ្ឌា វាកើតមានតែនៅអំឡុងពេលដំបូងៗនៃកំណើនតែប៉ុណ្ណោះ ។ ឥណ្ឌាជាប្រទេសតែមួយគត់

ក្រាហ្វិក ២៖ ទំនាក់ទំនងរវាងអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ និង ផសស ក្នុងមនុស្សម្នាក់




*កំណត់សម្គាល់៖ ទិន្នន័យពីឆ្នាំ១៩៩២ ១៩៩៧ ២០០២ និង ២០០៧*

*ប្រភព: WDI 2010, FSS 2010.*

ដែលមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកើនឡើង នៅពេលប្រាក់ចំណូលកើនកាន់តែលឿនក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ ទោះបីកម្ពុជា បានកាត់បន្ថយគួរឱ្យកត់សម្គាល់នូវអត្រាស្រេកឃ្លានក្នុងអំឡុងពេលដំបូងៗនៃកំណើនក្ដី ក៏ការកាត់បន្ថយនេះបានចាប់ផ្ដើមថយល្បឿននាពេលថ្មីៗ[៣] ។

នៅ ចិន និងវៀតណាម ទំនាក់ទំនងរវាងកង្វះអាហារូបត្ថម្ភ និងកម្រិតប្រាក់ចំណូល មានលក្ខណៈស្រដៀងគ្នាណាស់ ដោយសារខ្សែកោងដែលតំណាងឱ្យប្រទេសទាំងពីរមាននិន្នាការដូចគ្នា ។ ដូច្នេះ ទំនាក់ទំនងរវាងការកាត់បន្ថយភាពស្រេកឃ្លាន និងកំណើនប្រាក់ចំណូល នៅវៀតណាម ទំនងអាចទាយទុកបានផ្អែកតាមដំណើរការពីមុននៅចិន ។ ថៃមានកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ ខ្ពស់ជាងប្រទេសជ្រើសរើសឯទៀតៗ នៅចំណុចចាប់ផ្ដើមនៃខ្សែកោងរបស់ខ្លួន ប៉ុន្តែមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ខ្ពស់ជាងចិន នៅពេលចិនសម្រេចបាន កម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ប្រហាក់ប្រហែលគ្នានៅខាងចុងខ្សែកោង ។ ទោះបីល្បឿនកាត់បន្ថយភាពស្រេកឃ្លាននៅថៃ វាលឿនជាងនៅចិន បើធៀបនឹងល្បឿនកំណើនប្រាក់ចំណូល ប៉ុន្តែនៅត្រង់កម្រិតប្រាក់ចំណូលខ្ពស់ ថៃមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ខ្ពស់ជាងចិនគួរឱ្យកត់សម្គាល់ ។

ក្រាហ្វិក ៣ បង្ហាញពីអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ ធៀបនឹងកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់នៅកម្ពុជា និងប្រទេសបួនទៀតក្នុងពេលកន្លងមក ។ ខ្សែកោងចាប់ផ្ដើមពីកម្រិតខុសៗគ្នានៃប្រាក់ចំណូលក្នុងមនុស្សម្នាក់ និងអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ប៉ុន្តែស្ទើរគ្រប់ប្រទេស បានកាត់បន្ថយកង្វះអាហារូបត្ថម្ភកុមារ នៅពេលកម្រិតប្រាក់ចំណូលកើនឡើង លើកលែងតែប្រទេសឡាវ ដែលកម្រិតកង្វះអាហារូបត្ថម្ភកុមារស្ទើរតែគ្មានប្រែប្រួលអ្វីសោះ នៅពេលដែលប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនឡើងពី ៣០០ដុល្លារ ដល់ជាង ៤០០ដុល្លារ ។ ការប្រៀបធៀបនេះបង្ហាញថា នៅត្រឹមកម្រិតប្រាក់ចំណូលប្រហាក់ប្រហែលគ្នា អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ វាខុសគ្នាច្រើនរវាងប្រទេសទាំងប្រាំ ។ ដោយឡែកនៅត្រង់កម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ ទាបជាង ៣០០ដុល្លារ កម្ពុជាមានអត្រាប្រេវ៉ាឡង់កង្វះអាហារបត្ថម្ភកុមារខ្ពស់បំផុត គឺខ្ពស់ជាង បង់ក្លាដែស និងវៀតណាម នៅត្រង់កម្រិតប្រាក់ចំណូលប្រហាក់ប្រហែលគ្នាទៀតផង ។ នៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់ កើនពី ៣០០ ដល់ ៤០០ដុល្លារ អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមាររបស់វៀតណាម បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ប៉ុន្តែនៅអំឡុងពេលនោះ ខ្សែកោងរបស់កម្ពុជាមានលក្ខណៈរាបជាងខ្សែកោងរបស់វៀតណាម គឺបានន័យថា សម្រាប់កំណើនប្រាក់ចំណូលក្នុងមនុស្សម្នាក់ប្រហាក់ប្រហែលគ្នាពី ៣០០ ដល់ ៤០០ដុល្លារនេះ ការកាត់បន្ថយអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ នៅកម្ពុជា វាមានតិចជាងនៅវៀតណាម ។

នៅឯប្រទេសបង់ក្លាដែស នៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់មានកម្រិតទាប អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ មានកម្រិតខ្ពស់បំផុត ។ ប៉ុន្តែនៅពេលវាកើនឡើងបន្តិចពេលគឺ ប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនពី ២៥០ ដល់ ៤០០ដុល្លារ អត្រានេះបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ។ បង់ក្លាដែស អាចកាត់បន្ថយកង្វះអាហារូបត្ថម្ភកុមារបានជោគជ័យបែបនេះ ដោយសារមានការវិនិយោគធំៗទៅលើកម្មវិធីផ្ដោតចំគោលដៅជាច្រើន ។ នៅឯប្រទេសឥណ្ឌា នៅកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ក្បែរ ៥០០ដុល្លារ ស្ថានភាពអាហារូបត្ថម្ភរបស់

ក្រាហ្វិក ៣៖ ទំនាក់ទំនងរវាងអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ និង ផសស ក្នុងមនុស្សម្នាក់




*កំណត់សម្គាល់៖ ទិន្នន័យទទួលបានពីរវាងឆ្នាំ១៩៨៧ និង ២០០៨ ។*

*ប្រភព៖ WDI 2010, GDCGM 2010.*

៣ ចំណុចស្រួចៗនៅលើខ្សែកោងសម្រាប់កម្ពុជា និងបង់ក្លាដែស បង្ហាញពីផលប៉ះពាល់នៃវិបត្តិអាស៊ីនៅឆ្នាំ១៩៩៧ ។

ក្រាហ្វិក ៤៖ ទំនាក់ទំនងរវាងអត្រាមរណភាពកុមារ និង ផសស ក្នុងមនុស្សម្នាក់




*កំណត់សម្គាល់៖ ទិន្នន័យបានពីឆ្នាំដូចគ្នា នៅរវាងឆ្នាំ១៩៦០ និង ២០០៨ ។*

*ប្រភព: WDI 2010, GDCGM 2010.*

កុមារតូចៗមានលក្ខណៈអាក្រក់បំផុត ។ ហើយនៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់ កើនដល់ ៦០០ដុល្លារ (នៅចុងខ្សែកោង) អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារនៅតែល្អ ថយចុះតែតិចតួចប៉ុណ្ណោះ ។

ក្រាហ្វិក ៤ បង្ហាញពីអត្រាមរណភាពរបស់កុមារ ធៀបនឹង ផសស ក្នុងមនុស្សម្នាក់ ក្នុងពេលកន្លងមក ។ ប្រហែលគ្នានឹងលទ្ធផលដូចមានបង្ហាញក្នុងក្រាហ្វិក ១ ដែរ អត្រាមរណភាពរបស់កុមារ ធ្លាក់ចុះយ៉ាងខ្លាំង នៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនឡើង តែនៅទាបជាងកម្រិត ៥០០ដុល្លារ ។ បន្ទាប់ពីអត្រាមរណភាពរបស់កុមារ ធ្លាក់មកត្រឹម ៥០នាក់ក្នុង ១០០០នាក់ និងប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនខ្ពស់ជាង ៥០០ដុល្លារ ការកាត់បន្ថយអត្រាមរណភាពកុមារ ក៏ថយល្បឿន ។ ប៉ុន្តែវៀតណាមមានការវិវឌ្ឍខុសប្លែកពីគេ ដោយអត្រាមរណភាពកុមារបន្តធ្លាក់ចុះយ៉ាងខ្លាំងតទៅទៀត ក្រោយពេលសម្រេចបានអត្រាមរណភាពកុមារ ត្រឹម ៥០នាក់ក្នុង ១០០០នាក់ និង កម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់លើសពី ៥០០ដុល្លារ ។ នៅកម្រិតប្រាក់ចំណូលទាបជាង ៥០០ដុល្លារ ខ្សែកោងកម្ពុជា មានលក្ខណៈរាបស្មើបំផុត ក្នុងចំណោមប្រទេសជ្រើសរើសទាំងអស់ ។ ស្ថានភាពនេះបង្ហាញថា ការកែលំអសុខុមាលភាពរបស់ក្រុមកុមារទន់ខ្សោយបំផុតនៅកម្ពុជា មានល្បឿនយឺត ។

## សេចក្ដីសន្និដ្ឋាន

ទោះបីមានកំណើនសេដ្ឋកិច្ចខ្ពស់ និងការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ភាពស្រេកឃ្លាន និងអាហារូបត្ថម្ភនៅប៉ុន្មានឆ្នាំថ្មីៗនេះក្ដី ក៏កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដោយមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារកម្រិតខ្ពស់បំផុត ។ ការប្រៀបធៀបតាមប្រទេសក្នុងឯកសារនេះបង្ហាញថា ស្ថានភាពការអភិវឌ្ឍ និងសន្តិសុខស្បៀងនៅកម្ពុជា មានលក្ខណៈស្រដៀងគ្នានឹងនៅឡាវ និងបង់ក្លាដែសនាពេលបច្ចុប្បន្ន និងនៅវៀតណាមនាដើមទសវត្សរ៍ ២០០០ និង ថៃនាចុងទសវត្សរ៍ ១៩៧០ ។ និន្នាការនេះបង្ហាញថា ជាទូទៅកម្ពុជាដើរតាមលំនាំរបស់វៀតណាម និងចិន ដែលនៅទីនោះ កំណើនសេដ្ឋកិច្ចខ្ពស់បានហូរជ្រាបដល់ប្រជាជនស្រទាប់ក្រោម ហើយភាពស្រេកឃ្លាន និងកង្វះអាហារូបត្ថម្ភកុមារ បានថយចុះគួរឱ្យកត់សម្គាល់ គឺផ្ទុយពីការអភិវឌ្ឍនៅឥណ្ឌា ដែលបានហូររំលងប្រជាជនអ្នកជួបកង្វះអាហារូបត្ថម្ភ ។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗ កម្ពុជាបានងាកចេញពីមាគ៌ាមានជោគជ័យរបស់វៀតណាម និងចិន ដែលក្នុងនោះ កំណើននិងស្ថានភាពអាហារូបត្ថម្ភល្អប្រសើរវាកើតឡើងព្រមគ្នា។ ម្យ៉ាងទៀត វិសមភាពនៃប្រាក់ចំណូលបានកើនឡើងស្របគ្នានឹងកំណើនសេដ្ឋកិច្ច ហើយអត្រាកំណើនប្រជាជន ក៏នៅតែមានកម្រិតខ្ពស់ ។ កត្តាទាំងនេះរារាំងកម្ពុជាក្នុងការកែលំអសន្តិសុខស្បៀង និងស្ថានភាពអាហារូបត្ថម្ភ ជាពិសេសនៅពេលកំណើនសេដ្ឋកិច្ចបានថយចុះ ដោយសារឥទ្ធិពលនៃការធ្លាក់ចុះសេដ្ឋកិច្ចសាកលនាពេលថ្មីៗ ។

ការពិភាក្សាខាងលើនេះបង្ហាញថា ត្រូវមានកិច្ចប្រឹងប្រែងថែមទៀត ដើម្បីរុញច្រានកម្ពុជា ឱ្យដើរចំមាគ៌ាប្រកបដោយប្រសិទ្ធភាពរបស់វៀតណាម និងចិន និងប្រើប្រាស់កំណើនឲ្យបានកាន់តែសក្តិសិទ្ធិក្នុងការកែលំអស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀងសម្រាប់គ្រប់ៗគ្នានាពេលអនាគត ។ បង់ក្លាដែសមានកំណើនតិចជាងកម្ពុជាក៏ពិតមែន ប៉ុន្តែបទពិសោធន៍របស់បង់ក្លាដែសអាចផ្តល់ជាគំរូដ៏មានប្រយោជន៍សម្រាប់កម្ពុជា ពីព្រោះសកម្មភាពផ្តោតចំគោលដៅជាច្រើននៅប្រទេសនោះ បានជំរុញឱ្យស្ថានភាពអាហារូបត្ថម្ភកុមារប្រែប្រួលប្រសើរឡើងជាខ្លាំង ។

## ឯកសារយោង

FAO (Food and Agriculture Organisation of the United Nations) (1996), World Food Summit: Rome Declaration on World Food Security, http://www.fao.org/docrep/003/w3613e/w3613e00 (last accessed October 2010)

FAO (2009), Declaration of the World Summit on Food Security in Rome, http://www.fao.org/fileadmin/templates/wsfs/Summit/Docs/Final_Declaration/WSFS09_Declaration.pdf (last accessed 11 October 2010)

FSS (Food Security Statistics) (2010), Database of the Food and Agriculture Organisation of the United Nations, http://www.fao.org/economic/ess/food-security-statistics/en/ (last accessed October 2010)

GDCGM (Global Database of Child Growth and Malnutrition) (2010), Database of the World Health Organisation, http://www.who.int/nutgrowthdb/en/ (accessed October 2010)

Naron, H. C. (2009), *Cambodian Economy: Charting the Course of a Bright Future — A Survey of Progress*, Problems, and Prospects (Phnom Penh)

WDI (World Development Indicators) (2010), Database of the World Bank, http://data.worldbank.org/ (last accessed 11 October 2010)

WHO (World Health Organisation) (1995), Physical Status: The use and Interpretation of Anthropometry, report of a WHO expert committee, WHO Technical Report 854 (Geneva: WHO)

# ជំរើសគោលនយោបាយសម្រាប់ជនងាយរងគ្រោះ៖ កំណើនប្រាក់ចំណូល និងការគាំពារសង្គម[១]

## សេចក្ដីផ្ដើម

ការបំផ្លិចបំផ្លាញធនធានមនុស្ស សង្គម និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ក្នុងអំឡុងពេលពីរទសវត្សរ៍នៃសង្គ្រាម ជាដើមហេតុដ៏សំខាន់មួយនៃភាពក្រីក្រ ដែលបណ្ដាលឲ្យមានភាពងាយរងគ្រោះក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសអ្នកក្រីក្រនៅតាមទីជនបទ ។ កត្តារួមចំណែកដទៃទៀត មានដូចជា ការផាត់ចេញពីសង្គម កង្វះលទ្ធភាពទទួលបានសេវាសាធារណៈ និងឱកាសការងារមានតិច ។ ម្យ៉ាងវិញទៀត កំណើនវិស័យកសិកម្មមិនគ្រប់គ្រាន់ និងសេដ្ឋកិច្ចនៅជនបទមានមូលដ្ឋានតូចចង្អៀត ធ្វើឱ្យប្រជាជនភាគច្រើននៅជនបទងាយទទួលឥទ្ធិពលពីហានិភ័យ និងការប៉ះទង្គិចផ្សេងៗ ដែលអាចរុញច្រានពួកគេឲ្យធ្លាក់ចុះក្នុងភាពក្រីក្រធ្ងន់ធ្ងរ ។ ឧទាហរណ៍ ការធ្លាក់ចុះក្នុងពេលថ្មីៗនៃវិស័យជំរុញកំណើនសេដ្ឋកិច្ចសំខាន់ៗនៅកម្ពុជា ជាអាទិ៍ វិស័យកាត់ដេរ ទេសចរណ៍ និងសេវាកម្ម (ដោយសារវិបត្តិសេដ្ឋកិច្ចសាកល) បាននាំឲ្យមានការបាត់បង់ការងារ និងការថយចុះប្រាក់ផ្ញើទៅផ្ទះ។ ការធ្លាក់ចុះនេះ បានប៉ះពាល់ដោយផ្ទាល់ទៅលើកម្មករ និងក្រុមគ្រួសារ និងធ្វើឱ្យពួកគេរឹតតែងាយរងគ្រោះដោយការប៉ះទង្គិចផ្សេងៗទៅលើប្រាក់ចំណូល និងចំណាយប្រើប្រាស់ប្រចាំថ្ងៃ ។

អត្ថបទនេះ ពិនិត្យជារួមពីទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច ភាពក្រីក្រ ភាពងាយរងគ្រោះ និងកិច្ចគាំពារខាងសង្គមកិច្ច ដោយផ្អែកលើស្ថិតិ និងទិន្នន័យថ្មីៗ ព្រមទាំងឯកសារស្រាវជ្រាវផ្សេងៗដែលមានស្រាប់ ។ ដោយឡែកការសិក្សាមាន (១) កំណត់ក្រុមជនងាយរងគ្រោះ និងមូលហេតុសំខាន់ៗនៃភាពងាយរងគ្រោះ (២) ពិនិត្យពីគោលនយោបាយលើកិច្ចគាំពារខាងសង្គមកិច្ចដែលមានស្រាប់ និងសកម្មភាពផ្សេងៗ ដែលរាជរដ្ឋាភិបាលកម្ពុជា និងដៃគូនានាបានអនុវត្ត (៣) ពិភាក្សាពីប្រសិទ្ធភាពនៃកម្មវិធីគាំពារសង្គមកិច្ចដែលមានស្រាប់ និង (៤) លើកជាជម្រើសគោលនយោបាយសម្រាប់ជួយក្រុមជនងាយរងគ្រោះ ដែលជាប់ទាក់ទងនឹងកំណើនប្រាក់ចំណូល ការគាំពារសង្គម និងចន្លោះខ្វះខាតខាងចំណេះដឹង ។

## ទំនាក់ទំនងរវាង កំណើនសេដ្ឋកិច្ច ភាពក្រីក្រ និងភាពងាយរងគ្រោះ

ភាពក្រីក្រនៅកម្ពុជា មានលក្ខណៈសំគាល់ជាចំណាយប្រើប្រាស់ និងប្រាក់ចំណូលកម្រិតទាប ស្ថានភាពអាហារូបត្ថម្ភអន់ខ្សោយ ការអប់រំកម្រិតទាប កង្វះលទ្ធភាពបានប្រើប្រាស់សេវាសាធារណៈ

ក្រាហ្វិក ១៖ កំណើន ផសស (1994-2013 គិតតាមកម្រិតថ្លៃឆ្នាំ2000)




*ប្រភព៖ ទិន្នន័យពី MoEF*[2]

ក្រាហ្វិក ២៖ ប្រភពកំណើនតាមវិស័យ (1994-201




*ប្រភព៖ ទិន្នន័យពី MoEF*

និងឱកាសសេដ្ឋកិច្ច ភាពងាយរងគ្រោះពីហានិភ័យ និងការផាត់ចេញពីសកម្មភាពនយោបាយ សង្គម និងសេដ្ឋកិច្ច ។ អត្រាកំណើន ផសស មធ្យមប្រចាំឆ្នាំនៅកម្ពុជា ដល់ទៅ ៩,៥% នៅឆ្នាំ១៩៩៩-២០០៨ (ក្រាហ្វិក ១) បានធ្វើឲ្យកម្ពុជាមានការផ្លាស់ប្ដូរយ៉ាងជ្រាលជ្រៅ ហើយសង្គមជាតិក៏បានដាក់អនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងសម្រេចបានការកាត់បន្ថយភាពក្រីក្រ ការកែលំអជីវភាពរស់នៅ ការលើកកំពស់កម្រិតអប់រំ និងស្ថានភាពសុខភាពប្រសើរជាងមុន ។ ប៉ុន្តែកំណើនសេដ្ឋកិច្ចភាគច្រើនមានមូលដ្ឋាននៅតំបន់ទីក្រុង ហើយការបែងចែកផលប្រយោជន៍នៃកំណើន មានលក្ខណៈមិនស្មើគ្នា ដែលនាំឲ្យមានវិសមភាពកាន់តែធំឡើង (ធនាគារពិភពលោកឆ្នាំ២០០៧)[៣] ។

---

១ លោក គឹម សុធន ជាអ្នកស្រាវជ្រាវ និង លោកស្រី ខៀវ ភិរម្យ ជាជំនួយការស្រាវជ្រាវ នៃកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃវិទ្យាស្ថាន CDRI ។ អ្នកនិពន្ធ សូមថ្លែងអំណរគុណ កញ្ញា ហ្គូវ គីមហុង និង លោក ឈឹម ឈន់ ដែលបានជួយស្វែងរកឯកសារយោង ។

២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣ ផសស ក្នុងមនុស្សម្នាក់ កើនពី ២៨៥ដុល្លារ នៅឆ្នាំ១៩៩៧ ដល់ ៥៩៣ដុល្លារ នៅឆ្នាំ២០០៧ (ទិន្នន័យពីមូលនិធិ IMF) ។ ការវាយតម្លៃនិន្នាការភាពក្រីក្ររបស់ធនាគារពិភពលោកក្នុងឆ្នាំ២០០៩ បង្ហាញថា មេគុណ Gini(ការវាស់វែងវិសមភាពចំណូល) សម្រាប់ប្រទេសកម្ពុជាទាំងមូល បានកើនយ៉ាងលឿនពី ០,៣៩៦ នៅឆ្នាំ២០០៤ ដល់ ០,៤៣១ នៅឆ្នាំ២០០៧ ។

ក្រាហ្វិក ៣៖ របាយអត្រាគ្រួសារក្រីក្រ (គិតជា %) នៅតាមស្រុក ឆ្នាំ២០០៩



*ប្រភព៖ ទិន្នន័យតាមឃុំ ២០០៣-២០០៨ ក្រសួងផែនការ គូសផែនទីដោយ NCDD PST M&E unit ឆ្នាំ២០០៩*

ក្រាហ្វិក ៤៖ តំបន់អសន្តិសុខស្បៀង




*ប្រភព៖ FAO 2007*

វិសមភាពធំបង្កឧបសគ្គដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រារាំងដល់កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងអាចធ្វើឲ្យខូចខាតដល់កំណើនសេដ្ឋកិច្ចផង និងនាំអោយមានអស្ថិរភាព និងភាពបាក់បែកក្នុងសង្គមផង (ធនាគារពិភពលោក ២០០៦ក)។ ប្រទេសកម្ពុជាមានប្រជាជនសរុប ១៣,៤លាននាក់ ក្នុងនោះ មាន ៨០% ពឹងផ្អែកលើសេដ្ឋកិច្ចជនបទ ដែលមានកំណើនទាប និងមិនគ្រប់គ្រាន់ទេ (ក្រាហ្វិក ២)[៤] ។ កំណើនតាមលំនាំនេះ កន្លងមកផ្ដល់អត្ថប្រយោជន៍តិចតួចណាស់ដល់ប្រជាជនភាគច្រើន ជាពិសេសអ្នកនៅតំបន់ជនបទ ដូច្នេះប្រជាជនក្រីក្រនៅជនបទ នៅតែងាយរងគ្រោះជាខ្លាំងដោយហានិភ័យមកពីប្រភពផ្សេងៗ ។ ការសិក្សាជាច្រើនពីភាពក្រីក្របានលើកឡើងថា ការប្រឈមនឹងហានិភ័យ និងការប៉ះទង្គិចផ្សេងៗ ជាកត្តាដ៏ចំបងមួយដែលធ្វើឲ្យក្រុមគ្រួសារងាយរងគ្រោះ ត្រូវជាប់ជុង ឬធ្លាក់ខ្លួនកាន់តែជ្រៅក្នុងភាពក្រីក្រ (Fitzgerald *et al.* 2007; Ballard *et al.* 2007; So 2009; Kem *et al.* 2010) ។

៤ វិនិយោគផ្ទាល់ពីបរទេស (FDI) ប្រមូលផ្ដុំនៅក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម រីឯវិស័យកសិកម្មនៅបន្តខ្វះការវិនិយោគទុន និងមានការអភិវឌ្ឍមិនគ្រប់គ្រាន់ ។ ទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បង្ហាញថា ចំណែក ផសស នៃវិស័យកសិកម្ម បានធ្លាក់ចុះ តាំងពីឆ្នាំ១៩៩៤ មក (ក្រាហ្វិក ២) ។ នៅឆ្នាំ២០០៩ កម្ពុជាផលិតស្រូវបាន ២,៨តោន/ហិកតា ដែលជាតួលេខទាបបំផុតនៅក្នុងតំបន់ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១០) ។

៥ MPI ជាសន្ទស្សន៍ភាពក្រីក្រពហុវិស័យធ្ងន់ធ្ងរ ។ វាឆ្លុះបញ្ចាំងពីកង្វះខាតសេវាសំខាន់ៗបំផុត និងមុខងារចំបងៗនៃជីវភាពរស់នៅ ។ សន្ទស្សន៍នេះបង្ហាញពីភាពក្រីក្រតាមលំនាំផ្សេងមួយ ដោយពិនិត្យលើភាពខ្វះខាតមួយសំណុំផ្សេងទៀតក្រៅពីកង្វះខាតប្រាក់ចំណូល ។ MPI វាស់វែងលើវិស័យ ៣ គឺ សុខភាព ការអប់រំ និងកម្រិតជីវភាព ហើយប្រើសូចនាករ ១០ ដើម្បីវាស់វែងភាពក្រីក្រ ។ តាមវិធីវាស់វែងនេះ ក្រុមគ្រួសារមួយ ត្រូវកំណត់ថាជាគ្រួសារក្រីក្រពហុវិស័យ បើសិនជាបន្សំនៃសូចនាករនានាសម្រាប់ក្រុមគ្រួសារនោះ បង្ហាញនូវភាពខ្វះខាតលើសពី ៣០% ។

## អ្នកណាខ្លះជាជនងាយរងគ្រោះ? ហេតុអ្វីបានជាងាយរងគ្រោះ?

យុទ្ធសាស្ត្រជាតិលើការគាំពារសង្គម (NSPS) ដែលត្រូវដាក់អនុវត្តក្នុងពេលខាងមុខ បានកំណត់និយមន័យជនងាយរងគ្រោះថាជា (១) អ្នករស់នៅក្រោមបន្ទាត់ភាពក្រីក្រ (២) អ្នកមិនអាចទប់ទល់នឹងការប៉ះទង្គិច ឬទទួលការប៉ះទង្គិចញឹកញាប់ (អ្នកមានជីវភាពនៅក្រោម ឬនៅជិតបន្ទាត់ភាពក្រីក្រ ច្រើនតែជាជនងាយរងគ្រោះបំផុត) និង (៣) ទារក កុមារ នារីក្នុងវ័យបន្តពូជ គ្រួសារមានអសន្តិសុខស្បៀង ជនជាតិភាគតិច ជនចាស់ជរា អ្នកឈឺរ៉ាំរ៉ៃ អ្នកផ្ទុកមេរោគអេដស៍ និងជនពិការ ។ ដោយប្រើនិយមន័យនេះ គេអាចកំណត់បាននូវ ក្រុមជនងាយរងគ្រោះ ព្រមទាំង កត្តា និងមូលហេតុដែលបង្កភាពងាយរងគ្រោះ ។

### ប្រជាជនជាង ២៥% រស់នៅក្រោមបន្ទាត់ភាពក្រីក្រ

គេប៉ាន់ស្មានថា នៅចុងឆ្នាំ២០០៩ មានគ្រួសារកម្ពុជា ២៧,៤% កំពុងរស់នៅក្រោមបន្ទាត់ភាពក្រីក្រ (ក្រសួងផែនការ ២០០៩) ។ ប៉ុន្តែបើសិនគិតតាមសន្ទស្សន៍ភាពក្រីក្រពហុវិស័យ (MPI)[៥] នោះ អត្រាភាពក្រីក្រនៅកម្ពុជា ត្រូវកើនដល់ ៥៤% ដែលតំណាងឲ្យប្រជាជនប្រហែល ៧,៧លាននាក់ (Alkire *et al.* 2010) ។ សន្ទស្សន៍ភាពក្រីក្រ គិតតាមការរាប់ចំនួនប្រជាជនក្នុងអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ បង្ហាញថា អត្រាភាពក្រីក្រ គឺ ០,៨៣ នៅទីក្រុងភ្នំពេញ និង ២១,៨៥ នៅតំបន់ទីក្រុងដទៃទៀត ដែលបញ្ជាក់ថា ប្រជាជនក្រីក្រ ៧,៨% នៅកម្ពុជា កំពុងរស់នៅតំបន់ទីក្រុង (ធនាគារពិភពលោក ២០០៩) ។ នៅតំបន់ជនបទវិញ គ្រួសារក្រីក្រភាគច្រើនរស់នៅតាមខេត្តឆ្ងាយៗ ដូចជា រតនគិរី មណ្ឌលគិរី ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងខេត្តខ្លះទៀតនៅជុំវិញវាលទំនាបបឹងទន្លេសាប ដូចជាខេត្តកំពង់ធំ សៀមរាប ពោធិ៍សាត់ (ក្រាហ្វិក ៣) ។ ការសិក្សាមួយ

របស់អង្គការស្បៀងអាហារ និងកសិកម្ម (FAO) នៅឆ្នាំ២០០៧ បានរកឃើញថា ខេត្តទាំងនេះជាតំបន់អសន្តិសុខស្បៀង[៦] (ក្រាហ្វិក ៤) ដោយមានប្រជាជន ២,៦លាននាក់ កំពុងប្រឈមមុខនឹងកង្វះខាតស្បៀងអាហារ (កម្មវិធីស្បៀងអាហារពិភពលោក ២០០៧) ។ គិតតាមតួលេខខាងលើនេះ អង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា រកឃើញថា ៤៣% នៃកុមារអាយុពី ០-៥ឆ្នាំ រងគ្រោះដោយកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (ក្រិន) ២៨% មានសភាពស្គមស្គាំង និង ៨% មានកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ។ នៅឆ្នាំ២០០៩ កម្ពុជា មានសន្ទស្សន៍ភាពអត់ឃ្លានសាកល (GHI)[៧] ដល់ ២១,២ ដែលជាអត្រាខ្ពស់គួរឲ្យបារម្ភ ទោះបីកម្ពុជាតែងមានប្រវត្តិផលិតស្រូវអង្ករបានគ្រប់គ្រាន់ក៏ដោយ ។ ជនក្រីក្រ គឺងាយរងគ្រោះខ្លាំងពីហានិភ័យជាលក្ខណៈបុគ្គល ឬជាលក្ខណៈសាកល ឬទាំងពីរមុខ[៨] ។ ហានិភ័យជាលក្ខណៈបុគ្គល ដែលតែងជួបប្រទះ រួមមាន ជំងឺមិនឆ្លងរាតត្បាត គ្រោះថ្នាក់ សមាជិកគ្រួសារស្លាប់ ការបាត់បង់សត្វចិញ្ចឹម បំណុល ចោរកម្ម អំពើហិង្សា ការខូចខាតដំណាំក្នុងកម្រិតគ្រួសារ បរាជ័យក្នុងអាជីវកម្ម ការប៉ះទង្គិចចំណូលគ្រួសារដោយសារការបាត់បង់ការងារ ឬការថយចុះប្រាក់ចំណូលជាដើម ។ ចំពោះហានិភ័យជាលក្ខណៈសាកល ដូចជា គ្រោះធម្មជាតិ (ឧ. ទឹកជំនន់ ការរាំងស្ងួត) ជម្ងឺរាតត្បាត ជម្លោះក្នុងសង្គម (ទំនាស់ដីធ្លី ការថយចុះស្តុកធនធានធម្មជាតិ) និងវិបត្តិសេដ្ឋកិច្ច ជាដើម វាតែងប៉ះពាល់ដល់ជនក្រីក្រធ្ងន់ធ្ងរ ជាងក្រុមផ្សេងៗទៀតនៅក្នុងសង្គម ។

ក្រុមជនងាយរងគ្រោះក្នុងសង្គម មានជាអាទិ៍ (១) ប្រជាជនក្រីក្រនៅទីក្រុង (២) អ្នកផ្ទុកវីរុសអេដស៍ និងមានជម្ងឺអេដស៍ (៣) កុមារ និងយុវជន (៤) មនុស្សចាស់ជរា (៥) ជនពិការ (៦) ជនជាតិភាគតិច និង (៧) គ្រួសារមានស្ត្រីជាមេគ្រួ និងនារីក្នុងវ័យបន្តពូជ ។ ក្រុមនេះ បានទទួលរងក្នុងកម្រិតខុសៗគ្នានូវហានិភ័យជាលក្ខណៈបុគ្គល ឬសាកល ឬក៏ទាំងពីរមុខ ។

ការសិក្សារបស់ធនាគារពិភពលោក ស្តីពី "ហានិភ័យ និងភាពងាយរងគ្រោះនៃប្រជាជនកម្ពុជា" (២០០៦ខ) បានប្រៀបធៀបភាពងាយរងគ្រោះនៃក្រុមនីមួយៗ ដោយផ្អែកលើភាពងាយប៉ះពាល់ពីហានិភ័យ និងសមត្ថភាពដោះស្រាយហានិភ័យទាំងនោះ ។ ការសិក្សាបង្ហាញថា ក្រុមកុមារ និងយុវជន មានទំហំធំជាងគេ ក្នុងចំណោមក្រុមជនងាយរងគ្រោះទាំងអស់ មានស្ថានភាពអាហារូបត្ថម្ភអន់ខ្សោយ ត្រូវធ្វើការងារក្នុងប្រភេទយ៉ាប់យ៉ឺនបំផុត មានការអប់រំទាប ខ្វះខាតជំនាញ និងឱកាសទទួលបានការងារសមរម្យ ។ ជនពិការ និងជនក្រីក្រនៅទីក្រុង ស្ថិតនៅលំដាប់ទីពីរ និងទីបី ក្នុងចំណាត់ថ្នាក់ភាពងាយរងគ្រោះ និងលទ្ធភាពគ្រប់គ្រងហានិភ័យ ហើយបន្ទាប់មក គឺ ក្រុមចាស់ជរា ជនជាតិភាគតិច និងគ្រួសារមានស្ត្រីជាមេគ្រួ ។ ការសិក្សាដោយ So (2009), Kem *et al.* (2010) និង Ngo *et al.* (2010) បានបង្ហាញដែរថា ដោយសារលទ្ធភាពទាបក្នុងការដោះស្រាយហានិភ័យពីវិបត្តិសេដ្ឋកិច្ច ក្រុមជនងាយរងគ្រោះ និងគ្រួសាររបស់ពួកគេ ជាពិសេសគ្រួសារមានស្ត្រីជាមេគ្រួ កាន់តែងាយរងគ្រោះពីការប៉ះពាល់ដល់ចំណូល និងចំណាយប្រើប្រាស់ ដែលរុញច្រានពួកគេឲ្យជាប់ផុងកាន់តែជ្រៅទៅក្នុងភាពក្រីក្រ ។ ដូច្នេះយុទ្ធសាស្ត្រណាដែលអាចជួយកាត់បន្ថយភាពងាយរងគ្រោះ និងហានិភ័យពីវិបត្តិនានា ឲ្យក្រុមជនងាយរងគ្រោះបំផុតនោះ សុទ្ធតែអាចចាត់ទុកជាយុទ្ធសាស្ត្រដ៏សមស្របសម្រាប់ប្រយុទ្ធនឹងភាពក្រីក្រ និងជម្រុញកំណើនឲ្យមានចីរភាព និងសមធម៌ ។

### កិច្ចគាំពារសង្គមកិច្ច និងការកាត់បន្ថយភាពងាយរងគ្រោះ

កិច្ចគាំពារសង្គមកិច្ច ពេលខ្លះគេប្រើវាជា "ប្រព័ន្ធ" មួយសម្រាប់ដោះស្រាយភាពងាយរងគ្រោះ ទាំងជាលក្ខណៈបុគ្គល និងលក្ខណៈសាកល (Davies *et al.* 2008; Vakis 2006) ។ នាបច្ចុប្បន្ន ការដាក់អនុវត្តប្រព័ន្ធសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គមកិច្ច ដើម្បីជួយក្រុមជនងាយរងគ្រោះ បានក្លាយជាជំរើសមួយដែលមានអាទិភាពខ្ពស់ ។

រដ្ឋធម្មនុញ្ញ និងច្បាប់ជាច្រើន បានកំណត់ឲ្យរដ្ឋាភិបាលមានភារកិច្ចផ្តល់នូវប្រព័ន្ធសុវត្ថិភាពសង្គមផ្សេងៗ ជូនដល់ប្រជាជន ។ គោលដៅជាច្រើនជាប់ទាក់ទងនឹងការគាំពារសង្គមក៏មានអាទិភាពខ្ពស់ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ដែរ ។ យោងតាម NSDP ក្រសួងមន្ទីរ និងស្ថាប័នពាក់ព័ន្ធនានា ក៏បានអនុម័ត ផែនការសកម្មភាព និងគោលនយោបាយមួយចំនួន ។ កម្មវិធីគាំពារសង្គមច្រើនបែបច្រើនយ៉ាងសម្រាប់ជនក្រីក្រ ព្យាយាមដោះស្រាយបញ្ហាភាពងាយរងគ្រោះ និងការអភិវឌ្ឍធនធានមនុស្ស ។ កម្មវិធីគាំពារសង្គមចំបងៗដែលមានចែងក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រួមមាន សេវាសុវត្ថិភាពសង្គម បេឡាជាតិសម្រាប់សុវត្ថិភាពសង្គម ការបណ្តុះបណ្តាលវិជ្ជាជីវៈ អាហារូបករណ៍សម្រាប់ជនក្រីក្រ កម្មវិធីផ្តល់អាហារូបត្ថម្ភតាមសាលារៀន និងរបបយកទៅផ្ទះ មូលនិធិសមធម៌សុខភាព ការធានារ៉ាប់រងផ្អែកសុខភាពនៅតាមសហគមន៍ កម្មវិធីអាហារូបត្ថម្ភ ជំនួយសង្គ្រោះបន្ទាន់ កម្មវិធីការងារសាធារណៈ សម្បទានដីសង្គមកិច្ច ការផ្គត់ផ្គង់

---

៦ អសន្តិសុខស្បៀង កើតមាននៅពេលដែលមនុស្សខ្វះសារជាតុចិញ្ចឹម ដោយសារតែគ្មានស្បៀងអាហារ កង្វះលទ្ធភាពផ្នែកសេដ្ឋកិច្ច ឬសង្គមកិច្ចក្នុងការទទួលបានអាហារគ្រប់គ្រាន់ និងការបរិភោគអាហារមិនគ្រប់គ្រាន់ (កម្មវិធីស្បៀងអាហារពិភពលោក ឆ្នាំ២០០៥) ។

៧ នៅឆ្នាំ២០០៩ GHI របស់ប្រទេសជិតខាងកម្ពុជា គឺ វៀតណាម ១១,៩ ឡាវ ១៩,០ និង ថៃ ៨,២ ដែលសុទ្ធតែល្អជាងអត្រារបស់កម្ពុជា ។

៨ ហានិភ័យជាលក្ខណៈបុគ្គល វាប៉ះពាល់ដល់បុគ្គល ឬគ្រួសារខ្លះៗប៉ុណ្ណោះ រីឯហានិភ័យជាលក្ខណៈសាកល វាប៉ះពាល់ដល់មនុស្សច្រើនក្នុងពេលតែមួយ ។

ក្រាហ្វិក ៤៖ ចំណាយរដ្ឋាភិបាលលើការគាំពារសង្គមតាមក្រសួង (គិតជាភាគរយនៃ ផសស)




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១០*

ទឹកស្អាតនៅតំបន់ជនបទនិងអនាម័យ និងគម្រោងខ្នាតតូច ឬឥណទានខ្នាតតូច ។

ចំណាយរបស់រដ្ឋាភិបាលទៅលើការគាំពារសង្គម កើនឡើងរហូតក៏ពិតមែន ប៉ុន្តែវានៅមានកម្រិតទាប បើធៀបនឹងប្រទេសឯទៀតក្នុងតំបន់ (ក្រាហ្វិក ៥) ។ ក្នុងពេលជាមួយគ្នា ប្រាក់បើកផ្តល់ដោយដៃគូអភិវឌ្ឍន៍នានារបស់រដ្ឋាភិបាលសម្រាប់គម្រោងសុវត្ថិភាពសង្គម បានកើនដល់ ៥១លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១០ ។ ក្នុងចំណោមសរុប ១.៥០០អង្គការមិនមែនរដ្ឋាភិបាល មានជិតពាក់កណ្តាលកំពុងអនុវត្តកម្មវិធីជាប់ទាក់ទងនឹងការគាំពារសង្គម ។ ប៉ុន្តែទោះបីជាមានការប្រឹងប្រែងយ៉ាងធំធេង និងការខិតខំផ្តោតលើជនក្រីក្រក្តី ក៏ការគាំពារសង្គមនៅតែមិនទាន់បានទៅដល់ប្រជាជនមួយភាគធំ ដែលកំពុងត្រូវការជំនួយទ្រទ្រង់នៅឡើយ ។ ប្រសិទ្ធភាព និងចីរភាពនៃកម្មវិធីគាំពារសង្គមក៏បានថយចុះ ដោយសារធនធានមានកម្រិត កង្វះយុទ្ធសាស្ត្រនិងនីតិវិធីច្បាស់លាស់ និងរលូនគ្នាល្អសម្រាប់កំណត់ប្រជាជនគោលដៅ និងការកំណត់អាទិភាពនៃកម្មវិធី ដោយផ្អែកលើចំណាប់អារម្មណ៍របស់ដៃគូអភិវឌ្ឍន៍ ។

## សេចក្តីសន្និដ្ឋាន ជំរើសគោលនយោបាយ និង ទិស័យស្រាវជ្រាវជាអាទិភាពនានា សម្រាប់ការគាំពារសង្គមកិច្ចប្រកបដោយប្រសិទ្ធភាព

ភាពក្រីក្រ វិសមភាពកំណើន ការផាត់ចេញពីសង្គម និងកង្វះលទ្ធភាពទទួលបានឱកាសល្អ និងសេវាសាធារណៈ គឺជាមូលហេតុចំបងនៃភាពងាយរងគ្រោះ ។ ប្រជាជនងាយរងគ្រោះនៅកម្រិតផ្សេងៗគ្នា ទទួលរងការប៉ះទង្គិចខុសៗគ្នា ។ គេរកឃើញដូចៗគ្នាថា ក្រុមជនងាយរងគ្រោះទាំងអស់ ងាយរងការប៉ះទង្គិចណាស់ និងមានលទ្ធភាពតិចតួចក្នុងការដោះស្រាយវិបត្តិ ។ កន្លងមក មានការអនុវត្តអន្តរាគមន៍ខាងគាំពារសង្គមកិច្ចជាច្រើនបែបយ៉ាងរួចហើយ សម្រាប់កាត់បន្ថយភាពក្រីក្រ និងភាពងាយរងគ្រោះ ប៉ុន្តែវានៅមិនទាន់ច្រើនគ្រប់គ្រាន់ ដើម្បីឈោងឲ្យដល់ក្រុមធំៗនៃប្រជាជនងាយរងគ្រោះនោះទេ ។ កម្រិតកំណត់នៃកម្មវិធីគាំពារសង្គមកិច្ចទាំងនេះ អាចក្លាយជាឧបសគ្គដល់ ការរួបរួមគ្នានៅក្នុងសង្គម ការអភិវឌ្ឍធនធានមនុស្ស ការកែលំអជីវភាពរស់នៅ កំណើនមានសមធម៌និងមានមូលដ្ឋានធំទូលាយ និងគោលដៅចំបងនៃការកាត់បន្ថយភាពក្រីក្រ ។ ការស្វែងរកវិធីសាស្ត្រមួយ សម្រាប់ផ្តល់កិច្ចគាំពារសង្គមកិច្ចឲ្យបានសក្តិសិទ្ធិ វាប្រហែលគ្នានឹងការស្វែងរកវិធីសាស្ត្រសក្តិសិទ្ធិ និងគ្រប់ជ្រុងជ្រោយ សម្រាប់ដោះស្រាយភាពក្រីក្រនោះដែរ ។

ដើម្បីធានាឲ្យមានការគាំពារសង្គមកិច្ចដ៏សក្តិសិទ្ធ គួរយកចិត្តទុកដាក់លើការងារមួយចំនួនដូចតទៅ (១) ដោះស្រាយភាពក្រីក្រ និងភាពងាយរងគ្រោះនៅតំបន់ជនបទ ដោយធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ ហើយក្នុងនេះគួរផ្តល់អាទិភាពដល់ការជំរុញកំណើនវិស័យកសិកម្ម (២) ផ្តល់អាទិភាពដល់ការគាំពារសង្គមដែលនៅមានកម្រិតសព្វថ្ងៃ និងផ្តោតលើក្រុមជនមានតម្រូវការបន្ទាន់ ឬងាយរងគ្រោះបំផុត ដូចជា ពួកយុវជន ឬមនុស្សចាស់ជរា (៣) ធានាឲ្យមានការសម្របសម្រួលកាន់តែប្រសើររវាងស្ថាប័នពាក់ព័ន្ធ ឧទាហរណ៍ តាមរយៈការប្រើប្រាស់យ៉ាងពេញលេញនូវ នីតិវិធីកំណត់គោលដៅតាមលក្ខណៈរួម ដូចជា កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ID-Poor) ឬ ការប្រើវិធីសាស្ត្រផ្សេងៗ (ឧ. សន្ទស្សន៍ភាពក្រីក្រច្រើនមុខ (Multidimensional poverty index) ដើម្បីកំណត់ អ្នកទទួលផលជាដើម (៤) ធ្វើការស្រាវជ្រាវច្រើនទៀតសម្រាប់ផ្តល់ព័ត៌មានថ្មីៗទាន់ពេល ព្រមទាំងតាមដានបម្រែបម្រួល និងផលប៉ះពាល់នៃការគាំពារសង្គមកិច្ច នៅពេលអនាគត ដែលអាចក្លាយជាព័ត៌មានដ៏សំខាន់ សម្រាប់ការផ្តល់សេវាគាំពារសង្គមកិច្ចឲ្យបានសក្តិសិទ្ធិ ដើម្បីកាត់បន្ថយហានិភ័យ និងភាពងាយរងគ្រោះ ។

## ឯកសារយោង


Alkire, Sabina & Maria Emma Santos (2010), *Cambodia Country Briefing,* Oxford Poverty and Human Development Initiative (OPHI) Multidimensional Poverty Index Country Briefing Series, Oxford Poverty and Human Development Initiative website www.ophi.org.uk/policy/multidimensional-poverty-index/mpi-country-briefings/ (retrieved 27 August 2010)

Ballard, B. M. Sloth, C. Wharton, D. Fitzgerald, I. Mushid, K.A.S. Hansen, K. K. Phim, R. Lim, S. (2007), *We Are Living with Worry All the Time: A Participatory Poverty Assessment of the Tonle Sap* (Phnom Penh: Cambodia Development Resource Institute)

Davies, M. Leavy, J. Mitchell, & T. and Tanner (2008), *Social Protection and Climate Change Adaptation* (Brighton: Institute of Development Studies at the University of Sussex)

FAO (Food Agriculture Organisation) (2007), *Mapping of Food Security and Nutrition Situation and On-going Field Agent Efforts in Cambodia* (Phnom Penh: FAO)

Fitzgerald, I., So, S., Chan, S., Kem, S., & Tout, S. (2007), *Moving Out of Poverty? Trends in Community Well-being and Household Mobility in Nine Cambodian Villages* (Phnom Penh: Cambodia Development Resource Institute)

IFPRI (International Food Policy Research Institute) (2009), *Global Hunger Index: The Challenge of Hunger- Focus on Financial Crisis and Gender Inequality* (Washington DC: Dublin)

Kem, S. Theng, V. & Chhim, C. (forthcoming in 2010), *Rapid Assessment of Impact of Global Financial Crisis on Poor and Vulnerable People: Round 4* (Phnom Penh: Cambodian Development Resource Institute)

MoP (Ministry of Planning) (2009), Poverty and Select CMDGs, Maps and Charts 2003-2008, preliminary results of CDB-based Research and Analysis Project (Phnom Penh: MoP)

Ngo, S. & Chan, S. (2010), *More Vulnerable: The Implication of the Economic Downturn on Women in Cambodia* (Phnom Penh: Oxfam Research Report)

So, S. (2009), Informal *Risk Management and Safety Net Practices in Economic Crisis in Cambodia: Experiences of Poor and Vulnerable Workers and Households,* Annual Development Review, (5) (Phnom Penh: Cambodian Development Resources Institute) pp. 83-112

Vakis, R (2006), *Complementing Natural Disasters Management: The Role of Social Protection,* Discussion Paper No. 0542 (Washington, DC: World Bank)

WFP (World Food Programme) (2005), *Food Security Atlas of Cambodia* (Cambodia: World Food Programme)

World Bank (2007), *Sharing the Growth: Equity and Development Report 2007* (Phnom Penh: World Bank for the Cambodia Development Cooperation Forum)

World Bank (2009), Poverty Profile and Trend in Cambodia: Findings from the 2007 Cambodia Socio-Economic Survey (CSES) (Poverty Reduction and Economic Management Sector Unit, East Asia and Pacific Region, World Bank)

World Bank (2006a), *Cambodia: Halving Poverty by 2015? Poverty Assessment 2006* (Phnom Penh: World Bank)

World Bank (2006b), *Managing Risk and Vulnerability in Cambodia: An Assessment and Strategy for Social Protection* (Washington DC: World Bank)

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ផ្ដោតលើប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនក្នុងពិភពលោក និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ី នៅត្រីមាសទី២ ឆ្នាំ២០១០ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី២ ឆ្នាំ២០១០ ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅឥណ្ឌូនេស៊ី កើន ៦,២% ដែលជាកំណើនលឿនបំផុតគិតចាប់ពីត្រីមាសទី៣ ឆ្នាំ២០០៨ មក ។ កំណើននេះទទួលបានមួយផ្នែកមកពី កំណើនតម្រូវការខ្លាំងពីប្រទេសចិន ។ កំណើន ផសស នៅ ម៉ាឡេស៊ី ធ្លាក់ចុះមកត្រឹម ៨,៩% ស្របពេលដែល ផសស នៅ សិង្ហបុរី កើនដល់ ១៨,៧% ដែលជាកំណើនលឿនបំផុតលំដាប់ទី២ តាំងពីពេលសិង្ហបុរីចាប់ធ្វើកំណត់ត្រាកំណើនមក ។ រដ្ឋាភិបាលសិង្ហបុរី បានកែសម្រួលកំណើន ផសស នៅត្រីមាសទី១ ពី ១៦,០% ដល់ ១៧,៤% ។ កំណើន ផសស នៅ ថៃ រួមចុះមកត្រឹម ៩,១% ដោយសារបាតុកម្មប្រឆាំងរដ្ឋាភិបាល ដែលនាំឲ្យមជ្ឈមណ្ឌលពាណិជ្ជកម្មនៅក្រុងបាងកកគាំងសកម្មភាពតាំងពីខែមីនា ដល់ឧសភា ។ ផសស ពីមួយឆ្នាំទៅមួយឆ្នាំ នៅវៀតណាម កើន ៦,៤% ធៀបនឹង ៥,៨% នៅត្រីមាសទី១ ឆ្នាំ២០១០ ។ កំណើននេះ បានពីការរីកលូតលាស់វិស័យកាត់ដេរ សេវាកម្ម កសិកម្ម និង វិនិយោគបរទេសដែលរាប់បញ្ចូលទាំងឧស្សាហកម្មប្រេង និងឧស្ម័ន ផង ។

កំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ នៅ ចិន ថយចុះមកត្រឹម ១០,៣% ធៀបនឹង ១១,៩% នៅត្រីមាសទី១ ឆ្នាំ២០១០ ។ ក្នុងអត្រាកំណើននេះ ការរួមចំណែកនៃចំណាយប្រើប្រាស់ មាន ៣,៩ ឯកតាភាគរយ ការបង្កើតមូលធនជាប់លាប់ដុល មាន ៦,៦ ឯកតាភាគរយ និង ការនាំចេញសុទ្ធមាន ០,៦ ឯកតាភាគរយ ។ កំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ ថយចុះមកត្រឹម ៦,៥% នៅ ហុងកុង ៧,១% នៅ កូរ៉េខាងត្បូង និង ១១,៤% នៅ តៃវ៉ាន់ ។ កំណើន ផសស នៅ ជប៉ុន ធ្លាក់ចុះមកត្រឹម ២,៤% ប៉ុន្តែវាកើនដល់ ៣,០% នៅសហរដ្ឋអាមេរិក ដោយសារការរីកលូតលាស់យ៉ាងលឿនក្នុងការនាំចេញ កំណើនការវិនិយោគជាស្តុកទំនិញ និង ភាពប្រសើរឡើងនៃចំណាយប្រើប្រាស់សេវាកម្ម ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់អន្តរជាតិ

នៅត្រីមាសទី២ ឆ្នាំ២០១០ សំពាធបរិត្តផរណានៅតែបន្តកើតមាននៅ ជប៉ុន ស្របពេលដែលប្រទេសជាច្រើនមានកំណើនអតិផរណា ។ នៅ ឥណ្ឌូនេស៊ី អត្រាអតិផរណាកើនដល់ ៤,៤% ធៀបនឹង ៣,៣% កាលពីត្រីមាសទី១ ដោយសារស្បៀងអាហារឡើងថ្លៃក្រោយពេលផុតរដូវច្រូតកាត់ចំបង ។ ម៉ាឡេស៊ី នៅរក្សាបានអត្រាអតិផរណាទាប គឺ ១,៧% រីឯ សិង្ហបុរី មានអត្រាអតិផរណាកើនដល់ ៣,២% ធៀបនឹង ០,៩% នៅត្រីមាសមុន ។ ថ្លៃទំនិញប្រើប្រាស់នៅ ថៃ មានអតិផរណា ២,១% ចំណែកឯនៅ ចិន វាមានកំរិត ២,៧% ។ ថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំ នៅ ហុងកុង មានកំណើន ២,១% ធៀបនឹង ១,៩% នៅត្រីមាសមុន ។ កូរ៉េខាងត្បូង មានអត្រាអតិផរណា ២,៦% និង តៃវ៉ាន់ ១,១% ចំណែកឯ ជប៉ុន មានបរិត្តផរណា ០,៩% ។ អតិផរណានៅ តំបន់អឺរ៉ូ គឺ ១,៥% និង សហរដ្ឋអាមេរិក ១,៨% ។

ក្នុងអំឡុងពេលដូចគ្នា ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ឡើងថ្លៃ ១,៥% ទល់នឹងប្រាក់ដុល្លារអាមេរិក បើធៀបនឹងត្រីមាសមុន ។ ទល់នឹងប្រាក់ដុល្លារអាមេរិក ប្រាក់រីងហ្គីតម៉ាឡេស៊ី ឡើងថ្លៃ ៣,៩% ប្រាក់ដុល្លារសិង្ហបុរី ឡើងថ្លៃ ២,៩% ប្រាក់បាតថៃ ឡើងថ្លៃ ១,៧% ប្រាក់យ៉ុនចិន ឡើងថ្លៃ ០,៩% ដុល្លារតៃវ៉ាន់ ឡើងថ្លៃ ០,១% រីឯ ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ០,៩% ។ ជាមួយគ្នានេះដែរ ដុល្លារហុងកុង ធ្លាក់ថ្លៃ ០,៣% ប្រាក់វ៉ុនកូរ៉េខាងត្បូង ធ្លាក់ថ្លៃ ១,៩% ប្រាក់អឺរ៉ូ ធ្លាក់ថ្លៃ ៩,៧% និង ប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ១,៦% ។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ឆ្នាំ២០១០ ពោត និង សណ្ដែកសៀង ធ្លាក់ថ្លៃតិចតួច ធៀបនឹងត្រីមាសមុន ។ ពោត US លេខ២ ធ្លាក់ថ្លៃ ៣,៤% មកត្រឹម ១៥៧,៤ដុល្លារ/តោន ។ កៅស៊ូ ប្រភេទ SMR 5 ធ្លាក់ថ្លៃ ០,៧% មកត្រឹម ៣០៨៣,៧ដុល្លារ/តោន អង្ករ (Thai 100%) ធ្លាក់ថ្លៃ ១៨,៥% មកត្រឹម ៤៦១ដុល្លារ/តោន និង សណ្ដែកសៀង (US No.1) ធ្លាក់ថ្លៃ ០,៥% មកត្រឹម ៣៧១ដុល្លារ/តោន ។ ប្រេងនៅ ឡើងថ្លៃ ១,៧% ដល់ ៧៧ដុល្លារ/ធុង សាំង ឡើងថ្លៃ ១,០% ដល់ ០,៥៤ដុល្លារ/លីត្រ ហើយ ម៉ាស៊ូត ឡើងថ្លៃ ២,៣% ដល់ ០,៥៥ដុល្លារ/លីត្រ ។

*រៀបរៀងដោយ ស្រី បុប្ផារ័ត្ន*

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 4.4 | 3.9 | 4.2 | 5.4 | 5.7 | 6.2 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | -6.2 | -3.9 | -1.2 | 4.5 | 16.9* | 8.9 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | -10.1 | -3.5 | 0.8 | 4.0 | 17.4* | 18.7 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | -7.1 | -4.9 | -2.8 | 5.8 | 12.0 | 9.1 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | 5.8 | 6.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 6.1 | 7.9 | 9.1* | 10.7 | 11.9* | 10.3 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | -7.8 | -3.8 | -2.2 | 2.6 | 8.0* | 6.5 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | -4.4 | -2.2 | 0.4 | 6.1 | 8.1 | 7.1 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | -10.2 | -7.5 | -1.3 | 8.4* | 14.6* | 11.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | -2.5 | -4.8 | -4.7 | 0.1 | - | - |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | -9.1 | 0.6 | -4.7 | -1.4 | 4.4* | 2.4 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | -2.6 | -3.9 | -2.5 | 0.1 | 2.4* | 3.0 |

*Sources: International Monetary Fund, Economist and countries' statistic offices. * Updated data*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 8.5 | 5.6 | 2.78 | 2.6 | 3.6 | 4.4 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 3.7 | 1.3 | -2.23 | -0.2 | 1.3 | 1.7 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 2.1 | -0.5 | -0.4 | -0.3 | 0.9 | 3.2 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | -0.2 | -2.8 | -2.1 | 1.9 | 3.7 | 2.1 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 15.1 | 6.2 | 2.6 | 4.6 | 7.5 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | -0.6 | 1.5 | -1.26 | 0.7 | 2.1* | 2.7* |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 1.7 | -0.1 | -0.9 | 1.3 | 1.9 | 2.1 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 3.9 | 2.8 | 2.0 | 2.4 | 2.7 | 2.6 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 0.0 | -0.8 | -1.3 | -1.3* | 1.3* | 1.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 1.0 | 0.9 | -0.34 | 0.4 | 1.1 | 1.5 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | -0.1 | -1.0 | -2.2 | -2.0 | -1.2 | -0.9 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | -0.2 | -0.9 | -1.6 | 1.4 | 2.3 | 1.8 |

*Sources: International Monetary Fund, Economist and National Institute of Statistics. * Updated data*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១០ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.30 | 4092.50 | 4103.20 | 4062.70 | 4054.20 | 4108.00 | 4128.60 | 4164.40 | 4163.10 | 4180.11 | 4209.02 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938.00 | 9705.00 | 9134.00 | 9419.00 | 9699.00 | 11,630.80 | 10,225.00 | 9887.00 | 9472.44 | 9266.93 | 9,132.00 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.70 | 3.30 | 3.30 | 3.60 | 3.50 | 3.50 | 3.40 | 3.37 | 3.24 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.51 | 1.45 | 1.44 | 1.39 | 1.40 | 1.36 |
| ថៃ (បាត) | 40.20 | 40.20 | 37.90 | 32.22 | 33.36 | 35.29 | 33.98 | 33.96 | 33.30 | 32.90 | 32.33 |
| វៀតណាម (ដុង) | 15,777.00 | 15,859.00 | 15,994.00 | 16,030.00 | 16,382.00 | 16,954.00 | 17,801.00 | 17,841.00 | 18,472.00 | 18,825.67 | 18,993.00 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.84 | 6.83 | 6.83 | 6.83 | 6.83 | 6.77 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.80 | 7.78 | 7.75 | 7.75 | 7.75 | 7.75 | 7.76 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145.00 | 1024.00 | 955.00 | 929.04 | 1137.23 | 1412.50 | 1273.90 | 1239.04 | 1167.77 | 1143.97 | 1166.04 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.60 | 32.10 | 32.50 | 32.85 | 31.54 | 34.00 | 33.10 | 32.77 | 32.29 | 31.93 | 31.90 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.70 | 0.84 | 0.76 | 0.71 | 0.70 | 0.68 | 0.72 | 0.79 |
| ជប៉ុន (យ៉េន) | 108.20 | 110.20 | 116.40 | 117.80 | 102.46 | 93.72 | 95.95 | 93.58 | 89.78 | 90.73 | 92.20 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០១០(មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 183.12 | 171.16 | 146.85 | 168.13 | 162.88 | 157.41 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 636.53 | 719.35 | 659.16 | 732.33 | N/A | N/A |
| កៅស៊ូ SMR 5 | 1276.90 | 1430.50 | 1996.30 | 2202.30 | 2586.30 | 1439.77 | 1638.77 | 1924.80 | 2536.03 | 3105.90 | 3083.73 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 522.13 | 499.45 | 307.31 | 569.00 | 565.67 | 461.33 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 434.40 | 420.10 | 411.18 | 390.43 | 372.68 | 370.95 |
| ប្រេងឆៅ - OPEC spot (USD/តោន) | 33.50 | 50.14 | 61.58 | 69.25 | 95.44 | 42.34 | 57.46 | 68.32 | 73.86 | 75.73 | 77.00 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.90 | 42.19 | 47.70 | 53.58 | 62.22 | 31.97 | 43.11 | 46.92 | 49.64 | 53.87 | 54.43 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.20 | 34.17 | 40.51 | 46.46 | 51.03 | 53.87 | 55.13 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ឆ្នាំ២០១០ អនុមតិវិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ ធ្លាក់ចុះ ៥៧% ។ វិស័យកសិកម្ម ធ្លាក់ចុះ ៧៥% ធៀបនឹងត្រីមាសមុន មកត្រឹម ៤១,៤លានដុល្លារ ហើយវិស័យឧស្សាហកម្ម ធ្លាក់ចុះ ៧៨% មកត្រឹម ៥៤,៥លានដុល្លារ ប៉ុន្តែ វិស័យសេវាកម្ម កើនឡើង ៣៦% ។ នៅត្រីមាសដដែល តម្លៃនៃអនុមតិគម្រោងសាងសង់ កើនឡើងមួយជាបី ដល់ ២០២,១លានដុល្លារ ។ ធៀបនឹងត្រីមាសមុន អនុមតិគម្រោងសាងសង់ភូមិគ្រឹះ និងផ្ទះ កើនឡើង ៤៧% អនុមតិគម្រោងផ្សេងៗ កើនឡើង ៩២% និង អនុមតិគម្រោងសាងសង់ផ្ទះល្វែង កើនឡើង ១០៤៦% ។ ប្រសិនបើគម្រោងទាំងអស់បានអនុវត្តពេញលេញ គេត្រូវការកម្លាំងពលកម្មសរុបប្រមាណ ២៣.៨៤៦នាក់ ។

នៅត្រីមាសទី២ ចំនួនភ្ញៀវមកដល់កម្ពុជាសរុប ធ្លាក់ចុះ ២១% មកត្រឹម ៥៣៧.៤៦៥នាក់ ធៀបនឹងត្រីមាសមុន ។ ភ្ញៀវមកសម្រាកលំហែ ធ្លាក់ចុះ ២២% មកត្រឹម ៤៦៥.៨៣០នាក់ ភ្ញៀវមកធ្វើជំនួញ ធ្លាក់ចុះ ២,០% មកត្រឹម ៣៥.២០៣នាក់ និង ភ្ញៀវមកផ្សេងៗទៀត ធ្លាក់ចុះ ២៤% មកត្រឹម ៣៦.៤៣២នាក់ ។ ក្នុងចំណោមភ្ញៀវមកពីប្រទេសអាស៊ាន ភ្ញៀវវៀតណាម កើនឡើង ៣៣% ធៀបនឹងត្រីមាសមុន ដល់ ១២២.៩៨១នាក់ និងបានកើនឡើងចំនួន ៦ត្រីមាសជាបន្តបន្ទាប់មកហើយ ។ ភ្ញៀវថៃ កើនដល់ ២២.២៧០នាក់ ហើយភ្ញៀវម៉ាឡេស៊ី កើនដល់ ២០.៣៨២នាក់ ។

នៅអំឡុងពេលដដែល ការនាំចេញផលិតផលសំលៀកបំពាក់ កើនឡើង ១៧% ធៀបនឹងត្រីមាសមុន ដល់ ៥០៥,៤លានដុល្លារ ដោយសារការនាំចេញទៅ "ប្រទេសផ្សេងៗ" កើន ២៨% ដល់ ១១២លានដុល្លារ ការនាំចេញទៅប្រទេសជប៉ុន កើន ២៥% ដល់ ៥៤,៨លានដុល្លារ ការនាំចេញទៅអឺរ៉ុប កើន ១៣% ដល់ ១១៥,៩លានដុល្លារ និងការនាំចេញទៅសហរដ្ឋអាមេរិក កើន ១១% ដល់ ៨៥,២លានដុល្លារ ។ ការនាំចេញទៅប្រទេសអាស៊ាន ធ្លាក់ចុះ ១២% មកត្រឹម ៣៧,៥លានដុល្លារ ។ ការនាំចេញផលិតផលកសិកម្មសរុប ធ្លាក់ចុះ ៧៨% ធៀបនឹងត្រីមាសមុន ដោយការនាំចេញកៅស៊ូ ធ្លាក់ចុះ ៦២% ការនាំចេញឈើ ធ្លាក់ចុះ ៧៩% ការនាំចេញត្រី ធ្លាក់ចុះពី ០,៨១លានដុល្លារ ដល់ ០,៥៦លានដុល្លារ ។ ប៉ុន្តែការនាំចេញផលិតផលកសិកម្មផ្សេងៗ នៅនឹងដដែល នៅត្រីមាសទី២ ការនាំចូលសាំង រួមចុះ ២១% មកត្រឹម ១៧,៣លានដុល្លារ ហើយការនាំចូលសម្ភារៈសំណង់ រួមចុះ ៦,៩% មកត្រឹម ១៣,៥លានដុល្លារ ។ ការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ៤,០% ធៀបនឹងត្រីមាសមុន មកត្រឹម ៥៣,២លានដុល្លារ ហើយការនាំចូលដែកថែប ធ្លាក់ចុះ ៤,៧% មកត្រឹម ៧,២លានដុល្លារ ។ ការនាំចូលក្រណាត់ កើន ៤៩% ដល់ ១៧,៨លានដុល្លារ ប៉ុន្តែការនាំចូលត្រាក់ទ័រ ធ្លាក់ចុះ ១៣% មកត្រឹម ២,៥លានដុល្លារ ។ ការនាំចូលជី ធ្លាក់ចុះ ៣,០% មកត្រឹម ១៣,១លានដុល្លារ ប៉ុន្តែការនាំចូលម៉ាស៊ូត កើន ១០,១% ដល់ ៤៩,៦លានដុល្លារ ហើយការនាំចូលផ្សេងៗ កើន ៦២,៥% ដល់ ៩៤,៤លានដុល្លារ ។

## ហិរញ្ញវត្ថុសាធារណៈ

ចំណូលចរន្ត ធ្លាក់ចុះ ១៣% ធៀបនឹងត្រីមាសមុន ។ ការប្រមូលចំណូលពន្ធ កើនឡើង ៤,៥% ប៉ុន្តែការប្រមូលចំណូលមិនមែនពន្ធ ធ្លាក់ចុះ ៥៧% ។ ចំណូលមូលធន ធ្លាក់ចុះ ១,៩% ប៉ុន្តែចំណាយមូលធន កើនឡើង ១៤២% ធៀបនឹងត្រីមាសមុន ហើយចំណាយចរន្ត កើនឡើង ៤០% ។ ចំណាយលើបៀវត្សរ៍ កើនឡើង ៤៦% ចំណាយលើប្រាក់បំពេញខាត និងប្រាក់ឧបត្ថម្ភខាងសង្គមកិច្ច កើនឡើង ១៩% ប៉ុន្តែចំណាយចរន្តផ្សេងៗ ធ្លាក់ចុះ ១៨% ។ ហិរញ្ញប្បទានបរទេស កើនឡើង ១៧៦% ខណៈដែលហិរញ្ញប្បទានក្នុងស្រុក រួមចុះ ៥៤% ។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

នៅត្រីមាសទី២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំ កើនឡើង ៤,១% ដោយកម្រិតថ្លៃស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា កើនឡើង ៣,៦% ហើយថ្លៃដឹកជញ្ជូន កើនឡើង ៨,៧% ។ នៅត្រីមាសដដែល ប្រាក់រៀល ធ្លាក់ថ្លៃ ០,៧% ទល់នឹងប្រាក់ដុល្លារ និង ២,៣% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែឡើងថ្លៃ ០,៩% ទល់នឹងប្រាក់ដុងវៀតណាម ។ មាសឡើងថ្លៃ ៦,៧% ដោយលក់បាន ១៤២,៩ដុល្លារក្នុងមួយជី ។ ម៉ាស៊ូតឡើងថ្លៃ ៦,៥% ដល់ ៣៨៣៥រៀល/លីត្រ ហើយសាំង ឡើងថ្លៃ ៤,៧% ដល់ ៤៣៥៨រៀល/លីត្រ ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី២ រូបិយវត្ថុទូទៅ (M2) កើនដល់ ១៨.២៦៧ពាន់លានរៀល ធៀបនឹង ១៧.២៣៤ពាន់លានរៀល នៅត្រីមាសមុន ។ ប្រាក់រៀលចរាចរ ធ្លាក់ចុះ ២,៨% មកត្រឹម ២៩៤២ពាន់លានរៀល ហើយបញ្ញើជាប្រាក់រៀល កើន ៤៣% ដល់ ១៧៣ពាន់លានរៀល ។ នៅអំឡុងពេលដដែល បញ្ញើជារូបិយវត្ថុបរទេស កើន ៧,៥% ដល់ ១៤.៧៨៧ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៦,២% ដល់ ១៦.៤៨២ពាន់លានរៀល ដោយសារទ្រព្យសកម្មបរទេស កើន ១,០% ដល់ ១៨.៤៨៧ពាន់លានរៀល ហើយបំណុលបរទេស កើន ៦,០% ដល់ ២០០៦ពាន់លានរៀល ។ ទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ៣,៨% ដល់ ១៧៨៥ពាន់លានរៀល ។ ឥណទានក្នុងស្រុក កើនដល់ ៩៤៩៩ពាន់លានរៀល ហើយបំណុលផ្សេងៗ កើនដល់ ៧៧១៣ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

នៅខែសីហា ២០១០ អង្កេតរបស់ CDRI បានរកឃើញថា ពលករ ៧ក្រុម ក្នុងចំណោម ១០ក្រុម មានប្រាក់ចំណូលប្រចាំថ្ងៃពិតកើនឡើង ធៀបនឹងខែសីហា ២០០៩ ។ ស្ថានភាពរបស់អ្នកជាក់ស៊ីក្លូ អ្នកលីសែង អ្នកបម្រើភោជនីយដ្ឋាន អ្នកលក់បន្លែតូចតាច អ្នករត់ម៉ូតូឌុប អ្នកស៊ីឈ្នួលធ្វើស្រែ និងកម្មកររោងចក្រកាត់ដេរ បានល្អប្រសើរឡើង ប៉ុន្តែបីក្រុមផ្សេងទៀតមានប្រាក់ចំណូលប្រចាំថ្ងៃពិតធ្លាក់ចុះ ។

ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមរបស់អ្នកជាក់ស៊ីក្លូ កើន ៨,៥% ធៀបនឹងខែសីហាឆ្នាំមុន ដល់ ៨៣៩៣រៀល ។ អ្នកជាក់ស៊ីក្លូ មាន ៨៧% មកពីតាមបណ្តាខេត្ត ។ ពួកគេភាគច្រើនចំណាយពេល ៦ខែក្នុងមួយឆ្នាំ ប្រកបរបរជាអ្នកជាក់ស៊ីក្លូបន្ទាប់ពីផុតរដូវធ្វើស្រែ ។ ចំណាយជាមធ្យមសម្រាប់ជីវភាពប្រចាំថ្ងៃរបស់អ្នកជាក់ស៊ីក្លូ បានកើន ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ដល់ ៤៨២២រៀល ។ ពួកគេសន្សំប្រាក់បាន ៣០០០រៀលក្នុងមួយថ្ងៃ ដើម្បីឧបត្ថម្ភគ្រួសារ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់អ្នកលក់បន្លែតូចតាច កើន ០,៧% ធៀបនឹងឆ្នាំមុន មកដល់ ៨៣៨០រៀល ។ អង្កេតនានា ចាប់ពីខែវិច្ឆិកា ២០០៩ មក បង្ហាញថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាច បានកើនឡើងជាប់រហូត ។ ប៉ុន្តែ អ្នកលក់បន្លែតូចតាច ៦៧% ខ្ចះដើមទុនសម្រាប់ដំណើរការលក់ដូរ ដែលនាំឱ្យពួកគេត្រូវធ្លាក់ខ្លួនជំពាក់បំណុល ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករត់ម៉ូតូឌុបកើន ១០,២% ធៀបនឹងខែសីហាឆ្នាំមុន មកដល់ ១០.៥៤៤រៀល ។ ជាទូទៅ អ្នករត់ម៉ូតូឌុប ចំណាយ ៥០០០រៀលលើចំណីអាហារ និងតែងផ្ញើប្រាក់ទៅឧបត្ថម្ភគ្រួសារ ។ សម្រាប់ប្រាក់សន្សំដែលពួកគេផ្ញើទៅផ្ទះ អ្នករត់ម៉ូតូឌុប ៧០% និយាយថា គឺសម្រាប់តែចំណាយលើចំណីអាហារ ចំណែកឯ ១៩% បានរាយការណ៍ថា សម្រាប់ដំណើរការមុខរបរអាជីវកម្ម ៣% ទៀតប្រាប់ថា សម្រាប់សងបំណុល និង ៨% ទៀតបញ្ជាក់ថា សម្រាប់ចំណាយលើការសិក្សា ។ អ្នករត់ម៉ូតូឌុប ៥២% បានរាយការណ៍ទៀតថា ស្ថានភាពរស់នៅរបស់ខ្លួនប្រែប្រួលប្រសើរឡើង ចាប់តាំងពីបានប្រកបរបរជាអ្នករត់ម៉ូតូឌុប ២៨% ប្រាប់ថា ស្ថានភាពរស់នៅគ្មានប្រែប្រួលហើយ ២០% បញ្ជាក់ថា ស្ថានភាពរស់នៅរឹតតែលំបាក ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យមរបស់អ្នករើសអេតចាយធ្លាក់ចុះ ៩% ធៀបនឹងខែសីហាឆ្នាំមុន មកត្រឹម ៦៤៧០រៀល ។ អ្នកសម្ភាសន៍ ៩០% បានរាយការណ៍ថា ប្រាក់ចំណូលធ្លាក់ចុះដោយសារចំនួនអ្នករើសអេតចាយកើនឡើង ហើយរបស់អេតចាយធ្លាក់ថ្លៃ ។ អ្នករើសអេតចាយ ៨៧% មិនបានសន្សំប្រាក់ទេ ដោយសាររកចំណូលបានត្រឹមមួយថ្ងៃហូបមួយថ្ងៃប៉ុណ្ណោះ ។ អ្នករើសអេតចាយ ៧៥% រាយការណ៍ថា គ្រួសាររបស់ខ្លួនត្រូវជំពាក់បំណុលគេ ដោយសារខ្វះចំណីអាហារ ឬមានជម្ងឺ ។ អ្នករើសអេតចាយ ៨៤% មកពីតំបន់ជនបទ ហើយ ៦៧% នៃអ្នករើសអេតចាយទាំងអស់ គ្មានដីធ្លីទេ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ១,៦% ធៀបនឹងខែសីហា ២០០៩ មកត្រឹម ១១.៧២២រៀល ។ កម្មករអ្នកឆ្លើយសម្ភាសន៍ ៦០% រាយការណ៍ថា ប្រាក់ចំណូលធ្លាក់ចុះ ដោយសារកំណើនចំនួនកម្មករសំណង់មានជំនាញ ។ បន្ទាប់ពីបានចំណាយ ៤៣០០រៀលក្នុងមួយថ្ងៃទៅលើចំណីអាហារ កម្មករសំណង់មានជំនាញ អាចសន្សំបាន ១៦៨.០០០រៀលក្នុងមួយខែ សម្រាប់ផ្ញើទៅផ្ទះ ។ អ្នកឆ្លើយសម្ភាសន៍ ៥៧% និយាយថា ជីវភាពគ្រួសាររបស់ខ្លួនប្រែប្រួលប្រសើរឡើង ចាប់តាំងពីបានមកធ្វើការនៅភ្នំពេញ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតជាមធ្យម របស់កម្មកររោងចក្រកាត់ដេរ កើនឡើង ១៤,៣% ធៀបនឹងខែសីហាឆ្នាំមុន ដោយសារជាសំខាន់ ចំនួនម៉ោងធ្វើការបានកើនឡើងពី ៥៣ម៉ោង ដល់ ៦០ម៉ោងក្នុងមួយសប្តាហ៍ ។ ម្យ៉ាងទៀត កម្មកររោងចក្រកាត់ដេរ ៥០% រាយការណ៍ថា ប្រាក់ចំណូលបានកើនឡើង ធៀបនឹងឆ្នាំ២០០៨ និងមាន ១៨% រាយការណ៍ថា ប្រាក់ចំណូលនៅដដែល ហើយ ១៩% ទៀត មិនដឹងច្បាស់ទេ និង ១៣% ទៀត រាយការណ៍ថា ប្រាក់ចំណូលធ្លាក់ចុះ ។ កម្មកររោងចក្រកាត់ដេរ បានកើនចំណាយលើចំណីអាហារ ២៥% ដល់ ៥៨០០រៀលក្នុងមួយថ្ងៃ ប៉ុន្តែនៅសន្សំបានជាមធ្យម ៥២.៦០០រៀលក្នុងមួយខែ សម្រាប់ផ្ញើទៅផ្ទះវិញ ។

*រៀបចំដោយ*

*ស្រ៊ី បុប្ផារ័ត្ន និង*
*ប៊ុន ដូរីណា*


### Cambodia Development Review—2010 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........................

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒Other ..........................
First name: .................. Last name: .................. Position: ..................
Organisation / Company: ..........................
Address (CCC Box if applicable): ..........................
City / Province: .................. Country: ..................
Telephone: .................. Fax: ..................
e-mail: .................. ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 135.6 | 92 | 175.3 | 0.0 | 176.1 | 94.4 | 165.7* | 41.4 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 709.1 | 724.9 | 257.7 | 39.4 | 60.6 | 685.5 | 247.7 | 54.5 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *170.7* | *142.8* | *16.4* | *35.0* | *21.9* | *14.2* | *13.1* | *21.3* |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 1742.5 | 10003.2 | 495.6 | 0.0 | 150.2 | 3475.8 | 89.5 | 121.6 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *1048.3* | *8758.1* | *254.1* | *0.0* | *150.2* | *0.0* | *3.78* | *14.0* |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 2587.2 | 10570.9 | 928.6 | 39.4 | 386.3 | 4255.7 | 502.9 | 217.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | -41.2 | -95.7 | 882.0 | 1001.7 | -91.2 | -56.8 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | -32.0 | 308.6 | 266.5 | -99.0 | -91.5 | 169.3 | -59.8 | 452.0 |

*Including expansion project approvals. Source: Cambodian Investment Board. *Updated data*

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 79.1 | 154.7 | 32.1 | 6.7 | 2.2 | 9.8 | 5.1 | 7.5 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 297.2 | 221.6 | 95.2 | 18.9 | 6.3 | 28.0 | 11.1 | 127.2 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 259.6 | 740.9 | 53.7 | 36.7 | 12.2 | 29.0 | 35.2 | 67.4 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 635.8 | 1117 | 181.1 | 62.3 | 20.7 | 66.8 | 51.4 | 202.1 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | -48.5 | -65.6 | -66.8 | 222.7 | -23.1 | 293.2 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 96.7 | 75.7 | 31.9 | -55.8 | -95.7 | -81.0 | -71.6 | 224.4 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 1296.5 | 1239.4 | 335.2 | 221.2 | 247.2 | 308.1 | 371.5 | 260.9 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 718.6 | 881.9 | 287.1 | 243.0 | 240.2 | 279.5 | 312.2 | 276.6 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 2015.1 | 2121.3 | 622.3 | 464.2 | 487.4 | 587.6 | 683.7 | 537.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | 7.7 | -25.4 | 5.0 | 20.6 | 16.4 | -21.4 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 28.4 | 5.3 | -3.4 | 2.2 | 9.4 | 1.7 | 9.9 | 15.8 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 1787.8 | 2189.4 | 2452.5 | 2920.4 | 3160.1 | 3206.9 | 568.94 | 558.11 | 618.84 | 648.87 | 496.06 | 519.21 |
| ក្នុងនេះ៖ សំលៀកបំពាក់* | 1708.1 | 2108.1 | 2352.8 | 2810.8 | 3050.2 | 3097.8 | 462.2 | 492.4 | 535.5 | 579.3 | 433.3 | 505.4 |
| *- សហរដ្ឋអាមេរិក* | *1101.8* | *1281.7* | *1555.6* | *1851.7* | *1959.9* | *1913.0* | *88.0* | *88.1* | *89.3* | *80.1* | *76.7* | *85.2* |
| *- សហភាពអឺរ៉ុប* | *419.2* | *593.1* | *506.9* | *603.0* | *660.9* | *693.4* | *108.6* | *128.3* | *125.7* | *113.8* | *102.5* | *115.9* |
| *- អាស៊ាន* | *60.8* | *55.4* | *70.7* | *80.4* | *90.3* | *99.6* | *51.0* | *55.1* | *62.1* | *152.1* | *42.7* | *37.5* |
| *- ជប៉ុន* | *18.3* | *23.0* | *25.0* | *40.6* | *30.1* | *26.5* | *110.9* | *112.8* | *149.3* | *128.3* | *124.1* | *154.8* |
| *- ប្រទេសផ្សេងៗ* | *108.0* | *154.9* | *194.6* | *235.1* | *309.0* | *365.3* | *103.7* | *108.1* | *109.1* | *105.0* | *87.3* | *112.0* |
| កសិកម្ម | 79.7 | 81.3 | 99.7 | 109.6 | 109.9 | 109.1 | 106.74 | 65.71 | 83.34 | 69.57 | 62.76 | 13.81 |
| *- កៅស៊ូ* | *35.1* | *38.3* | *36.7* | *41.5* | *41.0* | *35.8* | *11.79* | *8.27* | *15.08* | *16.49* | *11.94* | *13.81* |
| *- ឈើ* | *10.2* | *11.1* | *10.3* | *8.6* | *8.7* | *3.4* | *0.55* | *0.5* | *0.64* | *1.83* | *2.75* | *4.48* |
| *- ត្រី* | *2.8* | *10.6* | *10.1* | *5.9* | *3.2* | *2.3* | *0.83* | *0.85* | *1.11* | *1.2* | *0.81* | *0.56* |
| *- ផ្សេងៗ* | *31.6* | *21.3* | *42.6* | *53.6* | *57.0* | *67.6* | *93.57* | *56.09* | *66.51* | *50.05* | *47.26* | *51.15* |
| ការនាំចូលសរុប* | 1824.9 | 2148.9 | 2513 | 512.2 | 554.8 | 1010.9 | 173 | 177.8 | 148.8 | 133.2 | 139.3 | 174.8 |
| ក្នុងនេះ៖ ផលិតផលសាំង | 33.2 | 30.2 | 40.2 | 38.8 | 58.7 | 70.1 | 16.8 | 15.6 | 19.3 | 19.4 | 22.0 | 17.3 |
| ម៉ាស៊ីន | 109.6 | 109.4 | 93.1 | 113.0 | 122.8 | 113.5 | 34.2 | 40.0 | 46.0 | 43.1 | 44.7 | 49.6 |
| សំភារៈសំណង់ | 80.8 | 95.3 | 134.7 | 56.5 | 69.0 | 77.8 | 13.8 | 14.8 | 15.7 | 13.3 | 14.5 | 13.5 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245 | 303.9 | 304.3 | 749.5 | 108.2 | 107.4 | 67.8 | 57.4 | 58.1 | 94.4 |
| ជញ្ជីងពាណិជ្ជកម្ម | -37.1 | 40.5 | -60.5 | 2408.2 | 2605.3 | 2196 | 395.94 | 380.31 | 470.04 | 515.67 | 356.76 | 344.41 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | - | -16.0 | 6.5 | 8.8 | 8.2 | -25.2 | 16.6 |
| ការនាំចេញសរុប | - | - | - | - | - | - | -1.7 | -1.9 | 10.9 | 4.9 | -23.6 | 4.7 |
| ការនាំចូលសរុប | - | - | - | - | - | - | -6.5 | 2.8 | -16.3 | -10.5 | 4.6 | 25.5 |
| | | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 20.1 | 23.4 | 11.6 | 19.5 | 8.5 | 1.6 | -5.4 | -7.0 | -11.4 | 5.3 | -6.3 | 2.6 |
| ការនាំចេញសរុប | 17.5 | 22.5 | 12.0 | 19.1 | 8.2 | 1.5 | 12.1 | -5.5 | -3.0 | 12.1 | -12.8 | -7.0 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | -79.6 | 8.3 | 82.2 | 30.9 | -67.5 | 0.0 | -28.0 | -19.5 | -1.7 |

*Import data include tax-exempt imports. Source: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (web site). Updated data*

### តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៣-១០ (ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 1764.0 | 2126.0 | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 |
| ចំណូលចរន្ត | 1733.0 | 2107.0 | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 |
| ចំណូលពន្ធ | 1220.0 | 1577.0 | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 |
| ពន្ធក្នុងស្រុក | - | - | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 |
| ចំណូលមិនមែនពន្ធ | 513.0 | 530.0 | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 |
| លក់ទំនិញ និងសេវា | - | - | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 |
| ចំណូលជាមូលធន | 31.0 | 19.0 | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 |
| ចំណាយសរុប | 2757.0 | 2932.0 | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 |
| ចំណាយជាមូលធន | 1171.0 | 1163.0 | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 |
| ចំណាយចរន្ត | 1586.0 | 1769.0 | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 |
| បៀវត្សរ៍ | 615.0 | 640.0 | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 |
| សមតុល្យជាទូទៅ | -993.0 | -806.0 | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886.0 | 864.0 | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 |
| ហិរញ្ញប្បទានក្នុងស្រុក | 106.0 | 148.0 | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 |

*Source: MEF web site*

### តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៣-១០

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | 2010 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | 1.1 | 3.9 | 5.8 | 4.7 | 5.8 | 19.7 | 4.3 | -4.8 | -3.0 | 1.7 | 7.0 | 4.1 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 1.5 | 6.4 | 8.6 | 6.4 | 9.9 | 33.1 | 6.1 | -5.2 | -2.7 | 1.8 | 7.8 | 3.6 |
| - ដឹកជញ្ជូន | 4.9 | 9.7 | 11.4 | 9.1 | 5.8 | 19.4 | -13.0 | -16.5 | -13.8 | 2.4 | 12.9 | 8.7 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3973.3 | 4016.3 | 4119.7 | 4119.0 | 4062.7 | 4058.2 | 4111.6 | 4128.6 | 4164.4 | 4157.3 | 4180.1 | 4209.0 |
| រៀលក្នុង ១ បាតថៃ | 95.8 | 99.9 | 102.6 | 108.7 | 122.8 | 123.5 | 116.6 | 119.2 | 122.9 | 126.0 | 127.0 | 129.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.5 | 25.8 | 25.1 | 25.0 | 24.8 | 23.6 | 23.3 | 23.5 | 23.0 | 22.3 | 22.1 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 41.4 | 46.3 | 54.0 | 70.6 | 83.2 | 105.9 | 105.6 | 110.7 | 123.2 | 133.8 | 133.9 | 142.9 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1508.0 | 2088.0 | 2633.0 | 3140.0 | 3262.3 | 4555.2 | 2873.7 | 3056.9 | 3867.0 | 3381.9 | 3599.5 | 3835.1 |
| ថ្លៃសាំង (រៀល/លីត្រ) | 2150.0 | 2833.0 | 3442.0 | 4004.0 | 4005.0 | 4750.8 | 3112.6 | 3452.4 | 3371.1 | 3940.2 | 4163.0 | 4358.7 |

*Sources: NIS, NBC and CDRI*

### តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-១០ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4027.0 | 4,797.0 | 5,475.0 | 7,224.0 | 10,735.0 | 10,345.0 | 11,222.0 | 12,611.0 | 13,869.0 | 14,655.0 | 15,514.6.0 | 12,610.9 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698.0 | -467.0 | -450.0 | -282.0 | 576.0 | 1513.3 | 1,266.0 | 1,249.0 | 1,042.0 | 1,573.0 | 1,720.0 | 1,785.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128.0 | -209.0 | -421.0 | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 |
| ឥណទានដល់ផ្នែកឯកជន | 1337.0 | 1817.0 | 2394.0 | 3630.0 | 6386.0 | 9894.0 | 9814.0 | 10,129.0 | 10,127.0 | 10,532.0 | 11,146.7 | 11,859.1 |
| រូបិយវត្ថុទូទៅ M2 | 3329.0 | 4330.0 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 12,488.0 | 13,859.0 | 14,912.0 | 16,228.0 | 17,234.5 | 18,267.1 |
| រូបិយវត្ថុ M1 | 937.0 | 1153.0 | 1323.0 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 |
| រូបិយវត្ថុផ្សេងៗ | 2392.0 | 3177.0 | 3702.0 | 5285.0 | 9259.0 | 9459.0 | 9942.0 | 11,164.0 | 12,139.0 | 13,108.0 | 14,086.0 | 15,152.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 6.0 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | -1.1 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 7.6 |

*Source: National Bank of Cambodia*

### តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2007 | 2007 | 2008 | 2009 | | | 2010 | | | | 2010 | |
| | | វិច្ឆិកា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 8075 | 9675 | 12628 | 8896 | 7738 | 7446 | 9413 | 9570 | 8393 | 10.3 | 7.6 | 8.5 |
| អ្នកលីសែង | 8588 | 9119 | 9005 | 10,319 | 8159 | 9566 | 9953 | 9340 | 10,500 | -5.0 | -9.5 | 28.7 |
| អ្នកលក់បន្លែតូចតាច | 8220 | 8552 | 9926 | 9764 | 8323 | 7647 | 7826 | 8062 | 8380 | 2.8 | -17.5 | 0.7 |
| អ្នករើសអេតចាយ | 5422 | 5727 | 4652 | 6637 | 7087 | 4693 | 6238 | 7407 | 6452 | 21.7 | 11.6 | -9.0 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4482 | 4643 | 4327 | 4346 | 4574 | 5568 | 5131 | 5380 | 6418 | 19.8 | 23.8 | 40.3 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5516 | 6426 | 8697 | 7126 | 5785 | 5003 | 5358 | 6260 | 6177 | -23.9 | -12.2 | 6.8 |
| កម្មកររោងចក្រកាត់ដេរ | 7568 | 7240 | 6554 | 6691 | 7410 | 7745 | 7557 | 7491 | 8470 | 11.9 | 12.0 | 14.3 |
| អ្នករត់ម៉ូតូឌុប | 10,634 | 11,872 | 15,691 | 12,148 | 9569 | 9696 | 11,302 | 10,274 | 10,544 | -3.0 | -15.9 | 10.2 |
| កម្មករសំណង់គ្មានជំនាញ | 6155 | 7777 | 8779 | 9956 | 9444 | 8132 | 7699 | 9013 | 11,722 | 25.9 | -9.5 | -1.6 |
| កម្មករសំណង់មានជំនាញ | 11,154 | 11,286 | 12,710 | 13,688 | 11,918 | 13,011 | 11,924 | 11,928 | 8733 | 1.3 | -12.9 | -7.5 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

*តពីទំព័រ ៣២* **ព័ត៌មានថ្មីៗ...**

- ហេតុអ្វី CDRI មានសារៈសំខាន់? តើយើងអាចបង្ហាញយ៉ាងដូចម្តេចនូវការប្តេជ្ញាចិត្ត ចំពោះ CDRI និងអនាគតរបស់ CDRI? គំនិត និងយោបល់ចុងក្រោយ សម្រាប់អនាគតវិទ្យាស្ថាន CDRI ។

លទ្ធផលដែលទទួលបានពីការផ្លាស់ប្តូរយោបល់ដ៏ផុលផុសក្នុងការសម្រាកដើម្បីពិភាក្សានេះ នឹងមានដាក់បញ្ចូលនៅក្នុងយុទ្ធសាស្ត្រស្រាវជ្រាវសម្រាប់ឆ្នាំ២០២០ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ ។

នៅខែវិច្ឆិកា ២០១០ វិទ្យាស្ថាន CDRI បានធ្វើការផ្សព្វផ្សាយជាថ្មីម្តងទៀត ទាំងក្នុងតំបន់ និងអន្តរជាតិ ដើម្បីស្វែងរកបេក្ខជនអ្នកមានសមត្ថភាពល្អ សម្រាប់មុខតំណែងជានាយកផ្នែកស្រាវជ្រាវនៅ CDRI ។ ការធ្វើសម្ភាសន៍បេក្ខជន នឹងធ្វើឡើងនៅដើមឆ្នាំ២០១១ ។ ព័ត៌មានបន្ថែម អាចរកបាននៅលើគេហទំព័ររបស់ CDRI: www.cdri.org.kh ។

នៅថ្ងៃទី ២៤-២៦ ខែវិច្ឆិកា លោកនាយកប្រតិបត្តិបានធ្វើជាតំណាង CDRI ទៅចូលរួមកិច្ចពិភាក្សាអន្តរជាតិ ស្តីពីការស្វែងរកភាពជាដៃគូសាកលថ្មីមួយ សម្រាប់ប្រទេសលូតលាស់តិចជាងគេ ក្នុងបរិបទនៃប្រទេសលូតលាស់តិចជាងគេនៃសហប្រជាជាតិ លើកទីបួន នៅឯទីក្រុងដាកា ប្រទេសបង់ក្លាដេស ដែលសហការរៀបចំឡើងដោយមជ្ឈមណ្ឌលសម្រាប់កិច្ចពិភាក្សាគោលនយោបាយ (CPD) នៃប្រទេសបង់ក្លាដេស មជ្ឈមណ្ឌលអភិវឌ្ឍន៍ OECD ហើយនិង UNDP ។

នៅថ្ងៃទី ៩ ខែធ្នូ CDRI បានដំណើរការកិច្ចប្រជុំពិនិត្យលទ្ធផលប្រចាំឆ្នាំ ជាមួយទីភ្នាក់ងារស៊ុយអែតសម្រាប់ការអភិវឌ្ឍអន្តរជាតិ (Sida) ដើម្បីបូកសរុបពីសកម្មភាពការងារជាទូទៅ និង លទ្ធផលស្រាវជ្រាវសំខាន់ៗក្នុងឆ្នាំ២០១០ របស់ CDRI ក៏ដូចជាកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ ដែលបាននិងកំពុងទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងពី Sida ។ កិច្ចប្រជុំនេះ ក៏បានពិភាក្សាពីអាទិភាពខាងគោលនយោបាយ និងការស្រាវជ្រាវទៅថ្ងៃអនាគតរបស់ CDRI និង Sida និងរបៀបរបបដើម្បីបន្តជំនួយទ្រទ្រង់ពី Sida សម្រាប់ឆ្នាំ២០១១-២០១៥ ។

នៅពាក់កណ្តាលខែធ្នូ ឆ្នាំ២០១០ លោកនាយកប្រតិបត្តិនៃ CDRI បានដឹកនាំគណៈប្រតិភូ អ្នកតំណាងនៃបណ្តាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS-DAN) ដែលជាបណ្តាញសហការ រវាងស្ថាប័នស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍នៅ កម្ពុជា ឡាវ ថៃ វៀតណាម និងខេត្តយូណានប្រទេសចិន និងទទួលបានជំនួយទ្រទ្រង់ពីមូលនិធិ Rockefeller ទៅធ្វើទស្សនកិច្ចនៅការិយាល័យកណ្តាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី នៅទីក្រុងម៉ានីល ដើម្បីស្វែងរកដៃគូសហការជាយុទ្ធសាស្ត្រសម្រាប់ថ្ងៃអនាគត ។ បន្ទាប់មក លោកនាយកប្រតិបត្តិបានតំណាងឲ្យ CDRI ទៅចូលរួមក្នុងសន្និសីទដៃគូសហការរបស់ Rockefeller ស្តីពី ការជំនះវិសមភាពនៅអាស៊ី ដែលរៀបចំឡើងនៅទីក្រុងបាងកក ។

## ផ្នែកស្រាវជ្រាវ

ពីខែតុលា ដល់ ធ្នូ ២០១០ វិទ្យាស្ថាន CDRI មានសកម្មភាពស្រាវជ្រាវ និងសកម្មភាពទាក់ទងនឹងការស្រាវជ្រាវ តាមកម្មវិធីជំនាញដូចតទៅ៖

**កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់សាធារណៈ** *(DGPSR)*

កម្មវិធីនេះបានរៀបចំសិក្ខាសាលាមួយ និងកំពុងអនុវត្តគម្រោងចំនួន ១០ ក្នុងត្រីមាសនេះ ។ សម្រាប់គម្រោង *"ការវិភាគពីរដ្ឋកម្ពុជា៖ ការស្វែងរកមាគ៌ានៃការអភិវឌ្ឍបានជោគជ័យ"* ក្រុមស្រាវជ្រាវបានពិភាក្សា និងសរសេរបញ្ចប់របាយការណ៍ព្រាងទី១ ។ គម្រោង *"ការវាយតម្លៃបែបគុណភាពលើផលប៉ះពាល់នៃសេវាកម្មច្រកចេញចូលតែមួយ"* ដែលទទួលហិរញ្ញប្បទានពីធនាគារពិភពលោក បានផ្តល់លទ្ធផលដែលចងក្រងចេញជាអត្ថបទមួយ សម្រាប់បញ្ចូលក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ គ្រោងបោះពុម្ពផ្សាយនៅខែមីនា ២០១១ ។ សម្រាប់គម្រោង *"ការវិភាគពីអំណាចយេនឌ័រ"* ដែលទទួលមូលនិធិពីមជ្ឈមណ្ឌលអន្តរជាតិស៊ុយអែតដើម្បីរបបប្រជាធិបតេយ្យនៅមូលដ្ឋាន (ICLD) ក្រុមស្រាវជ្រាវបានធ្វើសិក្ខាសាលាមួយ បង្ហាញពីលទ្ធផលស្រាវជ្រាវ ហើយកំពុងពិចារណាលើមតិយោបល់ ទទួលបានពីសិក្ខាសាលា ដើម្បីសរសេរបង្កើយរបាយការណ៍នៅចុងខែធ្នូ ។ សម្រាប់គម្រោង *"អភិបាលកិច្ចដែនរងទឹកភ្លៀង៖ បញ្ហាចោទក្នុងកិច្ចសហប្រតិបត្តិការប្រើប្រាស់ទឹកស្រោចស្រព"* ក្រុមស្រាវជ្រាវបានចុះសិក្សាដល់ទីកន្លែង ក្នុងខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២-៤ ធ្នូ ។ ក្របខ័ណ្ឌសម្រាប់ឯកសារពិភាក្សា ស្តីពី *"អភិបាលកិច្ចធារាសាស្ត្រ"* ដែលជាគម្រោងរួមគ្នាជាមួយកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE) នោះ បានរៀបចំរួចរាល់ ហើយអត្ថបទព្រាងដំបូង រំពឹងថានឹងបានស្រេចបាច់នៅខែមេសា ២០១១ រីឯការបោះពុម្ពផ្សាយគ្រោងធ្វើនៅខែមិថុនា ២០១១ ។

គម្រោង *"កំណែទម្រង់វិស័យសាធារណៈ ដើម្បីកសាងអភិបាលកិច្ចល្អលើទឹកស្រោចស្រពនៅកម្ពុជា៖ គំលាតរវាងគោលនយោបាយ និងការអនុវត្ត"* ត្រូវផ្អាកសិន ព្រោះមួយរយៈចុងក្រោយនេះ ក្រុមស្រាវជ្រាវជាប់ធ្វើការជាមួយកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE) លើគម្រោង *"កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក"* ។ សម្រាប់គម្រោង *"ការវិភាគពីវិសហមជ្ឈការ និងវិមជ្ឈការនៅកម្ពុជា៖ ភាពផ្ទុយគ្នារវាងមជ្ឈការ និងវិមជ្ឈការ"* ក្រុមស្រាវជ្រាវកំពុងចងក្រងជំពូក៤ នៃឯកសារពិភាក្សា ស្តីពី *"ការវិភាគពីវិសហមជ្ឈការ និងវិមជ្ឈការ ក្នុងស្ថានភាពលាយឡំគ្នានៃប្រព័ន្ធទាំងពីរនៅកម្ពុជា"* ។ ក្រុមស្រាវជ្រាវគម្រោង *"ចំណាកស្រុកមិនទៀងទាត់នៅកម្ពុជា៖ បញ្ហាប្រឈម និងគោលនយោបាយ*

*ឆ្លើយតប"* ដោយរួមសហការជាមួយកម្មវិធី សេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC) បានបញ្ចប់ការសិក្សាដល់ទីកន្លែង និងកំពុងវិភាគទិន្នន័យ ដើម្បីចងក្រងរបាយការណ៍ព្រាងដំបូង ដែលគ្រោងបញ្ចប់នៅចុងឆ្នាំ២០១០ ។ សម្រាប់គម្រោង *"អង្កេតមូលដ្ឋានលើអាជ្ញាធរថ្នាក់ក្រោមជាតិ៖ ការពង្រីកចំណេះដឹងពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា"* ក្រុមស្រាវជ្រាវ កំពុងបង្កើយការកំណត់គំរូតាង និងបញ្ជីសំណួរ ។ សម្រាប់គម្រោង *"ការកសាងវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់សម្រាប់សកម្មភាពដោះមីននៅកម្ពុជា"* ក្រុមស្រាវជ្រាវកំពុងពិនិត្យឡើងវិញលើឯកសារមានស្រាប់ និងកំណត់សូចនាករវាយតម្លៃ ។

**កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់** (ETRC)

កម្មវិធីនេះបានអនុវត្តគម្រោងស្រាវជ្រាវចំនួន ៨ ។ គម្រោង *"អង្កេតពលករងាយរងគ្រោះ"* និង *"អង្កេតថ្លៃទំនិញតាមខេត្ត"* កំពុងលូតលាស់ទៅមុខយ៉ាងល្អ ។ សម្រាប់គម្រោង *"ភាពក្រីក្រ និង ចំណងទាក់ទងជាមួយបរិស្ថាន៖ ករណីសិក្សានៅជនបទកម្ពុជា"* ដែលជាសមាសភាគទីពីរ នៃគម្រោង *"បណ្តាញភាពក្រីក្រ"* ក្រុមស្រាវជ្រាវបានបញ្ជូនរបាយការណ៍ព្រាងដំបូងទៅធនាគារ ADB ដើម្បីសុំមតិ និងបានធ្វើបទបង្ហាញពីលទ្ធផលរកឃើញដំបូងៗនៅក្នុងសន្និសីទថ្នាក់តំបន់ ស្តីពី *"បរិស្ថានរបស់អ្នកក្រ ក្នុងបរិបទមានបម្រែបម្រួលអាកាសធាតុ និងសេដ្ឋកិច្ចបៃតង"* នៅទីក្រុងញូវដេលី ប្រទេសឥណ្ឌា នៅថ្ងៃទី ២៤-២៦ វិច្ឆិកា ២០១០ ។ ឯកសារព្រាងដំបូងសម្រាប់គម្រោង *"ចរន្តពលករខុសៗគ្នា តម្រូវការខុសៗគ្នា និងផលប៉ះពាល់ខុសៗគ្នា៖ ការគ្រប់គ្រងចំណាកស្រុកកម្លាំងពលកម្មអន្តរជាតិ នៅអាស៊ាន"* គ្រោងចប់រួចរាល់សម្រាប់ការពិនិត្យឡើងវិញ នៅដើមឆ្នាំក្រោយ ហើយការងារផ្សេងៗ ក៏បានត្រៀមស្រេច សម្រាប់ទៅចូលរួមសិក្ខាសាលាបច្ចេកទេស នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នៅខែមករា ២០១១ ។

គម្រោង *"ការធ្វើរោគវិនិច្ឆ័យលើកំណើន"* មានដំណើរការទៅមុខល្អ ហើយរបាយការណ៍ព្រាងដំបូង បានផ្ញើទៅឲ្យវិទ្យាស្ថានជើង-ត្បូង (ប្រទេសកាណាដា) ដើម្បីសុំមតិបន្ថែមបន្ទាប់មក សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍តាមប្រទេសទាំងបី (កម្ពុជា ឡាវ វៀតណាម) ក៏បានធ្វើឡើងកាលពីថ្ងៃទី ១៦ ខែធ្នូ ។ របាយការណ៍ *"ការវិភាគពីវិនិយោគអន្តរជាតិក្នុងវិស័យកសិកម្មនៅកម្ពុជា"* កំពុងសរសេរចេញ ហើយការសិក្សាដល់ទីកន្លែង គ្រោងធ្វើឡើងនៅសប្តាហ៍ទី៣ ខែធ្នូ ២០១០ ដើម្បីប្រមូលព័ត៌មានបន្ថែមលើទិន្នន័យបានពីការសិក្សានៅការិយាល័យ ។ របាយការណ៍អំពី *"បញ្ហាប្រឈមចំបងៗលើមាគ៌ាលូតលាស់សេដ្ឋកិច្ច៖ ការកែសម្រួលរចនាសម្ព័ន្ធ និងតួនាទីរដ្ឋាភិបាល"* និង *"ការស្វែងរកសក្តានុពលកំណើន និងការវាយតម្លៃពីសក្តានុពលកំណើននៅកម្ពុជា"* កំពុងកែសម្រួលដោយផ្អែកលើមតិយោបល់ទទួលបានពី វិទ្យាស្ថានអភិវឌ្ឍន៍នៃប្រទេសកូរ៉េ និងអ្នកចូលរួមដទៃទៀតក្នុងសិក្ខាសាលានៃអ្នកអនុវត្តគោលនយោបាយ និងរបាយការណ៍បណ្តោះអាសន្ន ក្នុងទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង នៅខែតុលា ២០១០ ។ អត្ថបទពីរ អំពី *"ផលប្រយោជន៍ និងចំណាយ នៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ (GMS)"* និង *"ការវាយតម្លៃផលប៉ះពាល់របស់ចិន ទៅលើការកាត់បន្ថយភាពក្រីក្រនៅ GMS"* ដែលជាការសិក្សាលើកទី៦ និង ទី៨ អំពីប្រទេស GMS ធ្វើឡើងដោយបណ្តាញវិភាគអភិវឌ្ឍន៍ (DAN) នោះ កំពុងរៀបចំបង្កើយសម្រាប់ការបោះពុម្ពផ្សាយជាអន្តរជាតិ ដោយ ISEAS ។ បច្ចុប្បន្ន CDRI កំពុងស្វែងរកដៃគូសហការជាយុទ្ធសាស្ត្រ ដើម្បីជួយទ្រទ្រង់ដល់ DAN ចាប់ពីឆ្នាំ២០១១ តទៅ ។

សន្និសីទប្រចាំឆ្នាំលើកទី៣ ស្តីពី *"ការស្រាវជ្រាវ និងគោលនយោបាយជំរុញការរើបសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជា"* នៃវេទិកាសិក្សាស្រាវជ្រាវការអភិវឌ្ឍ (DRF) ដែលធ្វើឡើងនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៩-១០ កញ្ញា ២០១០ បានសម្រេចជោគជ័យយ៉ាងខ្លាំង ដោយមានការពេញចិត្តពីសំណាក់អ្នកពាក់ព័ន្ធនឹងវិស័យអភិវឌ្ឍន៍នានាជាច្រើន ។ វេទិកានេះបានរួមចំណែកយ៉ាងច្រើន ក្នុងការលើកកម្ពស់ចំណងទាក់ទងរវាងការស្រាវជ្រាវនិងគោលនយោបាយ ការបង្កើតនិងចែករំលែកចំណេះដឹងខាងការអភិវឌ្ឍ និងការពង្រឹងបណ្តាញស្រាវជ្រាវអភិវឌ្ឍន៍នៅកម្ពុជា ។ វេទិកានេះ ក៏បានបោះពុម្ពផ្សាយអត្ថបទ *"ការសិក្សាបឋម៖ សមត្ថភាពស្រាវជ្រាវតាមសាកលវិទ្យាល័យនៅប្រទេសកម្ពុជា"* ជាភាសាខ្មែរ និងអង់គ្លេស ហើយបន្តផ្តល់ជំនួយទ្រទ្រង់ដល់សិក្ខាសាលា នៅតាមសាកលវិទ្យាល័យនានា ការស្រាវជ្រាវរួមគ្នា និងក្រុមចំណាប់អារម្មណ៍ខាងស្រាវជ្រាវ ។ នៅត្រីមាសនេះ កម្មវិធី ETRC ទទួលបានគម្រោងថ្មី ២ គឺ៖ *"វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា"* មកពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) និង *"ការវិភាគពីភាពក្រីក្ររ៉ាំរ៉ៃនៅជនបទកម្ពុជា៖ ភស្តុតាងបានពីទិន្នន័យជាក្រុម"* មកពី បណ្តាញអភិវឌ្ឍន៍អាស៊ីបូព៌ា ។ គម្រោង *"វិបត្តិហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា"* មានរយៈពេល ២ឆ្នាំ នឹងអនុវត្តឡើងដោយរួមសហការជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ វិទ្យាស្ថានជាតិស្ថិតិ ទីស្តីការគណៈរដ្ឋមន្ត្រី និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

**កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន** (NRE)

NRE បានបន្តការងារលើគម្រោងស្រាវជ្រាវធំៗ ៣ ក្នុង *"កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ លើការគ្រប់គ្រងធនធានទឹក"* សម្រាប់សមាសភាគអភិបាលកិច្ច សមាសភាគរូបវ័ន្ត និងសមាសភាគសេដ្ឋកិច្ច ។ ឯកសារពិភាក្សាស្តីពី អភិបាលកិច្ចលើការស្រោចស្រព សម្រាប់សមាសភាគអភិបាលកិច្ច បានចងក្រងជិតចប់ហើយ ។ ឯកសារពិភាក្សាលើការវិភាគធារាសាស្ត្រ និងសង្ខេបគោលនយោបាយ សម្រាប់សមាសភាគរូបវ័ន្ត កំពុងត្រៀមបោះពុម្ពផ្សាយ រីឯឯកសារពិភាក្សាស្តីពី តម្លៃទឹកប្រើប្រាស់លើការដាំដុះ សម្រាប់សមាសភាគសេដ្ឋកិច្ច បានចងក្រងចប់ហើយ ។ ក្រុមស្រាវជ្រាវគម្រោងនេះ បានរៀបចំសិក្ខាសាលាថ្នាក់ខេត្ត ៣ នៅខេត្តកំពង់ធំ ពោធិ៍សាត់ និងកំពង់ឆ្នាំង ដើម្បី

ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងទទួលយកព័ត៌មានត្រលប់ពីអ្នកពាក់ព័ន្ធ ។ ក្រុមស្រាវជ្រាវ ក៏បានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយ និងកិច្ចប្រជុំគណៈកម្មការពិគ្រោះយោបល់លើកទី៧ នៅថ្ងៃទី ៨-៩ ធ្នូ ២០១០ ស្ដីពី ការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព ។

សេចក្ដីព្រាងនៃឯកសារពិភាក្សា ក្នុងគម្រោង *"ព្រៃតំបន់ត្រូពិចសំរាប់ការកាត់បន្ថយភាពក្រីក្រ – ការវិភាគទិន្នន័យតាំងពីកម្រិតគ្រួសារដល់កំរិតសាកល"* បានចប់សព្វគ្រប់ និងបានផ្ញើចេញដើម្បីទទួលមតិយោបល់ពីម្ចាស់ជំនួយ ។ សម្រាប់គម្រោង *"ការកសាងសមត្ថភាពសហគមន៍ សំរាប់ការផ្ដួចផ្ដើមគំនិតកាត់បន្ថយភាពក្រីក្រនៅតំបន់អាងទន្លេសាប"* ក្រុមស្រាវជ្រាវបានចងក្រងលទ្ធផល នៃអង្កេតពីការត្រៀមខ្លួន និងសមត្ថភាពសហគមន៍ ហើយបច្ចុប្បន្នកំពុងបន្តកិច្ចប្រឹងប្រែងប្រមូលឯកសារស្រាវជ្រាវ សម្រាប់មជ្ឈមណ្ឌលធនធានទន្លេសាបនៅក្នុងបណ្ណាល័យ CDRI និងរៀបចំឯកសារទាំងនោះឲ្យកាន់តែងាយស្រួលប្រើប្រាស់ ។ ក្រៅពីនេះ ក្រុមស្រាវជ្រាវក៏បានជ្រើសបន្ថែមឃុំច្រើនទៀតនៅជុំវិញបឹងទន្លេសាប ដើម្បីបង្កើនសកម្មភាពអង្កេតរបស់ខ្លួន ។

### កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD)

PARD បានអនុវត្តគម្រោង ៣ ក្នុងត្រីមាសនេះ គឺៈ *"ការសិក្សាពីឌីណាមិកនៃភាពក្រីក្រ"* *"ការកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទនៅបឹងទន្លេសាបៈ សកម្មភាពរួមគ្នា និងសមត្ថភាពគ្រប់គ្រងធនធាន"* និង *"ការវាយតម្លៃពីផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច នៃច្រករបៀងនៅតំបន់ឆ្នេរភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ និងការត្រួតពិនិត្យជម្ងឺឆ្លង"* ។

នាបច្ចុប្បន្ន ក្រុមនេះកំពុងបន្តអនុវត្តគម្រោង ៤ ។ ក្រុមស្រាវជ្រាវក្នុងគម្រោង *"ការបូកសរុបពីសន្តិសុខស្បៀងអាហារូបត្ថម្ភ និងគោលនយោបាយអភិវឌ្ឍន៍កសិកម្មនៅកម្ពុជា"* បានសរសេរជារបាយការណ៍ ២ និងបានចែកចាយ និងធ្វើបទបង្ហាញពីឯកសារស្រាវជ្រាវចំនួន ៦ នៅក្នុងកិច្ចប្រជុំតុមូលកាលពីថ្ងៃទី ៤ វិច្ឆិកា ២០១០ ដែលមានអ្នកចូលរួមជាតំណាងមកពី ស្ថាប័នរដ្ឋសំខាន់ៗ ទីភ្នាក់ងារផ្ដល់ជំនួយ និង អង្គការមិនមែនរដ្ឋាភិបាល ។ សម្រាប់គម្រោង *"ការវាយតម្លៃពីផលប៉ះពាល់នៃការរៀបចំក្រុមកសិករទៅលើសន្តិសុខស្បៀងសម្រាប់ជនក្រីក្រនៅជនបទ"* ក្រុមស្រាវជ្រាវបានបញ្ចប់ការចុះសិក្សាដល់កន្លែងជាដំបូងៗ នៅខេត្តស្វាយរៀង បាត់ដំបង និងសៀមរាប ហើយរបាយការណ៍ពីការងារចាប់ផ្ដើមគម្រោង បានកែសម្រួលយោងតាមមតិយោបល់ពី ធនាគារពិភពលោក និង AusAID ។ ទាក់ទិននឹងគម្រោង *"ការកសាងវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់សម្រាប់សកម្មភាពដោះមីននៅកម្ពុជា"* ក្រុមស្រាវជ្រាវកំពុងពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ និងទិន្នន័យថ្នាក់ជាតិ ដើម្បីកំណត់រកគំលាត និងសូចនាករពាក់ព័ន្ធនានា សម្រាប់ការវាយតម្លៃពីផលប៉ះពាល់ ។ ក្នុងគម្រោង *"ភាពរលូនគ្នាខាងគោលនយោបាយសម្រាប់ការអភិវឌ្ឍជនបទ និងកសិកម្ម"* ក្រុមស្រាវជ្រាវកំពុងពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់ ដើម្បីរៀបចំការស្រាវជ្រាវ មានទាំងករណីសិក្សាផ្សេងៗផង សម្រាប់ធ្វើការវិភាគ និងបានទៅចូលរួមក្នុងកិច្ចប្រជុំមួយ នៅទីក្រុងឡុងប្រទេសអង់គ្លេស កាលពីថ្ងៃទី ២៣-២៦ វិច្ឆិកា ២០១០ ដើម្បីធ្វើការសម្រេចលើក្របខណ្ឌស្រាវជ្រាវ និងឧបករណ៍ស្រាវជ្រាវសម្រាប់ការសម្ភាសជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ ។

### កម្មវិធីអភិវឌ្ឍន៍សង្គម (SD)

SD បានអនុវត្តគម្រោង ៣ ។ អត្ថបទប្រមូលផ្ដុំឯកសារបទបង្ហាញនានា នៅក្នុងសន្និសីទសុខាភិបាលអន្តរជាតិ ស្ដីពី *"ការលើកកំពស់លទ្ធផលក្នុងវិស័យសុខាភិបាលៈ ស្ថាប័ន សន្ទុះចិត្ត និងការលើកទឹកចិត្ត"* ដែល CDRI បានរៀបចំឡើង ដោយរួមសហការជាមួយ វិទ្យាស្ថានខាងគោលនយោបាយ Oxford (OPI) កាលពីខែមេសា ២០១០ នោះ បានផ្ញើទៅឲ្យអ្នកបោះពុម្ពផ្សាយពិនិត្យហើយ ។ ការបោះពុម្ពសៀវភៅនេះ ទទួលបានមូលនិធិពីសាកលវិទ្យាល័យស្រាវជ្រាវ (University Research Co., LLC) ។ ក្រុមស្រាវជ្រាវកំពុងរៀបចំឯកសារមួយ ស្ដីពី *"ចំណាយអាសន្នលើការថែទាំសុខភាពក្នុងគ្រួសារ"* សម្រាប់គម្រោង EQUITAP[១] ដែលទទួលហិរញ្ញប្បទានពី AusAID ។ លទ្ធផលបឋមពីការវិភាគបានបញ្ជូនទៅឲ្យអ្នកសម្របសម្រួលដើម្បីសុំមតិយោបល់ហើយ។ ម្យ៉ាងទៀតក្រុមស្រាវជ្រាវកំពុងបង្ហើយ ការបង្កើតគំរូតាង និងបញ្ជីសំណួរ សម្រាប់គម្រោងរួមគ្នាជាមួយ DGPSR ស្ដីពី *"អង្កេតមូលដ្ឋានលើអាជ្ញាធរថ្នាក់ក្រោមជាតិៈ ការពង្រីកចំណេះដឹងពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា"* ។

ក្រុមការងារកសាងសន្តិភាព បានដំណើរការដោយជោគជ័យ នៅស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង នូវវគ្គបណ្ដុះបណ្ដាលស្ដីពី *"ធ្វើការរួមគ្នាដើម្បីសន្តិភាព និងអភិវឌ្ឍន៍"* ដែលផ្ដោតលើបញ្ហាចោទខ្លាំងនៅទីនោះគឺ ទំនាស់ដីធ្លី ។ ដោយផ្អែកលើលទ្ធផលស្រាវជ្រាវរបស់ CDRI ក្រុមការងារបានចុះធ្វើការវាយតម្លៃ ពីតម្រូវការវគ្គបណ្ដុះបណ្ដាល នៅក្នុងឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ខេត្តសៀមរាប សម្រាប់ប្រើជាមូលដ្ឋានរៀបចំវគ្គបណ្ដុះបណ្ដាលមួយស្ដីពី *"ការគ្រប់គ្រងទំនាស់ ការដោះស្រាយទំនាស់ និង អភិបាលកិច្ចល្អ"* នៅទីនោះ នៅពាក់កណ្ដាលខែធ្នូ ។ ម្យ៉ាងទៀត ក្រុមការងារក៏បានដំណើរការវគ្គបណ្ដុះបណ្ដាលស្ដីពី *"តួនាទីនៃប្រព័ន្ធផ្សព្វផ្សាយក្នុងការកសាងសន្តិភាព"* សម្រាប់អ្នកសារព័ត៌មានមកពីប្រព័ន្ធផ្សព្វផ្សាយ និងសមាគមសារព័ត៌មានក្នុងស្រុកនានា ។

---

១ EQUITAP សំដៅលើសមធម៌ក្នុងប្រព័ន្ធសុខាភិបាលនៅអាស៊ីប៉ាស៊ីហ្វិក ហើយវាជាកិច្ចប្រឹងប្រែងរួមគ្នាមួយ នៃក្រុមស្រាវជ្រាវជាង ១៥ក្រុម នៅអាស៊ី និងអឺរ៉ុប ក្នុងការពិនិត្យលើសមធម៌ក្នុងប្រព័ន្ធសុខាភិបាលជាតិនានាក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ។ កិច្ចសហការនេះ រួមមាន ការអភិវឌ្ឍឧបករណ៍ខាងការស្រាវជ្រាវ និងការវាយតម្លៃជាក់ស្ដែងលើការអនុវត្តនៃប្រព័ន្ធសុខាភិបាលជាតិនានា ។

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

នៅថ្ងៃទី ១៨-១៩ ខែតុលា ឆ្នាំ២០១០ លោកនាយកប្រតិបត្តិនៃ វិទ្យាស្ថាន CDRI បានទៅចូលរួមសន្និសីទថ្នាក់តំបន់របស់វិទ្យាស្ថានសិក្សាពីអាស៊ីអាគ្នេយ៍ (ISEAS) នៅប្រទេសសិង្ហបុរីស្ដីពី មហាអនុតំបន់មេគង្គ៖ ចេញពីច្រករបៀងភូមិសាស្ត្រ ទៅជាច្រករបៀងសេដ្ឋកិច្ច-សង្គមកិច្ច ដើម្បីធ្វើបទបង្ហាញពីប្រទេសកម្ពុជា៖ ការអភិវឌ្ឍប្រទេស និងសមាហរណកម្មចូលក្នុងមហាអនុតំបន់មេគង្គ កំពុងជឿនលឿនទៅមុខ ។

ក្នុងអំឡុងពេលពីខែតុលា-ធ្នូ ២០១០ វិទ្យាស្ថាន CDRI បានបន្តដំណើរការ កសាងយុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ របស់ខ្លួន ដែលមានកំណត់ពីអាទិភាពខាងគោលនយោបាយ និងការស្រាវជ្រាវក្នុងរយៈពេលវែង ដើម្បីធ្វើជាមូលដ្ឋាន នៃ ផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ របស់វិទ្យាស្ថាន CDRI ។ ឯកសារយុទ្ធសាស្ត្រស្រាវជ្រាវ និងផែនការយុទ្ធសាស្ត្រទាំងពីរនេះ នឹងដាក់ជូនក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI ពិនិត្យអនុម័តក្នុងពេលប្រជុំពេញអង្គនៅថ្ងៃទី ១៧ មីនា ២០១១ ដើម្បីប្រើជាឧបករណ៍ទាក់ទាញជំនួយគាំទ្រជាលក្ខណៈកម្មវិធី ដែលមានការសម្របសម្រួលល្អពីដៃគូអភិវឌ្ឍន៍នានារបស់ប្រទេសកម្ពុជា និងប្រភពមូលនិធិដទៃទៀត សម្រាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយរបស់វិទ្យាស្ថាន CDRI ។

នៅថ្ងៃទី ១៦-១៩ វិច្ឆិកា ២០១០ វិទ្យាស្ថាន CDRI បានសម្រាកការងារដើម្បីធ្វើការពិភាក្សាប្រចាំឆ្នាំ២០១០ នៅខេត្តសៀមរាប ដោយមានការចូលរួមពីថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់ របស់វិទ្យាស្ថាន ។ ព្រឹត្តិការណ៍នេះ ជាសកម្មភាពចុងក្រោយក្នុងកម្មវិធីអបអរសាទរខួបលើកទី២០ របស់ CDRI (១៩៩០-២០១០) និងមានចែកចេញជា ៦ វគ្គ៖

- ការវិវត្តនៅប្រទេសកម្ពុជា៖ ឱកាស និងបញ្ហាប្រឈមសម្រាប់ CDRI
- ការពិនិត្យឡើងវិញពីគោលដៅសំខាន់ៗនៃផែនការយុទ្ធសាស្ត្រឆ្នាំ២០០៦-២០១០ របស់ CDRI៖ តើយើងសម្រេចបានអ្វីខ្លះ? តើមានអ្វីខ្លះដែលយើងមិនទាន់សម្រេចបានល្អ? តើយើងអាចដកស្រង់មេរៀនអ្វីខ្លះសម្រាប់ថ្ងៃខាងមុខ?
- យុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ របស់ CDRI៖ ប្រធានបទ សំណួរ និងបញ្ហាចំបងៗ
- សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០១០ នៃកម្មវិធីទាំងអស់របស់ CDRI ។ អាទិភាព និងបញ្ហានានា សម្រាប់ផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥
- មាគ៌ាឆ្ពោះទៅមុខសម្រាប់ CDRI៖ តើយើងចង់ឲ្យ CDRI មានការវិវត្តខុសប្លែកពីមុនយ៉ាងដូចម្ដេចនៅឆ្នាំ២០១៥? អាទិភាពសម្រាប់ដំណាក់កាលខាងមុខនៃការពង្រឹងស្ថាប័ន និងការគ្រប់គ្រងបន្តវេននៅ CDRI

*(តទៅទំព័រ ២៩)*

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្ដី
អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៤ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០១០

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ផ្ដល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្ដល់ជូននូវមូលវិចារឯករាជ្យស្ដីពីដំណើរប្រព្រឹត្តទៅ នៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ ខេង សេង និង អ៊ឹង សុជាតិ
រោងពុម្ពអង្គរអុហ្វសិត ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១០ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។